00710384

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

Extraordinary Chambers in the Courts of Cambodia

Chambres Extraordinaires au sein des Tribunaux Cambodgiens

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia
Nation Religion King

Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះសាលាដំបូង

Trial Chamber

Chambre de Premiere instance

ឯកសារដើម

ORIGINAL/ORIGINAL

ថ្ងៃ ខែ ឆ្នាំ (Date): 28-Jun-2011, 14:25

CMS/CFO: Sann Rada

**<u>កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃកិច្ចដំណើរការនីតិវិធីជំនុំជម្រះក្តីលើ</u>**

សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អវតក/អជសដ

**<u>សាធារណៈ</u>**

**ថ្ងៃទី២៧ ខែមិថុនា ឆ្នាំ២០១១**

**សវនាការបឋម**

**ម៉ោង ០៩: ០០នាទី**

**ចៅក្រមសាលាដំបូង៖**

ចៅក្រម និល ណុន ជាប្រធាន

ចៅក្រម ស៊ីលវៀ ខាតរ៉ាយថ៍

*(Judge Silvia Carwright)*

ចៅក្រម យ៉ា សុខន

ចៅក្រម ហ្សង់ម៉ាក ឡាវែន៍

*(Judge Jean-Marc Lavegne)*

ចៅក្រម ធូ មណី

ចៅក្រម យូរ ឧត្តរា

ចៅក្រម ក្លូឌា ហ្វេនស៍

*(Judge Claudia Fenz)*

**ក្រឡាបញ្ជីសាលាដំបូង៖**

លោកស្រី សែ កុលវុឌ្ឍី

លោក ឌុច ផារី

លោកស្រី ស៊ូហ្សាន ឡេម *(Ms.Susan LAMB)*

កញ្ញា ណាតាចា វីស៊ែល រីសឺ

*(Ms. Natacha Wexels-Riser)*

លោកស្រី ហ្វេនហ្ស៊ីស្កា អេកកែលមិន

*(Ms. Franziska Eckelmans)*

**ការិយាល័យសហព្រះរាជអាជ្ញា៖**

លោកស្រី ជា លាង

លោក អាន់ឌ្រូ ខេលី *(Mr.Andrew CAYLEY)*

លោក ច័ន្ទ តារាវស្មី

**មេធាវីការពារជនជាប់ចោទ នួន ជា៖**

លោក សុន អរុណ

លោក ម៉ៃខល ផេសមិន

00710385

(Mr. Michiel PESTMAN)

លោក វិចទ័រ កូប៉េ(Mr.Victor KOPPE)

**ជនជាប់ចោទ៖**

លោក នួន ជា

លោក ខៀវ សំផន

លោក អៀង សារី

លោកស្រី អៀង ធីរិទ្ធ

**មេធាវីការពារជនជាប់ចោទ ខៀវ សំផន៖**

លោក ស សូវ៉ាន

លោក ហ្សាក់ វែកហ្សេស

(Mr. Jacques VERGES)

**មេធាវីការពារជនជាប់ចោទ អៀង ធីរិទ្ធ៖**

លោក ផាត់ ពៅស៊ាង

លោកស្រី កាលីង វ៉ាន់ដឺវូត

(Ms.Karlijn Van der Voort)

**មេធាវីការពារជនជាប់ចោទ អៀង សារី៖**

លោក អាង ឧត្តម

លោក ម៉ៃខល កាណាវ៉ាស

(Mr.Michael KARNAVAS)

**មេធាវីតំណាងដើមបណ្ដឹងរដ្ឋប្បវេណី៖**

លោក ពេជ អង្គ

លោកស្រី អេលីហ្សាបេត ស៊ីម៉ុនណូហ្វត

(Ms. Elisabeth SIMONNEAU-FORT)

លោកស្រី ម៉ុច សុវណ្ណារី

លោកស្រី ម៉ាទីន ហ្សាកកាំង

(Ms. Martine Jaquin)

លោកស្រី ស៊ីលឃីស្ទួត ហ្ស៊ីនស្គី

(Ms. Silke Stuzinsky)

លោកស្រី ហ្វាប៊ីយ៉ែន ទ្រូស្ស ណាព្រូស

(Ms. Fabienne Trusses-Naprous)

លោក អូលីវីយេ បាហ៊ូញ

(Mr. Olivior Bahougne)

កញ្ញា លី ម៉ាញៀន (Ms.Lyma Nguyen)

លោក ប៉ាស្កាល់ អូប៊ីង (Mr. Pascal Aubouin)

លោក គ្រីស្ទីន ម៉ាទីណូ

(Mr. Chritine Martinau)

កញ្ញា ហ្វីលីពីន ស៊ុតហ្ស៍ (Ms.Phillipine Sutz)

លោក អេម៉ានូអែល ហ្សាកូមី

(Ms.Emanuel Jacomy)

**ផ្នែកគ្រប់គ្រងតុលាការ៖**

លោក អ៊ុំ អរុណ

## បញ្ជីឈ្មោះអ្នកនិយាយ៖

ភាសាដែលបានប្រើ លើកលែងតែមានការបញ្ជាក់ផ្សេងទៀតនៅក្នុងប្រតិចារឹក

| អ្នកនិយាយ | ភាសា |
|---|---|
| ចៅក្រម និល ណុន (ប្រធានអង្គជំនុំ) | ខ្មែរ |
| ចៅក្រម ស៊ីលវៀ ខាតវ៉ាយថ៍ | អង់គ្លេស |
| ចៅក្រម ហ្សង់ម៉ាក ឡាវែន៍ | បារាំង |
| លោកស្រី ជា លាង | ខ្មែរ |
| លោក អាន់ឌ្រូ ខេលី | អង់គ្លេស |
| លោក សុន អរុណ | ខ្មែរ |
| លោក ម៉ៃខល ផេសមិន | អង់គ្លេស |
| លោក រ៉ិចឆ័រ កូប៉េ | អង់គ្លេស |
| លោក ស សូវាន | ខ្មែរ |
| លោក ផាត់ ពៅស៊ាង | ខ្មែរ |
| លោកស្រី កាលីង វ៉ាន់ដឺវូត | អង់គ្លេស |
| លោក អាង ឧត្តម | ខ្មែរ |
| លោក ម៉ៃខល កាណាវាស | អង់គ្លេស |
| លោក ពេជ អង្គ | ខ្មែរ |
| លោកស្រី អេលីហ្សាបេត ស៊ីម៉ុនណូហ្វត | បារាំង |
| លោកស្រី ម៉ុច សុវណ្ណារី | ខ្មែរ |
| លោកស្រី ម៉ាទីន ហ្សាកកាំង | បារាំង |
| លោក នួន ជា | ខ្មែរ |
| លោកស្រី សែ កុលវុឌ្ឍី | ខ្មែរ |

# កិច្ចដំណើរការនីតិវិធី

*(ចៅក្រមចូលក្នុងបន្ទប់សវនាការ)*

[០៩:០០:៣៧]

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញអស់លោក លោកស្រីអង្គុយចុះ!

ថ្ងៃនេះ ថ្ងៃច័ន្ទ ទី២៧ ខែមិថុនា ឆ្នាំ២០១១ អង្គជំនុំជម្រះសាលាដំបូងនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា បើកសវនាការបឋមលើសំណុំរឿងលេខ០០២ ដែលមានជនជាប់ចោទចំនួនបួនរូប។ មួយ ឈ្មោះ នួន ជា ភេទ ប្រុស កើតថ្ងៃទី២៧ ខែកក្កដា ឆ្នាំ១៩២៦។ ពីរ ឈ្មោះ ខៀវ សំផន ភេទ ប្រុស កើតនៅថ្ងៃទី២៧ ខែកក្កដា ឆ្នាំ១៩៣១។ បី ឈ្មោះ អៀង សារី ភេទ ប្រុស កើតនៅថ្ងៃទី២៤ ខែតុលា ឆ្នាំ១៩២៥។ បួន ឈ្មោះ អៀង ធីរិទ្ធ ភេទ ស្រី កើតនៅថ្ងៃទី១០ ខែមីនា ឆ្នាំ១៩៣២។

ជនជាប់ចោទទាំងបួនរូបនេះ ត្រូវជាប់ចោទពីបទឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ តាមរយៈការសម្លាប់សមាជិកក្រុមជនជាតិចាមនិងវៀតណាម។ ការបំពារបំពានយ៉ាងធ្ងន់ធ្ងរលើអនុសញ្ញាទីក្រុងហ្សឺណែវ ចុះថ្ងៃទី១២ ខែសីហា ឆ្នាំ១៩៤៩ និងការបំពារបំពានលើក្រមព្រហ្មទណ្ឌកម្ពុជាឆ្នាំ១៩៥៦ ដែលរួមមាន ការធ្វើមនុស្សឃាត ការធ្វើទារុណកម្ម ការវាយប្រហារលើសាសនា ដែលបានប្រព្រឹត្តតាមរយៈអំពើសកម្ម និងអកម្ម ដោយបានចូលរួមក្នុងសហឧក្រិដ្ឋកម្មរួមរៀបចំផែនការញុះញង់ឲ្យប្រព្រឹត្ត បញ្ជាឲ្យមានការប្រព្រឹត្ត ជួយ និងជំរុញដល់ចារីឲ្យប្រព្រឹត្តនៅទីក្រុងភ្នំពេញ និងនៅលើទឹកដីនៃព្រះរាជាណាចក្រកម្ពុជាក្នុងអំឡុងពេលពីថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ រហូតដល់ថ្ងៃទី៦ ខែមករា ឆ្នាំ១៩៧៩។

[០៩:០៣:០៦]

សមាសភាពចៅក្រមនៃអង្គជំនុំជម្រះសាលាដំបូងរួមមាន មួយ គឺរូប ខ្ញុំឈ្មោះ និល ណុន ជាប្រធាន។ ពីរ លោកស្រីចៅក្រម ស៊ីលវៀ ខាតវ៉ាយថ៍។ បី លោកចៅក្រម យ៉ា សុខន។ បួន លោកចៅក្រម ហ្សង់មាក ឡាវែន៍។ ប្រាំ លោកចៅក្រម ធូ មណី និងមានចៅក្រមបម្រុងចំនួនពីររូបគឺ មួយ លោកចៅក្រម យូរ ឧត្តរា ពីរ លោកស្រីចៅក្រម ក្លូឌា ហ្វេនស៍។

សវនាការបឋមនេះ ប្រព្រឹត្តទៅដោយអនុលោមតាមវិធាន៨០ស្ទួន នៃវិធានផ្ទៃក្នុង អ.វ.ត.ក។ អនុលោមតាមវិធាននេះ និងដូចដែលមានបញ្ជាក់នៅក្នុងរបៀបវារៈដែលអង្គជំនុំជម្រះបានផ្ញើជូនទៅភាគី

កាលពីថ្ងៃទី១៤ ខែមិថុនា ឆ្នាំ២០១១ ក្នុងពេលសវនាការនេះអង្គជំនុំជម្រះត្រូវពិចារណាលើបញ្ជីឈ្មោះសាក្សី ដើមបណ្ដឹងរដ្ឋប្បវេណី និងអ្នកជំនាញ ដែលបានស្នើឡើងដោយភាគី ហើយបុគ្គលទាំងនោះជាប់ទាក់ទងទៅនឹងលំដាប់នៃអង្គហេតុដំបូងដែលត្រូវធ្វើសវនាការ។ អង្គជំនុំជម្រះនឹងពិចារណាផងដែរទៅលើបញ្ហាអញ្ញត្រកម្មដែលមានចែងនៅក្នុងវិធាន៨៩ ហើយអង្គជំនុំជម្រះនឹងផ្ដល់ពេលវេលាទៅឲ្យសហមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណី ដើម្បីធ្វើការបញ្ជាក់លម្អិតបឋម អំពីខ្លឹមសារសំណងដែលពួកគាត់មានបំណងចង់ទាមទារ ដោយអនុលោមតាមវិធាន២៣ស្ទួនបី អនុវិធាន៣ ត្រង់ចំណុចខ នៃវិធានផ្ទៃក្នុង អ.វ.ត.ក។

[០៩:០៤:៤៧]

ទោះបីជារបៀបវារៈដែលបានផ្ញើជូនទៅភាគី ត្រូវបានធ្វើឡើងក្នុងគោលបំណងដើម្បីផ្ដល់ការណែនាំដល់ភាគី អំពីការកំណត់កាលបរិច្ឆេទ សម្រាប់សវនាការបឋមក៏ដោយ កាលបរិច្ឆេទនិងពេលវេលាទាំងនោះ គឺគ្រាន់តែជាការចង្អុលបង្ហាញតែប៉ុណ្ណោះ។ អង្គជំនុំជម្រះរក្សាសិទ្ធិក្នុងការកែប្រែនូវកាលបរិច្ឆេទនិងពេលវេលាទាំងអស់នោះ អាស្រ័យទៅលើការវិវឌ្ឍន៍នៃការពិភាក្សាលើចំណុចនីមួយៗនៅថ្ងៃបន្តបន្ទាប់។

ជាកិច្ចបន្ត មុននឹងឈានចូលដល់ការទាញហេតុផលនូវរបៀបវារៈ ដែលបានគ្រោងទុកសូមលោកស្រី អញ្ជើញលោកស្រី សែ កុលវុឌ្ឍី ឡើងរាយការណ៍អំពីស្ថានភាព វត្តមាន និងអវត្តមានភាគីដែលត្រូវអញ្ជើញចូលរួមនៅក្នុងដំណើរការសវនាការបឋមនាថ្ងៃនេះ។ សូមអញ្ជើញ!

[០៩:០៥:៥៤]

**លោកស្រី សែ កុលវុឌ្ឍី៖**

សូមគោរពលោកប្រធាន, ភាគីដែលត្រូវចូលរួមនៅក្នុងថ្ងៃនេះមានវត្តមាននិងអវត្តមានដូចតទៅ៖ សហព្រះរាជអាជ្ញា មានវត្តមានគ្រប់ចំនួន។ ជនជាប់ចោទមានវត្តមានវត្តមានគ្រប់ចំនួន។ មេធាវីការពារឲ្យជនជាប់ចោទមានវត្តមានគ្រប់ចំនួន។ លើកលែងតែមេធាវីអន្តរជាតិការពារឲ្យជនជាប់ចោទលោកស្រី អៀង ធីរិទ្ធ លោកស្រីមេធាវី ដាយអាណា អេលីស អវត្តមាន។ ដោយឡែក មេធាវីតំណាងឲ្យដើមបណ្ដឹងរដ្ឋប្បវេណីមានវត្តមានចំនួន១៣រូប ក្នុងនោះមានមេធាវីជាតិចំនួន៣រូប និងមេធាវីអន្តរ-ជាតិមានចំនួន១០រូប។

[០៩:០៦:២៩]

**ប្រធានអង្គជំនុំ៖**

អរគុណលោកស្រី សែ កុលវុឌ្ឍី។

ជាកិច្ចបន្ត គឺធ្វើនីតិវិធីបង្ហាញខ្លួន និងការទទួលស្គាល់មេធាវីបរទេស។

ដោយអនុលោមតាមវិធាន២២ អនុវិធាន២ ចំណុច ក នៃវិធានផ្ទៃក្នុង មុនពេលចាប់ផ្តើមដំណើរការសវនាការ អង្គជំនុំជម្រះសូមអញ្ជើញមេធាវីជាតិ ក្រុមមេធាវីនីមួយៗឡើងសុំការទទួលស្គាល់មេធាវីបរទេសក្នុងក្រុមរបស់ខ្លួនដែលមិនទាន់បានស្នើសុំការទទួលស្គាល់ពីអង្គជំនុំជម្រះសាលាដំបូង នៅដំណាក់កាលមុន។

ជាដំបូងនេះ គឺសូមអញ្ជើញលោកមេធាវី ស សូវ៉ាន ឡើងធ្វើស្នើសុំការទទួលស្គាល់មេធាវីបរទេសដែលនៅក្នុងក្រុមរបស់លោកមិនទាន់បានធ្វើការស្នើសុំការទទួលស្គាល់ពីអង្គជំនុំជម្រះសាលាដំបូង។ សូមអញ្ជើញ!

[០៩:០៧:២៥]

**លោក ស សូវ៉ាន៖**

សូមអរគុណលោកប្រធាន និងគោរពអង្គជំនុំជម្រះ។

ខ្ញុំសូមបង្ហាញលោកមេធាវី ហ្សាក់ វែកហ្សេស ជាមេធាវីអន្តរជាតិ របស់លោកអតីតប្រមុខរដ្ឋ លោក ខៀវ សំផន។

**ប្រធានអង្គជំនុំ៖**

សូមអរគុណលោក ស សូវ៉ាន។

លោក ហ្សាក់ វែកហ្សេស លោកត្រូវបានអង្គជំនុំជម្រះសាលាដំបូងទទួលស្គាល់ថា លោកជាមេធាវីការពារក្តីសម្រាប់គោលបំណង នៃកិច្ចដំណើរការនីតិវិធីនៅចំពោះមុខអង្គជំនុំជម្រះ តាមរយៈការទទួលស្គាល់នេះ លោកមេធាវីទទួលបាននូវសិទ្ធិនិងបុព្វសិទ្ធិ ដូចគ្នានឹងមេធាវីជាតិដែរ។

សូមអង្គុយចុះលោក ស សូវ៉ាន!

[០៩:០៨:៣១]

អង្គជំនុំជម្រះកត់សម្គាល់នូវវត្តមានរបស់លោក ពេជ អង្គ សហមេធាវីជាតិនាំមុខតំណាងឲ្យដើមបណ្តឹងរដ្ឋប្បវេណី និងលោកស្រី អេលីហ្សាបេត ស៊ីម៉ុនណូហ្វត សហមេធាវីអន្តរជាតិនាំមុខតំណាងឲ្យដើមបណ្តឹងរដ្ឋប្បវេណី ដែលត្រូវបានតែងតាំងដោយ អ.វ.ត.ក កាលពីពេលថ្មីៗអនុលោម

តាមវិធាន១២ស្ទួន អនុវិធាន១ នៃវិធានផ្ទៃក្នុង។

ជាកិច្ចបន្ត អង្គជំនុំជម្រះសូមអញ្ជើញលោក ពេជ អង្គ សហមេធាវីជាតិនាំមុខតំណាងឲ្យដើមបណ្តឹងរដ្ឋប្បវេណីឡើងស្នើសុំការទទួលស្គាល់មេធាវីតំណាងឲ្យដើមបណ្តឹងរដ្ឋប្បវេណីបរទេសដែលមានវត្តមាននៅទីនេះ ដោយអនុលោមតាមវិធាន២២ អនុវិធាន២ ចំណុច ក នៃវិធានផ្ទៃក្នុង។

សូមអញ្ជើញលោក ពេជ អង្គ!

[០៩:០៩:៣៧]

**លោក ពេជ អង្គ៖**

សូមគោរពលោក លោកស្រីចៅក្រម ដែលមានវត្តមានទីនេះ លោកជំទាវសហព្រះរាជអាជ្ញា លោកសហព្រះរាជអាជ្ញា អស់លោក លោកស្រីមេធាវី និងបងប្អូន ដែលមានវត្តមានទីនេះ។

ខ្ញុំបាទ ពេជ អង្គ សូមធ្វើការបញ្ជាក់បន្ថែមបន្តិច ដោយសារអម្បាញ់មិញក្រឡាបញ្ជីបានបញ្ជាក់ពីចំនួននៃមេធាវីដែលបានមានវត្តមានខាងតំណាងឲ្យដើមបណ្តឹងរដ្ឋប្បវេណី។ នៅក្នុងនេះគឺមានវត្តមានមេធាវីជាតិតែខ្ញុំម្នាក់ទេនៅខាងដើមបណ្តឹងរដ្ឋប្បវេណី ហើយមេធាវីជាតិបីនាក់ទៀត ដែលត្រូវមានវត្តមាននៅពេលនេះ មិនអាចមានវត្តមាននៅទីនេះបាន ដោយសារថាកៅអីមានកំណត់ ហើយគាត់នឹងចូលមកក្នុងសវនាការនេះ នៅពេលសម្រាកបន្ទាប់ពី ប្រហែលជាម៉ោងដប់នេះ។

[០៩:១០:៣១]

ហើយទាក់ទងទៅនឹងការទទួលស្គាល់មេធាវីអន្តរជាតិនៅទីនេះ ខ្ញុំមានកិត្តិយសសូមជម្រាបថា នៅថ្ងៃនេះ គឺយើងមានមេធាវីអន្តរជាតិតំណាងឲ្យដើមបណ្តឹងរដ្ឋប្បវេណីមានប្រាំបួនរូប ដែលមានវត្តមាននៅទីនេះ ហើយពីមុនខ្ញុំបាទបានសុំឲ្យអង្គជំនុំជម្រះទទួលស្គាល់រួចហើយ នូវមេធាវីអន្តរជាតិចំនួនពីររូប ហើយមេធាវីអន្តរជាតិប្រាំបួនរូបនេះ គឺស្ថិតនៅក្នុងក្រុមមេធាវីចំនួនប្រាំបួន ដែលតំណាងឲ្យកូនក្តីសរុបទាំងអស់៣.៨៥០រូប ដែលបើគិតទៅតាមលទ្ធផលនៃការសម្រេចរបស់អង្គបុរេជំនុំជម្រះដែលបានចេញនៅថ្ងៃសុក្រ ទី២៤ ខែមិថុនា ឆ្នាំ២០១១ នេះ ហើយដែលអនុញ្ញាតឲ្យអ្នកដែលទើបតែទទួលត្រូវបានទទួលស្គាល់ជាដើមបណ្តឹងរដ្ឋប្បវេណីថ្មីៗនេះ ទទួលសិទ្ធិពេញលេញជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ខ្លួន ហើយទាំងមេធាវីនាំមុខ ទាំងមេធាវីតំណាងឲ្យដើមបណ្តឹងរដ្ឋប្បវេណីទាំងអ្នកដែលត្រូវបានចាត់ទុកថាជាដើមបណ្តឹងរដ្ឋប្បវេណី មានការត្រេកអរចំពោះសេចក្តីសម្រេចរបស់អង្គបុរេជំនុំជម្រះ។

នៅខាងក្រោយយើងខ្ញុំនេះ គឺមានមេធាវីអន្តរជាតិចំនួន៩រូប ដែលខ្ញុំសូមជម្រាបជូន ហើយនិង

ស្នើសុំដល់អង្គជំនុំជម្រះទទួលស្គាល់មេធាវីទាំងអស់នោះដូចតទៅៈ

[០៩:១២:១១]

ទីមួយ គឺកញ្ញា លី ម៉ាញឿន សូមអញ្ជើញក្រោកឈរ!

កញ្ញា លី ម៉ាញឿន ជាមេធាវីអន្តរជាតិដែលអញ្ជើញមកពីប្រទេសអូស្រ្តាលី ដែលតំណាងឱ្យកូនក្ដីដែលជាជនជាតិបរទេស ជាខ្មែរដែលស្ថិតនៅក្រៅប្រទេស និងជាជនជាតិភាគតិចវៀតណាមមួយចំនួន ហើយគាត់មានដៃគូរបស់គាត់គឺ លោក សំ សុគង់ ដែលស្ថិតនៅក្នុងអង្គការ អិល.អេ.ស៊ី ជំនួយផ្លូវច្បាប់កម្ពុជា។

ទីពីរ គឺលោកមេធាវី អូលីយ៉េ បាហ៊ូញ។

លោក អូលីវីយ៉េ បាហ៊ូញ ជាមេធាវីអន្តរជាតិមកពីប្រទេសបារាំង ដែលតំណាងឱ្យជនរងគ្រោះដែលជាជនជាតិចាម និងជនរងគ្រោះដោយមូលហេតុសាសនា ជាមួយនឹងដៃគូរបស់គាត់ គឺលោកមេធាវី ឡោ ជុនធី មកពីអង្គការជំនួយផ្លូវច្បាប់កម្ពុជា។

[០៩:១៣:២៩]

ទីបី គឺលោក អេម៉ានូអែល ហ្សាកូមី ជាមេធាវីអន្តរជាតិមកពីប្រទេសបារាំង ដែលតំណាងឱ្យដើមបណ្ដឹងរដ្ឋប្បវេណី ដែលរស់នៅទីក្រុងភ្នំពេញ ហើយនិងប្រទេសបារាំង ហើយដែលមានដៃគូរបស់គាត់ គឺលោក សំ សុគង់ មកពីអង្គការការពារច្បាប់កម្ពុជា។

ទីបួន គឺកញ្ញា ហ្វីលីពីន ស៊ុតហ្ស៍ មានវត្តមានទីនេះ។ កញ្ញាគឺជាមេធាវីអន្តរជាតិ ដែលមកពីប្រទេសបារាំង ហើយស្ថិតនៅក្នុងក្រុមជាមួយនិងលោក អេម៉ានូអែល ហ្សាកូមី ហើយមានដៃគូគឺលោក សំ សុគង់ ខាងអង្គការជំនួយផ្លូវច្បាប់កម្ពុជា។

[០៩:១៤:២២]

ទីប្រាំ គឺលោកស្រី ស៊ីលឃី ស្ទូតហ្សីនស្គី ដែលមានវត្តមាននៅទីនេះ ជាមេធាវីអន្តរជាតិមកពីប្រទេសអាល្លឺម៉ង់ ដែលតំណាងកូនក្ដីជាទូទៅផងដែរ ហើយជាពិសេសកូនក្ដីដែលជាជនរងគ្រោះដោយមូលហេតុយ៉េនឌ័។ គាត់មានដៃគូរបស់គាត់គឺ មេធាវីមកពីខាងអង្គការជំនួយផ្លូវច្បាប់ ហើយនិងអង្គការការពារសិទ្ធិមនុស្សកម្ពុជា។

ទីប្រាំមួយ លោក ប៉ាស់ ស្កាល់អូប៉ីង ជាមេធាវីអន្តរជាតិមកពីប្រទេសបារាំង តំណាងកូនក្ដីដែលរស់នៅប្រទេសបារាំង ដែលមានដៃគូជាតិរបស់គាត់គឺ លោក ហុង គឹមសួន មកពីអង្គការការពារសិទ្ធិ

មនុស្សកម្ពុជា។

ទីប្រាំពីរ គឺលោកស្រីមេធាវី ម៉ាទីន ហ្សាកាំង។ លោកស្រី ម៉ាទីន ហ្សាកាំង គឺជាមេធាវីអន្តរជាតិ ជនជាតិបារាំង មកពីប្រទេសបារាំង ហើយតំណាងឲ្យកូនក្តីទូទៅជាមួយនឹងមេធាវីជាតិរបស់គាត់ពីររូប គឺលោក គឹម ម៉េងឃី ហើយនិងលោកស្រី ម៉ុច សុវណ្ណារី នៅក្នុងក្រុមរបស់គាត់ ហើយតំណាង ហើយដូចគ្នាដែរគឺ លោកស្រីមេធាវី ហ្វាប៊ីយ៉ែន ទ្រូស្ស ជាមេធាវីនៅក្នុងក្រុម អា.អេស.ហ្វេស ដូចលោកស្រីមេធាវី ម៉ាទីន ហ្សាកាំង ដូច្នេះដែរ គាត់អញ្ជើញមកពីទីក្រុងបារាំង ហើយស្ថិតតំណាងកូនក្តីជាមួយលោក គឹម ម៉េងឃី និងលោកស្រី ម៉ុច សុវណ្ណារី ដូចគ្នា។

ទីប្រាំបួន ហើយនិងចុងក្រោយគេបង្អស់គឺ លោកស្រីមេធាវី គ្រីស្ទីន ម៉ាទីនណូ ជាមេធាវីជនជាតិបារាំងនៅក្នុងក្រុមមេធាវីគ្មានព្រំដែនដូចគ្នា ជាមួយមេធាវីពីរនាក់មុន។ ហើយមានដៃគូដដែលគឺលោក គឹម ម៉េងឃី និងលោកស្រី ម៉ុច សុវណ្ណារី។ ដូច្នេះ នេះគឺជាមេធាវីអន្តរជាតិដែលមានវត្តមាននៅពេលនេះ ហើយដែលមានបំណង មេធាវីនាំមុខមានបំណងស្នើសុំឲ្យតុលាការទទួលស្គាល់លោកស្រី ហើយនិង លោកមេធាវីទាំងអស់នេះ ដើម្បីឲ្យមានសិទ្ធិបំពេញកិច្ចការតំណាងកូនក្តីរបស់ខ្លួនគ្រប់គ្រាន់នៅក្នុងចំពោះមុខ អ.វ.ត.ក នេះ។

បាទ, សូមអរគុណ។

[០៩:១៧:១៤]

**ប្រធានអង្គជំនុំ៖**

បាទ, សូមអរគុណ លោកមេធាវី ពេជ អង្គ។

លោក លោកស្រីមេធាវីអន្តរជាតិតំណាងដើមបណ្តឹងរដ្ឋប្បវេណីចំនួន៩រូប ដែលមានឈ្មោះដូចដែលលោកមេធាវី ពេជ អង្គ បានឡើងធ្វើការស្នើសុំឲ្យ អង្គជំនុំជម្រះទទួលស្គាល់អម្បាញ់មិញនេះ។ អង្គជំនុំជម្រះសាលាដំបូងទទួលស្គាល់ថា លោក លោកស្រី ជាមេធាវីតំណាងឲ្យដើមបណ្តឹងរដ្ឋប្បវេណីសម្រាប់គោលបំណងនៃកិច្ចដំណើរការនីតិវិធីចំពោះមុខអង្គជំនុំជម្រះសាលាដំបូង។ តាមរយៈការទទួលស្គាល់នេះ លោក លោកស្រី ទទួលបានសិទ្ធិ និងបុព្វសិទ្ធិ ដូចគ្នានឹងមេធាវីជាតិ តំណាងដើមបណ្តឹងរដ្ឋប្បវេណីដែរ។

[០៩:១៨:១២]

ជាកិច្ចបន្ត អង្គជំនុំជម្រះសូមណែនាំដល់មន្ត្រីរដ្ឋបាលតុលាការ ដែលរៀបចំនូវកិច្ចដំណើរការ

សម្របសម្រួលនៃកិច្ចដំណើរការក្នុងសវនាការនេះថា ដើម្បីឲ្យកិច្ចដំណើរការធ្វើនីតិវិធីទាញហេតុផលផ្ទាល់មាត់នាពេលនេះ និងនាពេលខាងមុខប្រព្រឹត្តទៅបានល្អ និងអាចរក្សានូវសណ្តាប់ធ្នាប់ ទស្សនីយភាពក្នុងបន្ទប់សវនាការដែលមានជនជាប់ចោទមានវ័យចាស់ មានការពិបាកនៅក្នុងការបន្លាស់ទី។ យើងខ្ញុំណែនាំដល់មន្ត្រីតុលាការនៅទីនេះឲ្យដំណើរការ សូមរូតវាំងននបិទបន្ទប់សវនាការនៅក្រោយពេលដែលចៅក្រមនៃអង្គជំនុំជម្រះសាលាដំបូងដកខ្លួនចេញពីអាសនៈទៅបន្ទប់ពិភាក្សា ឬក៏ឈប់សម្រាក និងឲ្យបើកវាំងននវិញឲ្យបានមុនបន្តិច មុនពេលចៅក្រមអង្គជំនុំជម្រះសាលាដំបូងចូលកាន់ទីអាសនៈ។

នេះជាការណែនាំទូទៅដែលអនុវត្តរហូត លើកលែងតែមានការណែនាំផ្សេងពីនេះ។

ជាកិច្ចបន្ត ឈានចូលដល់របៀបវារៈ ការប្រកាសអំពីបញ្ជីឈ្មោះសាក្សី ដើមបណ្តឹងរដ្ឋប្បវេណី និងអ្នកជំនាញបណ្តោះអាសន្ន សម្រាប់ដំណាក់កាលដំបូងនៃការជំនុំជម្រះអង្គសេចក្តី។

[០៩:១៩:៥៥]

នៅក្នុងកិច្ចប្រជុំរៀបចំសវនាការ អង្គជំនុំជម្រះបានប្រាប់ដល់ភាគី អំពីចេតនារបស់អង្គជំនុំជម្រះក្នុងការចាប់ផ្តើមសវនាការលើអង្គសេចក្តីទៅតាមលំដាប់នៃអង្គហេតុដូចខាងក្រោម៖

១- រចនាសម្ព័ន្ធរបបកម្ពុជាប្រជាធិបតេយ្យ។

២-តួនាទីរបស់ជនជាប់ចោទម្នាក់ៗ នៅមុនពេលមានការបង្កើតរបបកម្ពុជាប្រជាធិបតេយ្យ និងនៅពេលជនជាប់ចោទម្នាក់ៗបានទទួលការចាត់តាំងនូវតួនាទីនេះ។

៣-តួនាទីរបស់ជនជាប់ចោទម្នាក់ៗ ក្នុងជួររដ្ឋាភិបាលកម្ពុជាប្រជាធិបតេយ្យ ការទទួលខុសត្រូវរបស់ពួកគាត់តាមការចាត់តាំងក្របខ័ណ្ឌនៃសិទ្ធិអំណាចរបស់ពួកគាត់ និងខ្សែបណ្តាញទាក់ទងនៅក្នុងរយៈកាលដែលពាក់ព័ន្ធ និងយុត្តាធិការពេលវេលារបស់ អ.វ.ត.ក។

[០៩:២០:៥០]

៤-គោលនយោបាយនៃរបបកម្ពុជាប្រជាធិបតេយ្យ ស្តីពីបញ្ហាទាំងឡាយដែលបានលើកឡើងនៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះ។ គោលបំណងនៃការចង្អុលបង្ហាញដំបូងនេះ គឺត្រូវបានធ្វើឡើងដើម្បីជូនដំណឹងដល់ភាគីឲ្យបានដឹងជាមុន ទាក់ទងនឹងលំដាប់នៃអង្គហេតុដែលការរៀបចំសម្រាប់សវនាការ។

អង្គជំនុំជម្រះក៏បានប្រកាសថា ខ្លួននឹងជូនដំណឹងជាមុនអំពីបញ្ជីឈ្មោះសាក្សី អ្នកជំនាញដើមបណ្តឹងរដ្ឋប្បវេណី ដែលអង្គជំនុំជម្រះនឹងត្រូវកោះហៅពាក់ព័ន្ធនឹងអង្គហេតុនីមួយៗដើម្បីអនុញ្ញាតឲ្យភាគីអង្គភាពគាំពារសាក្សី និងអ្នកជំនាញអាចត្រៀមរៀបចំទាន់ពេលវេលា។

[០៩:២១:៣៩]

ដើម្បីជួយដល់អង្គជំនុំជម្រះក្នុងការកំណត់នូវសាក្សីដើមបណ្ដឹងរដ្ឋប្បវេណី អ្នកជំនាញដែលពាក់ព័ន្ធទៅនឹងលំដាប់នៃអង្គហេតុដែលត្រូវធ្វើសវនាការទាំងនេះ អង្គជំនុំជម្រះបានស្នើសុំឱ្យភាគីផ្ដល់បន្ថែមទៀតនូវបញ្ជីឈ្មោះសាក្សី ដើមបណ្ដឹងរដ្ឋប្បវេណី និងអ្នកជំនាញ ដែលភាគីមានបំណងស្នើសុំឱ្យកោះហៅពាក់ព័ន្ធនឹងអង្គហេតុនីមួយៗត្រឹមថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០១១។

ផ្អែកតាមបញ្ជីឈ្មោះបន្ថែម និងបញ្ជីឈ្មោះសាក្សី ដើមបណ្ដឹងរដ្ឋប្បវេណី និងអ្នកជំនាញដែលបានដាក់ពីពេលមុន អង្គជំនុំជម្រះបានរៀបចំបញ្ជីឈ្មោះសាក្សី ដើមបណ្ដឹងរដ្ឋប្បវេណី និងអ្នកជំនាញបណ្ដោះអាសន្នមួយដែលអង្គជំនុំជម្រះគ្រោងនឹងកោះហៅសម្រាប់អង្គហេតុ ដែលត្រូវធ្វើការជំនុំជម្រះនៅដំណាក់កាលដំបូង។

[០៩:២២:៣៤]

នៅក្នុងដំណាក់កាលនេះ ដើម្បីចៀសវាងនូវការធ្វើសវនាការជាអសាធារណៈ អង្គជំនុំជម្រះបានរៀបចំជាលាយលក្ខណ៍អក្សរនូវបញ្ជីឈ្មោះសាក្សី ដើមបណ្ដឹងរដ្ឋប្បវេណី និងអ្នកជំនាញ ជាលក្ខណៈបណ្ដោះអាសន្នមួយសម្រាប់ភាគី។ ហើយដែលបុគ្គលទាំងនោះ ត្រូវបានភាគីស្នើសុំឱ្យកោះហៅសម្រាប់អង្គហេតុដែលត្រូវធ្វើការជំនុំជម្រះដំបូង។

បញ្ជីឈ្មោះសាក្សី ដើមបណ្ដឹងរដ្ឋប្បវេណី និងអ្នកជំនាញ នឹងត្រូវចែងជូនទៅភាគីនៅពេលនេះ។ មន្ត្រីតុលាការសូមចាត់ចែង ចែកជូននូវបញ្ជីឈ្មោះសាក្សី អ្នកជំនាញ ដើមបណ្ដឹងរដ្ឋប្បវេណីបណ្ដោះអាសន្នដល់ភាគី។

សូមអញ្ជើញលោក សុន អរុណ!

[០៩:២៣:៤៥]

**លោក សុន អរុណ៖**

ខ្ញុំបាទ សុន អរុណ មេធាវីការពារលោក នួន ជា។ ជាបឋមនេះ ខ្ញុំបាទសូមគោរពអង្គសវនាការទាំងមូល សូមគោរពលោកប្រធាននៃអង្គសវនាការ។

ដោយយោងទៅលើកូនក្ដីខ្ញុំមានវ័យចាស់ជរា ហើយមានជំងឺមិនសូវជាស្រួលខ្លួនផង សូមលោកប្រធានមេត្តាអនុញ្ញាតឱ្យលោក នួន ជា ហ្នឹងបានពាក់មួក ពីព្រោះអីខ្យល់ត្រជាក់ប៉ះមកគាត់អង្គុយអត់បានយូរទេ បន្តិចឈាមវាឡើង អាហ្នឹងរឿងទីមួយ។ ហើយទីពីរ វ៉ែនតា គាត់ពាក់ សូមពាក់វ៉ែនតាខ្មៅ

ដើម្បីកុំឲ្យវាចាំងពន្លឺហ្នឹង តែចាំងទៅធ្វើទុក្ខក្បាលគាត់ទៀត។ ម្ល៉ោះហើយសូមលោកប្រធានមេត្តាអនុញ្ញាតពីរបែបបទនេះ បើសិនជាមិនយល់ទាស់។

[០៩:២៤:៥២]

រឿងមួយទៀត ខ្ញុំបាទក្នុងនាមជាមេធាវីការពារលោក នួន ជា បានស្នើតាមរយៈអក្សរៗ ជាលិខិតស្នាមទៅ ស៊ី.អឹម.អេស សុំឲ្យកៅអី និងតុរបស់មេធាវីការពារលោក នួន ជា ដែល អ៊ី.ស៊ី.ស៊ី.ស៊ី ទទួលស្គាល់ថាមេធាវីពេញច្បាប់ ជាមេធាវីដែលមានសិទ្ធិស្មើគ្នានឹងមេធាវីដទៃទៀត ម្ល៉ោះហើយសូមឲ្យតុលាការ ខាង ស៊ី.អឹម.អេស គេឆ្លើយមកថា គ្មានសមត្ថភាពនឹងរៀបចំហ្នឹងទេ ឲ្យសុំទៅខាងតុលាការ។

បើអ៊ីចឹងថ្ងៃនេះ ខ្ញុំបាទសុំលោកប្រធានអង្គសវនាការ មេត្តារៀបចំឲ្យបានមេធាវីខ្ញុំទាំងបីនាក់នេះមានសិទ្ធិស្មើគ្នា និងមានសិទ្ធិស្មើទៅមេធាវីដទៃទៀត មានសិទ្ធិស្មើទៅនឹងព្រះរាជអាជ្ញា ដើម្បីអង្គុយឲ្យបានស្រួល ដើម្បីនឹងជំនុំគ្នា និងជជែកគ្នា និងសរសេរក្នុងរឿងសវនាការ។ នៅពេលនេះមិនបាន មិនអាចធ្វើទាន់ ខ្ញុំដឹងអ៊ីចឹង ពីព្រោះខ្ញុំបានស្នើក្រោយពី អេស.អឹម.អេស មិនអនុញ្ញាតហើយ ខ្ញុំបានស្នើទៅខាងអ្នកស្រី នីហ្សា ដែលជាប្រធាន ឌី.អេស.អេស ហ្នឹងឲ្យស្នើមកខាងតុលាការ។ ប៉ុន្តែ មកដល់ថ្ងៃនេះខ្ញុំចូលមកក្នុងតុលាការ ខាងនោះប្អូន អរុណ នោះខាង អេស.អឹម.អេស ថាមិនអនុញ្ញាតទេ មានតែពីរទេៗ ខ្ញុំថាពេលនេះកាលពីលើកមុនបានឲ្យ អនុញ្ញាតឲ្យបីអង្គុយអ៊ីចឹង អង្គុយយ៉ាងពិបាកអ៊ីចឹង។ ហើយដល់អ៊ីចឹងទៅធ្វើការអត់កើតទេ ដល់ពេលចូលក្នុងសវនាការមែនទែន ដល់អង្គហេតុ អង្គសេចក្តី អង្គុយអ៊ីចឹងមួយឆ្នាំ កន្លះឆ្នាំ មួយឆ្នាំ អាហ្នឹងវេទនាដាច់។ សិទ្ធិអត់ស្មើគ្នាទេ។ ម្ល៉ោះហើយពេលនេះ សូមលោកប្រធានមេត្តាអនុញ្ញាតឲ្យរៀបចំតុសម្រាប់ពួកខ្ញុំបីនាក់នេះឲ្យបានសមរម្យ ដើម្បីមានពេលនឹងជជែកគ្នា មានពេលនឹងជំនុំគ្នា មានពេលនឹងសរសេរ ហើយនិងស្តាប់។ សូមអរគុណ។

[០៩:២៧:០១]

**ប្រធានអង្គជំនុំ៖**

អរគុណ លោកមេធាវី។

**លោក សុន អរុណ៖**

ខ្ញុំបាទ-- រឿងមួយទៀតកូនក្តីខ្ញុំបាទសុំ គាត់មាន ចង់មានប្រសាសន៍ចំពោះតុលាការ សូមជូនយោបល់ចំពោះតុលាការបើអនុញ្ញាត នៅពេលឥឡូវនេះ ខ្លីទេ បន្តិចប្រហែលបីបួនប្រាំម៉ាត់។

**ប្រធានអង្គជំនុំ៖**

ឥឡូវខ្ញុំដោះស្រាយបញ្ហានេះសិន។

ទីមួយ សំណើពីរ ពាក់ម្ហូកហើយនិងវ៉ែនតា អង្គជំនុំជម្រះអនុញ្ញាតដោយមានមូលហេតុសមស្របទប់ទល់ទៅនឹងបរិយាកាសនៃធាតុត្រជាក់នៃម៉ាស៊ីនត្រជាក់នៅទីនេះ ដែលគាត់មិនស៊ាំ ឬក៏មិនអាចនៅស្ថានភាពត្រជាក់បាន ហើយនិងបញ្ហាភ្នែក។

[០៩:២៧:៥៦]

បញ្ហាទីពីរ គឺលើបញ្ហាកៅអី នេះមានការចាប់អារម្មណ៍ ហើយអង្គជំនុំជម្រះទើបតែមានចំណាប់អារម្មណ៍អម្បាញ់មិញនេះទេ ទទួលព័ត៌មាននេះ ហើយជាសំណើសុំសមរម្យ អង្គជំនុំជម្រះនឹងពិភាក្សាជាមួយនឹងខាងរដ្ឋបាលដើម្បីពិចារណា ហើយចាត់ចែងកិច្ចការនេះជូន។ ខ្ញុំគិតថា បញ្ហានេះមិនមែនជាបញ្ហាអ្វីធំដុំទេ យើងនឹងអាចដោះស្រាយបាន។

ទីបី ដើម្បីឲ្យច្បាស់លាស់និងអស់ចិត្ត អង្គជំនុំជម្រះអនុញ្ញាតឲ្យលោក នួន ជា អាចចង់មានចំណាប់អារម្មណ៍អ្វី អាចនិយាយបាន។ សូមអញ្ជើញ!

**លោក នួន ជា៖**

ខ្ញុំនិយាយអានេះអ្អែ៎?

**ប្រធានអង្គជំនុំ៖**

អាចអង្គុយៗ ឲ្យអង្គុយនិយាយចុះ អនុញ្ញាតឲ្យអង្គុយនិយាយបានន៉ែ៎ ហើយបើកក្បាលមីក្រូផង។

[០៩:២៨:៥៩]

**លោក នួន ជា៖**

ជាបឋម ខ្ញុំបាទសូមគោរពលោកប្រធានតុលាការ ពិសេសលោកស្រី បងប្អូនរួមជាតិក្នុងទីនេះ បងប្អូនរួមជាតិទូទាំងប្រទេសនិងក្រៅប្រទេសដោយមេត្រី។ ខ្ញុំមិនសប្បាយចិត្តចំពោះសវនាការនេះ ហើយខ្ញុំប្រគល់ភារៈនេះជូនមេធាវីរបស់ខ្ញុំ ដើម្បីពន្យល់ពីហេតុផល។

សូមមេធាវីស្ងួត្រ។

**ប្រធានអង្គជំនុំ៖**

អម្បាញ់មិញនេះ យើងអនុញ្ញាតឲ្យជនជាប់ចោទគាត់និយាយខ្លីអ្វីដែលគាត់ចង់និយាយ ហើយ

មិនវែងទេ។ ចំណែកឯបញ្ហាតទៅទៀត អង្គជំនុំជម្រះមិនអនុញ្ញាតទេ ពីព្រោះវាក្រៅរបៀបវារៈដែលបានកំណត់។

ដូច្នេះ មេធាវីអាចអង្គុយចុះ។ អង្គជំនុំជម្រះនឹងបន្តកិច្ចនីតិវិធីទៅទៀត លោកអាចនិយាយបាននៅពេលក្រោយ ដំណាក់កាល គឺមិនទាន់អាចនិយាយបានទេ ពីព្រោះអំមិញគាត់ចង់និយាយពេក ឥឡូវយើងឲ្យនិយាយរួចហើយ។ អ៊ីចឹងមិនមានយកវេទិការនេះមកជជែកវែកញែកក្រៅពីអង្គហេតុ ដែលត្រូវជជែកពិភាក្សាទៅតាមដំណើរការនីតិវិធីទេ។ លើកលែងតែដំណាក់កាលចុងក្រោយនៃបញ្ហាដែលមានប្រសិនបើមានបំណង គឺតុលាការនឹងអនុញ្ញាត។

[០៩:៣១:០៩]

ជាកិច្ចបន្ត បញ្ជីនេះត្រូវបានប្រគល់ទៅឲ្យភាគីជាលក្ខណៈសម្ងាត់បំផុត។

**លោក ម៉ៃខល ផេសមិនៈ**

ខ្ញុំមានចំណុចមួយលោកចៅក្រម។ ខ្ញុំចង់លើកទាក់ទងទៅនឹងប្រធានបទ និងរបៀបវារៈនៃអង្គសនវាការនេះ។

**ប្រធានអង្គជំនុំៈ**

តើលោកត្រូវចំណាយពេលប៉ុន្មានទៅដើម្បីលើកឡើងបញ្ហានេះ?

អញ្ជើញ!

**លោក ម៉ៃខល ផេសមិនៈ**

សូមអរគុណលោកប្រធាន។ ដូចដែលកូនក្តីរបស់ខ្ញុំបានពន្យល់ហើយ ថាគាត់មិនសប្បាយចិត្តទេ ខ្ញុំសូមពន្យល់ថាហេតុអ្វីបានជាគាត់មិនសប្បាយចិត្ត។

នេះជាមិនមែនសវនាការបឋមទេ ប្រហែលថាវាជាសវនាការបឋមសម្រាប់លោក អៀង សារី ប៉ុន្តែមិនមែនជាសវនាការបឋមសម្រាប់លោក នួន ជា ទេ។ ដូចដែលលោកចៅក្រមបានដឹងហើយថា យើងបានលើកឡើងអញ្ញាត្រកម្មចំនួនបី ហើយសំខាន់បំផុតនោះគឺថា អញ្ញាត្រកម្មរបស់យើង គឺថាយើងមានការទាមទារឲ្យមានការបដិសេធនូវការស៊ើបអង្កេតរបស់ចៅក្រមស៊ើបអង្កេត ដែលយើងគិតថាដែលជាការស៊ើបអង្កេតមិនយុត្តិធម៌នឹងប៉ះពាល់យ៉ាងធ្ងន់ធ្ងរដល់សិទ្ធរបស់លោក នួន ជា ដែលយើងគិតថាដំណើរការនីតិវិធីនេះត្រូវតែបញ្ចប់។

[០៩:៣៣:២៤]

យើងក៏បានសុំឲ្យកោះហៅសាក្សីជាង ៣០០នាក់ ដែលយើងគិតថា ជាសាក្សីដែលគួរដែលត្រូវបានគេស្តាប់ចម្លើយជាសាធារណៈ។ ពោល គឺជាសាក្សីដែលបានដឹងអំពីបរិបទប្រវត្តិសាស្ត្រសម្រាប់តុលាការនេះ ក៏ដូចជាបរិបទជម្លោះ ដែលនិងសាក្សីសម្រាប់ធ្វើសក្ខីកម្មទៅលើបញ្ហាស៊ើបអង្កេត ដែលមិនយុត្តិធម៌។ យើងដឹងថា តើហេតុអ្វីបានជាយើងត្រូវចូលរួមនៅក្នុងសវនាការនៅពេលនេះទេ? ព្រោះអង្គជំនុំជម្រះសាលាដំបូងបានកំណត់នូវរបៀបវារៈសម្រាប់រយៈពេលសវនាការចំនួនបួនថ្ងៃ ដែលមិនមានអញ្ញាត្រកម្មណាមួយ ឬក៏សាក្សីណាមួយដែលលោក នួន ជា បានស្នើឡើងត្រូវបានលើកមកពិភាក្សានោះទេ។ ទោះបីជាវិធានតុលាការនេះបានចែងថា បញ្ហាទាំងអស់នេះនឹងត្រូវយកមកពិភាក្សានៅសវនាការបែបនេះក៏ដោយ។

កូនក្តីរបស់ខ្ញុំលោក នួន ជា បានជឿជាក់ថា គាត់មានសិទ្ធិដើម្បីនិយាយអំពីបញ្ហាអញ្ញាត្រកម្មទាំងអស់នេះ ហើយគាត់ក៏បានជឿថា គាត់មានសិទ្ធិដើម្បីពន្យល់ថា ហេតុអ្វីបានជាអញ្ញាត្រកម្មទាំងអស់នេះវាមានសារៈសំខាន់សម្រាប់គាត់ ដែលត្រូវយកមកពិភាក្សាជាសាធារណៈនៅមុនពេលដែលយើងចាប់ផ្តើមសវនាការលើអង្គសេចក្តីទាំងមូល។ ហើយយើងក៏ជឿជាក់ថា គាត់គួរតែត្រូវបានគេអនុញ្ញាតឲ្យពន្យល់ដល់ប្រជាជនកម្ពុជានូវហេតុអ្វីបានជាសាក្សីរបស់គាត់ក៏ត្រូវតែគេស្តាប់ចម្លើយនៅក្នុងសវនាការនេះ។ ហើយសំខាន់ជាងនេះទៅទៀត គឺលោក នួន ជា ជឿជាក់ថា ការពិភាក្សាទាំងអស់នេះត្រូវតែធ្វើឡើងជាសាធារណៈ ដើម្បីជាប្រយោជន៍ដល់ប្រជាពលរដ្ឋកម្ពុជា។

ហេតុអ្វីបានជាកូនក្តីរបស់យើងខ្ញុំលោក នួន ជា មិនត្រូវបានផ្តល់ឱកាសដើម្បីឲ្យពន្យល់? ហេតុអ្វីបានជាគាត់មិនត្រូវបានគេអនុញ្ញាតឲ្យពន្យល់អំពីហេតុផល ថាហេតុអ្វីបានជាការស៊ើបអង្កេតរបស់ចៅក្រមស៊ើបអង្កេតមិនយុត្តិធម៌? គោលបំណងចម្បងនិងសំខាន់បំផុតនៃការស៊ើបអង្កេត គឺការប្រមូលភស្តុតាងប្រឆាំងនឹងលោក នួន ជា តែប៉ុណ្ណោះ ហើយមិនគិតដល់ភស្តុតាងដែលជួយបង្ហាញអំពីតួនាទីស្អាតស្អំរបស់លោក នួន ជា នៅក្នុងអំឡុងរបបខ្មែរក្រហមនោះទេ។

[០៩:៣៥:៣២]

ហេតុអ្វីបានជាគាត់មិនអាចនិយាយអំពីបញ្ហាទាំងអស់នេះបាន? ហេតុអ្វីបានលោក នួន ជា មិនមានឱកាសក្នុងការនិយាយអំពីរឿងនេះ? ហេតុអ្វីបានជាយើងមិនបានអនុញ្ញាតឲ្យប្រាប់តុលាការនូវថ្ងៃនេះ ដើម្បីពន្យល់ទៅកាន់ប្រជាជនកម្ពុជាថា រដ្ឋាភិបាលចាប់តាំងពីដើមដំបូងមកបានរារាំងដល់ការស៊ើបអង្កេតនៅក្នុងសំណុំរឿងប្រឆាំងទៅនឹងលោក នួន ជា ដូចដែលគេកំពុងបានធ្វើនៅក្នុងករណី០០៣ និង

០០៤ ដែរ។ យើងខ្ញុំមានការអាណិតចំពោះព្រះរាជអាជ្ញា ហើយយើងខ្ញុំក៏យល់ច្បាស់អំពីការលំបាក និងការខកចិត្តរបស់ខាងព្រះរាជអាជ្ញានៅក្នុងសំណុំរឿង០០៣ និង ០០៤ ដែរ។

[០៩:៣៦:១១]

យើងខ្ញុំបានដាក់សំណើសុំៗឱ្យស៊ើបអង្កេតចំនួន ២៦សំណើ ប៉ុន្តែសហចៅក្រមស៊ើបអង្កេត គឺមិនបានធ្វើការស៊ើបអង្កេតទៅតាមសំណើរបស់ខ្ញុំនោះទេ។ ហេតុអ្វីបានជាការទម្លាក់គ្រាប់បែករបស់សហរដ្ឋអាមេរិកដ៏មហន្តរាយមកលើប្រទេសកម្ពុជា ហើយនឹងប៉ះពាល់ និងផលប៉ះពាល់នូវការទម្លាក់មកលើប្រជាជនកម្ពុជាមិនត្រូវបានគេស៊ើបអង្កេត? ហេតុអ្វីបានជាតួនាទីដែលគួរឱ្យសង្ស័យរបស់ប្រទេសវៀតណាមមកលើប្រទេសកម្ពុជានៅមុនពេល និងអំឡុងពេលក៏ដូចជាក្រោយពេលរបបខ្មែរក្រហមមិនត្រូវបានយកមកពិភាក្សា? ថាតើតុលាការមួយនេះកំពុងព្យាយាមជីកកប់ប្រវត្តិសាស្ត្រ ឬក៏យ៉ាងណា?

ហើយហេតុអ្វីបានជាសាក្សីដែលសំខានបំផុត ដែលយើងគិតថាសាក្សីដែលមិនអាចខ្វះបាន គឺជាសាក្សីដែលនៅខាងក្នុងនៃរបបនឹងមិនត្រូវបានគេយកមកស៊ើបអង្កេត ឬមិនត្រូវបានស្តាប់ចម្លើយ? ហេតុអ្វីបានជាអ្នកទាំងនោះមិនត្រូវបានគេស្តាប់ចម្លើយ? វាមិនមែនដោយសារតែយើងមិនបានស្នើសុំឱ្យយើងស្តាប់ចម្លើយអ្នកទាំងនោះៗទេ ហើយក៏មិនមែនដោយសារតែយើងគ្មានហេតុផលដើម្បីស្តាប់ចម្លើយសាក្សីទាំងអស់នេះក្នុងឋានៈជាសាក្សីខាងក្នុងនោះដែរ។ សាក្សីទាំងអស់នេះគឺជាសាក្សីខាងក្នុងសំខាន់បំផុត ប៉ុន្តែមិនត្រូវបានគេសម្តាប់ចម្លើយទេ ដោយសារតែរដ្ឋាភិបាលនៅក្នុងប្រទេសនេះ គឺគាត់ហាក់បីដូចជាមានអាកប្បកិរិយាបដិសេធនៅក្នុងការសហប្រតិបត្តិការ។ បានន័យថា រដ្ឋាភិបាលបានមិនរវល់ទៅនឹងដីការបស់តុលាការ។

[០៩:៣៧:៤៣]

វិធីនៃការស៊ើបអង្កេតបឋមវិវត្តបានបង្ហាញថា រដ្ឋាភិបាលនៅតែមិនយល់អំពីសារៈសំខាន់នៃឯករាជ្យភាពរបស់តុលាការ។ រដ្ឋាភិបាលមិនត្រូវប្រាប់ចៅក្រម ថាតើពួកគាត់គួរតែធ្វើអ្វីនោះទេ។ យើងមានភស្តុតាងរឹងមាំដែលបានបង្ហាញថា បញ្ហានេះពិតជាបានកើតឡើងនៅក្នុងករណីសំណុំរឿងរបស់លោក នួន ជា។ ហេតុដូច្នេះហើយបានជាកូនក្តីរបស់ខ្ញុំចង់ធ្វើការបង្ហាញអំពី ពន្យល់បង្ហាញអំពីដំណើរការនេះ។

[០៩:៣៨:២០]

ដូចដែលបានលើកឡើងការស៊ើបអង្កេត គឺមិនមានយុត្តិធម៌ ដូច្នេះហើយសំណុំរឿងរបស់លោក

នួន ជា មិនគួរត្រូវបានគេយកមកជំនុំជម្រះនោះទេ ហើយការកាត់សេចក្តី គឺដូចជាការសង់ផ្ទះដូច្នេះដែរ គឺយើងត្រូវការគ្រឹះយ៉ាងរឹងមាំ ហើយបើមិនមានគ្រឹះយ៉ាងរឹងមាំនោះទេ ផ្ទះនឹងដួលរលំ។ ដូចគ្នានោះដែរ នៅក្នុងតុលាការ បើសិនជាយើងមិនមានគ្រឹះរឹងមាំវានឹងដួលរលំនៅពេលនេះ ឬក៏នៅពេលខាងក្រោយ។

យ៉ាងហោចណាស់តុលាការនេះ គឺជាឱកាសជាប្រវត្តិសាស្ត្រមួយ ប៉ុន្តែមិនមែនជាលើកទីមួយទេដែលមេដឹកនាំខ្មែរក្រហមត្រូវបាននាំមកកាត់ទោស។ នៅក្នុងឆ្នាំ១៩៧៩ ប៉ុល ពត និង អៀង សារី ត្រូវបានគេកាត់ទោសពីបទប្រល័យពូជសាសន៍ ដោយតុលាការមួយដែលគ្រប់គ្រងនឹងរៀបចំទាំងស្រុងដោយរដ្ឋាភិបាលវៀតណាម។ ហើយតាំងពីឆ្នាំ១៩៧៩ មកមានការផ្លាស់ប្តូរតែបន្តិចបន្តួចប៉ុណ្ណោះទៅនឹងដំណើរការនេះ ប្រសិនបើតុលាការនេះមិនចង់គ្រាន់តែបង្ហាញតែជាតុលាការឲ្យតែល្អមើលនោះទេ ដូច្នេះ វាជាឱកាសដែលត្រូវបង្ហាញឲ្យឃើញអំពីសមត្ថភាពរបស់ខ្លួនឲ្យបានច្បាស់ហើយ។

លោក លោកស្រីចៅក្រមមិនគួរធ្វើឲ្យមានកំហុសដូចសហចៅក្រមស៊ើបអង្កេតបានធ្វើនោះទេ។ សេចក្តីសម្រេចដែលមិនគិតអំពីសំណើរបស់ នួន ជា នៅក្នុងសវនាការបឋម គឺជារឿងគួរឲ្យសោកស្តាយណាស់ ប៉ុន្តែយើងសង្ឃឹមថាវាមិនទាន់ហួសពេលនោះទេ។ មិនមែនតែលោក នួន ជា ម្នាក់ឯងនោះទេ ប៉ុន្តែប្រជាជនកម្ពុជាផងដែរ ដែលចង់បានតុលាការមួយដែលត្រឹមត្រូវ ដែលមានបំណងស្វែងរកការពិត នងមិនធ្វើអ្វីទៅតាមអ្នកដែលមានអំណាចប្រាប់ឲ្យធ្វើដែលមិនគិតគូរពីប្រវត្តិសាស្ត្រនោះទេ។ ហើយក៏គ្មាននរណាម្នាក់ដែលចង់បានតុលាការ ដែលយកគំរូតាមតុលាការរៀបចំដោយវៀតណាមនោះដែរ។

[០៩:៣៩:៥៦]

យើងចង់មានការពិភាក្សាជាមូលដ្ឋានមួយអំពីការស៊ើបអង្កេត ដែលមានមូលដ្ឋានគ្រឹះសម្រាប់តុលាការនៅពេលអនាគតត និងពិភាក្សាអំពីសាក្សីដែលត្រូវស្តាប់ចម្លើយនៅក្នុងពេលសវនាការ។ អស់រយៈពេលជាងបីឆ្នាំកន្លះហើយ សហចៅក្រមស៊ើបអង្កេតក៏បានស៊ើបអង្កេតដោយសម្ងាត់ គ្មាននរណាម្នាក់ដឹងថា ចៅក្រមស៊ើបអង្កេតធ្វើអ្វីនោះទេ លោក នួន ជា មិនបានដឹង សាធារណជនក៏មិនបានដឹងឥឡូវនេះដល់ពេលដែលយើងត្រូវបង្ហាញអំពីតម្លាភាពហើយ។

[០៩:៤០:២២]

កូនក្តីរបស់យើងខ្ញុំ នួន ជា មិនអាចសុំលាឈប់អំពីដំណើរការទាំងនេះដូចបុគ្គលិកអន្តរជាតិរបស់ការិយាល័យសហចៅក្រមស៊ើបអង្កេតនោះទេ។ ប៉ុន្តែ គាត់ក៏មិនអាចត្រូវបានគេបង្ខំឲ្យគាត់អង្គុយ

នៅក្នុងបន្ទប់សវនាការនេះរហូតនោះទេ គាត់នឹងចាកចេញពីបន្ទប់នេះ ហើយគាត់នឹងត្រឡប់មកវិញ ចូលរួមទៅក្នុងសវនាការជាមួយនឹងអង្គជំនុំជម្រះសាលាដំបូងនេះ នៅពេលដែលអង្គជំនុំជម្រះសាលាដំបូងមានបំណងពិភាក្សាអំពីអញ្ញត្រកម្ម និងសាក្សីដែលគាត់បានលើកឡើង។ ហើយប្រសិនបើមានសវនាការបែបនោះមែន នៅសប្តាហ៍នេះ ហើយនៅពេលខាងមុខលោក នួន ជា នឹងចូលរួម។ លោក នួន ជា មិនចង់ចូលរួមនៅក្នុងដំណើរការ-- គាត់នឹងចូលរួមនៅក្នុងសវនាការនេះនៅពេលដែលសាក្សីរបស់គាត់ និងបញ្ហាអញ្ញាត្រកម្មរបស់ត្រូវបានលើកឡើង។

ដូច្នេះ ខ្ញុំសូមអរគុណចំពោះលោកចៅក្រមដែលបានអនុញ្ញាតផ្តល់ឱកាសនេះ។ សូមអរគុណ។

[០៩:៤១:១៨]

**ប្រធានអង្គជំនុំ៖**

យើងឈប់អនុញ្ញាតទៀតហើយ បានប្រាសចាកនូវរបៀបវារៈដែលបានកំណត់។

យើងបន្តកិច្ចនីតិវិធីនៃដំណើរការរបស់យើងតាមរបៀបវារៈដែលបានគ្រោងទុក។

បញ្ជីត្រូវបានប្រគល់ទៅឲ្យភាគីជាលក្ខណៈសម្ងាត់ ហើយក៏បានបង្ហាញពីរហស្សនាមសម្រាប់សាក្សី អ្នកជំនាញ និងដើមបណ្តឹងរដ្ឋប្បវេណីទាំងនោះផងដែរ។ ក្នុងករណីដែលឈ្មោះរបស់សាក្សីអ្នកជំនាញ ឬដើមបណ្តឹងរដ្ឋប្បវេណីណាមួយត្រូវបានលើកឡើងត្រូវបានលើកឡើងនៅក្នុងសវនាការនេះ ភាគីត្រូវប្រើរហស្សនាមរហូតដោយរង់ចាំនូវសម្រេចចុងក្រោយ ថាតើសាក្សី អ្នកជំនាញ និងដើមបណ្តឹងរដ្ឋប្បវេណីទាំងនោះត្រូវកោះហៅ ឬមិនកោះហៅ ឬចាំបាច់ត្រូវផ្តល់នូវវិធានការការពារដែរ ឬយ៉ាងណា?

ភាគីនឹងទទួលបាននូវពេលវេលាសម្រាប់ធ្វើការផ្តល់យោបល់ទាក់ទងនឹងបញ្ជីឈ្មោះសាក្សី ដើមបណ្តឹងរដ្ឋប្បវេណី និងអ្នកជំនាញបណ្តោះអាសន្ននេះ។

អញ្ជើញ! មានបញ្ហាអីទៀតហើយ?

[០៩:៤២:៥៦]

**លោក នួន ជា៖**

លោកប្រធាន លោកស្រី, ខ្ញុំសូមចាកចេញក្នុងពេលនេះ ហើយនឹងត្រៀមខ្លួនជាស្រេចត្រឡប់មកវិញ ប្រសិនបើតុលាការនឹងលើកយកសំណើរបស់ខ្ញុំមកជជែកដេញដោលជាសាធារណៈ។

[០៩:៤៣:១៨]

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះអនុញ្ញាត។ អនុរក្សមន្ទីឃុំឃាំងនាំគាត់ចាកចេញពីបន្ទប់សវនាការទៅកាន់មន្ទីរឃុំឃាំងវិញចុះ។

ភាគីនឹងទទួលបាននូវពេលវេលាសម្រាប់ធ្វើការផ្តល់យោបល់ទាក់ទងទៅនឹងបញ្ជីឈ្មោះសាក្សី ដើមបណ្តឹងរដ្ឋប្បវេណី និងអ្នកជំនាញបណ្តោះអាសន្ននេះ។ ប្រសិនបើភាគីឯកភាពប្រើតែរហស្សនាមនូវពេលពិភាក្សាអំពីបញ្ជីឈ្មោះសាក្សី អ្នកជំនាញ និងដើមបណ្តឹងរដ្ឋប្បវេណីនោះអង្គជំនុំជំម្រះយល់ថាផ្នែកទាំងអស់នៃកិច្ចសវនាការបឋម រួមទាំងផ្នែកពាក់ព័ន្ធនឹងសាក្សីដើមបណ្តឹងរដ្ឋប្បវេណី និងអ្នកជំនាញ អាចបន្តធ្វើជាសាធារណៈបាន។

តើភាគីណាជំទាស់ទៅនឹងសំណើនេះដែរឬទេ? ឬស្នើសុំឲ្យអង្គជំនុំជម្រះធ្វើសវនាការអសាធារណៈនៅក្នុងអំឡុងពេលសវនាការបឋមនៅថ្ងៃចុងក្រោយ នៅពេលដែលពិភាក្សាអំពីបញ្ជីឈ្មោះសាក្សី ដើម-បណ្តឹងរដ្ឋប្បវេណី និងអ្នកជំនាញបណ្តោះអាសន្ននោះ។ ប្រសិនបើមានសូមអញ្ជើញ។

អញ្ជើញមេធាវី!

[០៩:៤៤:៤៩]

**លោកស្រី អេលីហ្សាបេត ស៊ីម៉ុនណូហ្វត៖**

លោកប្រធាន, អង្គជំនុំជម្រះបានដឹងថាក្នុងឋានៈជាមេធាវីរដ្ឋប្បវេណី យើងមិនបានដាក់បញ្ជីដើមបណ្តឹងរដ្ឋប្បវេណីនោះទេ ហើយយើងមានឱកាសក្នុងការពន្យល់ទៅលើបញ្ហានេះ ប៉ុន្តែយើងគិតថាថ្ងៃនេះ គឺយើងអាចផ្តល់នូវការពន្យល់យ៉ាងលឿនបំផុតទៅលើមូលហេតុដែលថា ហេតុអ្វីបានយើងនៅក្នុងដំណាក់កាលនេះ មិនដាក់បញ្ជីដើមបណ្តឹងរដ្ឋប្បវេណី។ តើលោកប្រធានអនុញ្ញាតឲ្យយើងពន្យល់បន្តិចបានទេ អំពីបញ្ហានេះ?

**ប្រធានអង្គជំនុំ៖**

មិនអនុញ្ញាតទេ ពាក់ព័ន្ធនឹងបញ្ហាអំមិញ គឺយើងប្រាប់អំពីបញ្ហានីតិវិធីនៃការដំណើរការប្រព្រឹត្តទៅជាអសាធារណៈលើការជជែក ហើយបើធ្វើជាសាធារណៈអាចធ្វើទៅបានលុះត្រាតែភាគីព្រមព្រៀង និងយល់ស្របគ្នាទាំងអស់ថា ត្រូវប្រើរហស្សនាមដែលអង្គជំនុំជម្រះបានកំណត់សម្រាប់សាក្សី អ្នកជំនាញ និងដើមបណ្តឹងរដ្ឋប្បវេណីដែលមាននៅក្នុងបញ្ជីរួចហើយ។ បើពុំដូច្នេះទេ គឺអង្គជំនុំជម្រះ ប្រសិនបើស្តាប់នូវមតិយោបល់របស់ភាគីទៅមានលក្ខណៈសមស្រប គឺអង្គជំនុំជម្រះអាចផ្លាស់ប្តូរពីសវនាការជា

សាធារណៈដែលពិនិត្យ ឬក៏រំពឹងទុកថាមិនអាចនឹងរក្សាការសម្ងាត់បាន ចំពោះបញ្ហានេះបានទៅជាសវនាការអសារណៈដើម្បីជជែកពិភាក្សាលើបញ្ហានោះប៉ុណ្ណោះ។

[០៩:00:00]

**លោកស្រី អេលីហ្សាបេត ស៊ីម៉ុនណូហ្វត៖**

លោកប្រធាន ខ្ញុំគិតថាយើងមានលទ្ធភាពក្នុងការជ្រើសរើសសវនាការអសាធារណៈ ប៉ុន្តែខ្ញុំចង់អ្វីដែលខ្ញុំចង់និយាយនេះ គឺថាវាពាក់ព័ន្ធទៅនឹងសាលដីការបស់អង្គបុរេជំនុំជម្រះកាលពីថ្ងៃព្រហស្បតិ៍ ហើយយើងមាន២.000ដើមបណ្តឹងរដ្ឋប្បវេណីជាង ដែលយើងត្រូវការពារ។ ដូច្នេះហើយរហូតមកដល់ពេលនេះ យើងមិនទាន់បានបង្កើតបញ្ជីនៅឡើយទេ។ ដូច្នេះ ខ្ញុំគ្រាន់តែចង់ពន្យល់បន្តិចបន្តួច ពីព្រោះថាយើងចង់បានការពន្យល់បន្ថែមទៅលើវិធីសាស្ត្រដែលយើងនឹងត្រូវជ្រើសរើស ដើម្បីជ្រើសរើសឲ្យបានច្បាស់នូវដើមបណ្តឹងរដ្ឋប្បវេណីដែលនឹងត្រូវមកនិយាយនៅក្នុងសវនាការ។

ដូច្នេះ ច្បាស់ណាស់ថា ដំណើរការជំនុំជម្រះក្តីមិនអាចធ្វើឡើងបានទេ នៅពេលដែលដើមបណ្តឹងរដ្ឋប្បវេណីមិនបានជ្រើសរើសមេធាវីរបស់ខ្លួន ដោយមានការពិគ្រោះយោបល់ជាមួយមេធាវីរបស់ខ្លួនដើម្បីមកនិយាយអំពីអង្គហេតុនៅទីនេះ។ យើងមិនទាន់បានបំពេញបញ្ជីនេះនៅឡើយទេមកដល់ពេលនេះ ដូច្នេះយើងចង់ទទួលបានការបញ្ជាក់ច្បាស់លាស់ ដោយមូលហេតុបញ្ហាច្បាប់ បញ្ហាអង្គហេតុ។ ដូច្នេះ ខ្ញុំគ្រាន់តែចង់បានតែប៉ុន្មាននាទីតែប៉ុណ្ណោះក្នុងការពន្យល់អំពីបញ្ហានេះ ហើយនឹងស្នើសុំអង្គជំនុំជម្រះក្នុងការពន្យល់បំភ្លឺបន្ថែមទៅលើវិធីសាស្ត្រដែលយើងត្រូវធ្វើបញ្ជីនេះ។

[០៩:៤៧:៤៥]

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញមានភាគីណាផ្សេងទៀតមានបញ្ហាជំទាស់លើកសំណើដែលបានលើកឡើងអម្បាញ់មិញដែរឬទេ?

**លោក ម៉ៃខល កាណាវាស៖**

អរុណសួស្តីលោកចៅក្រម អរុណសួស្តីអ្នកទាំងអស់គ្នាដែលនៅក្នុងជុំវិញអង្គសវនាការនេះ។ ខ្ញុំសូមដាក់ជូនថា ឲ្យយើងមានពិភាក្សាជាសាធារណៈ ថាតើអ្នកណាៗដែលអាចបង្ហាញខ្លួននៅមុខអង្គសវនាការនេះជាសាធារណៈ? ហើយទាក់ទងទៅនឹងបញ្ហាបុគ្គលនីមួយៗដែលអាចត្រូវធ្វើសវនាការជាសម្ងាត់ហ្នឹង ហើយតាមការពិភាក្សានេះយើងពិនិត្យមើលថា តើយើងពិនិត្យមើលអំពីដំណើរការជា

សម្ងាត់ហ្នឹងយ៉ាងដូចម្តេច? ដូច្នេះ យើងចាំបាច់ត្រូវតែធ្វើការបង្ហាញអំពីជាសាធារណៈដោយមិនចាំបាច់បង្ហាញអំពីឈ្មោះទេ នេះគឺជាដំណើរការដែលមានតម្លាភាពដោយថា ហេតុអ្វីបានជាសាក្សីមួយចំនួនមិនត្រូវបានគេយកមកស្តាប់ចម្លើយនៅក្នុងសាធារណៈ ហើយសាក្សីដូចនេះ យើងគួរតែរៀបចំនៅក្នុងជាលក្ខណៈអសាធារណៈ។ សូមអរគុណ។

[០៩:៤៩:១៤]

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះកត់សម្គាល់នូវគំនិត មតិយោបល់របស់លោកមេធាវីដែលបានលើកឡើង ហើយបើមិនមានមតិយោបល់អីផ្សេងទៀតទេ គឺអង្គជំនុំជម្រះនឹងលើកបញ្ហានេះទៅពិចារណាសម្រេចដើម្បីដំណើរការនៅក្នុងអំឡុងពេលនៃកិច្ចជជែកពិភាក្សាអំពីបញ្ជីឈ្មោះសាក្សីដើមបណ្តឹងរដ្ឋប្បវេណី និងអ្នកជំនាញនេះ។

អញ្ជើញ!

[០៩:៤៩:៤០]

**លោក ស សូវាន៖**

សូមគោរពអង្គជំនុំជម្រះ សូមគោរពលោកប្រធាន, ខ្ញុំបាទមេធាវីលោកអតីតលោកប្រមុខរដ្ឋ ខៀវ សំផន ខ្ញុំបាទសូមស្នើថាថ្ងៃព្រហស្បតិ៍នេះ ខ្ញុំបានស្តាប់លោកប្រធានបានមានប្រសាសន៍អំមិញហ្នឹងថា យើងជជែកគ្នាអំពីរឿងបញ្ជីឈ្មោះជាសាធារណៈ ប៉ុន្តែខ្ញុំសូមអ៊ីចេះថា នៅក្នុងថ្ងៃព្រហស្បតិ៍នេះ យើងអាចៗជជែកគ្នាជាសាធារណៈ ឬមួយខ្ញុំសូមឲ្យមានជជែកគ្នាការសម្ងាត់ ពីព្រោះបញ្ជីសាក្សីរបស់ខ្ញុំវាគ្មានលេខកូដនៅក្នុងបញ្ជីរបស់សម្ងាត់អំមិញនេះទេ។ ដូច្នេះ ខ្ញុំសូមថាថ្ងៃព្រហស្បតិ៍នេះខ្ញុំមានលទ្ធភាពជជែកជាសម្ងាត់ពីរឿងបញ្ជីសាក្សីរបស់ខ្ញុំ។ សូមអរគុណលោកប្រធាន។

**ប្រធានអង្គជំនុំ៖**

អរគុណ មេធាវី។

**លោកស្រី អេលីហ្សាបេត ស៊ីម៉ុនណូហ្វត៖**

លោកប្រធាន, ខ្ញុំគិតថាយើងមិនអាចធ្វើការពន្យល់នៅថ្ងៃនេះបានទេ ហើយយើងនឹងផ្តល់នៅថ្ងៃព្រហស្បតិ៍ ហើយពិតណាស់យើងនឹងបង្កើតបញ្ជីដើមបណ្តឹងរដ្ឋប្បវេណី ហើយយើងគិតថា ដោយអនុវត្តវិធាន៩០ ស្ទួន នៃវិធានផ្ទៃក្នុង គឺថាយើងតែមួយគត់ដែលជាអ្នកដែលមានសិទ្ធិនៅក្នុងការធ្វើការ

កាត់បន្ថយនូវការបញ្ជីនេះ។ ដូចនេះ យើងនឹងស្នើឡើងនូវបញ្ជីដែលមានការកាត់បន្ថយទៅលើប្រធានបទទាំងបួននៃការជំនុំជម្រះក្តី។ ហើយយើងសោកស្តាយណាស់ដែលយើងមិនបានពន្យល់បញ្ហានេះនៅថ្ងៃនេះ អ៊ីចឹង យើងនឹងពន្យល់បញ្ហានៅថ្ងៃព្រហស្បតិ៍។

**ប្រធានអង្គជំនុំ៖**

អរគុណច្រើន ហើយនូវមតិយោបល់របស់អស់លោក លោកស្រីមេធាវីដែលបានលើកឡើងជុំវិញបញ្ហាថា តើធ្វើនីតិវិធីពិភាក្សាសម្រេចជុំវិញបញ្ហាការជ្រើសរើសសាក្សី អ្នកជំនាញដើមបណ្តឹងរដ្ឋប្បវេណីដែលត្រូវកោះហៅមកធ្វើសក្ខីកម្មសម្រាប់អង្គហេតុបួនដំបូងនៃដំណើរការសវនាការអង្គសេចក្តីនោះ ថាតើត្រូវធ្វើជាសាធារណៈ ឬក៏អសាធារណៈ។

អម្បាញ់មិញនេះ គឺអស់លោកលោកស្រីបានមានមតិយោបល់ហើយ គឺទោះបីយ៉ាងណាយើងកត់សម្គាល់ឃើញថា មានមតិយោបល់មិនដូចគ្នាទេ គឺមានមតិយោបល់ខុសគ្នាលើបញ្ហានេះ។ ដូច្នេះ គឺអង្គជំនុំជម្រះកត់សម្គាល់លើនូវមតិយោបល់របស់អស់លោក លោកស្រីមេធាវី ដែលបានលើកឡើង ហើយនឹងអង្គជំនុំជម្រះនឹងធ្វើការសម្រេចបញ្ហានេះនៅថ្ងៃព្រហស្បតិ៍ ឬក៏ថ្ងៃចុងក្រោយនៃដំណើរការសវនាការដល់ដំណាក់កាលជជែកពិភាក្សាលើបញ្ហានេះ។

[០៩:៥៣:៥០]

ជាបន្ត នៅក្នុងបញ្ជីឈ្មោះសាក្សីដើមបណ្តឹងរដ្ឋប្បវេណី និងអ្នកជំនាញបណ្តោះអាសន្ន អង្គជំនុំជម្រះបានចង្អុលបង្ហាញអំពីសាក្សីដើមបណ្តឹងរដ្ឋប្បវេណី និងអ្នកជំនាញដែលអង្គជំនុំជម្រះយល់ថាមានភាពពាក់ព័ន្ធបំផុត និងអាចបញ្ជាក់អំពីអង្គហេតុដែលត្រូវធ្វើការជំនុំជម្រះអង្គសេចក្តីនៅដំណាក់កាលដំបូង។ ក្នុងអំឡុងពេលសវនាការអង្គជំនុំជម្រះនឹងពិចារណាផងដែរអំពីការកោះហៅសាក្សីផ្សេងទៀត ប្រសិនបើខ្លួនគិតថាមានភាពចាំបាច់អនុលោមតាមវិធាន៨៧ អនុវិធាន៤ នៃវិធានផ្ទៃក្នុងអ.វ.ត.ក ។ អង្គជំនុំជម្រះក៏នឹងពិចារណាផងដែរ នូវដើមបណ្តឹងរដ្ឋប្បវេណីដែលត្រូវបានទទួលយកដោយអង្គបុរេជំនុំជម្រះនាពេលថ្មីៗនេះ។ ដើមបណ្តឹងរដ្ឋប្បវេណីថ្មីៗទាំងនោះ គឺជាផ្នែកមួយនៃក្រុមដើមបណ្តឹងរដ្ឋប្បវេណីរួម។ ដើមបណ្តឹងរដ្ឋប្បវេណីខ្លះនឹងត្រូវពិចារណាដាក់នៅក្នុងបញ្ជីដើម្បីស្តាប់សក្ខីកម្មទាក់ទងនឹងបទឧក្រិដ្ឋដែលបានចោទប្រកាន់នៅដំណាក់កាលក្រោយ។

ប៉ុន្តែ ដោយការពិចារណាទៅលើកាតព្វកិច្ចរបស់អង្គជំនុំជម្រះ ក្នុងការធានាឲ្យមានការជំនុំជម្រះប្រកបដោយភាពឆាប់រហ័សនិងយុត្តិធម៌នោះ អង្គជំនុំជម្រះនឹងមិនកោះហៅសាក្សីដែលសក្ខីកម្មរបស់

ពួកគាត់ទំនងជាមានភាពច្រំដែលជាមួយនឹងភស្តុតាងផ្សេងៗទៀត ដែលមាននៅចំពោះមុខអង្គជំនុំជម្រះ ទោះបីជាសាក្សីទាំងនោះមានភាពពាក់ព័ន្ធក្តី ដោយហេតុថា សាក្សី អ្នកជំនាញ ដើមបណ្តឹងរដ្ឋប្បវេណី ដែលភាគីបានដាក់ស្នើសុំចំពោះមុខអង្គជំនុំជម្រះមានចំនួន១.០៥៤នាក់ អង្គជំនុំជម្រះធ្លាប់បានបញ្ជាក់ថា ខ្លួនមានបំណងស្តាប់សក្ខីកម្មក្នុងចំនួនមួយតិចជាងចំនួននេះ។

បន្ទាប់ពីមានការទាញហេតុផលដោយផ្ទាល់មាត់ ស្តីពីបញ្ហាបញ្ជីឈ្មោះបណ្តោះអាសន្ន អង្គជំនុំជម្រះរំពឹងថានឹងផ្តល់បញ្ជីឈ្មោះសាក្សីដើមបណ្តឹងរដ្ឋប្បវេណី និងអ្នកជំនាញជាក់លាក់សម្រាប់អង្គ-ហេតុដែលត្រូវធ្វើការជំនុំជម្រះដំបូងនោះ។ បន្ទាប់ពីសវនាការបឋមនេះ ព័ត៌មានផ្សេងទៀតដែលទាក់-ទងនឹងសាក្សីដើមបណ្តឹងរដ្ឋប្បវេណី និងអ្នកជំនាញដែលត្រូវបានស្នើឡើងដោយភាគីនានា ហើយដែលអង្គជំនុំជម្រះយល់ថា ទាក់ទងនឹងអង្គហេតុដែលត្រូវជំនុំជម្រះនៅក្នុងដំណាក់កាលក្រោយៗនិងជម្រាបជូនភាគី នៅពេលក្រោយ។ អង្គជំនុំជម្រះបានទទួលសំណើមួយចំនួនពីភាគី ដែលបានស្នើសុំឲ្យមានការបញ្ជាក់អំពីការជួបទាក់ទងគ្នារវាងភាគី និងសាក្សីដើមបណ្តឹងរដ្ឋប្បវេណី និងអ្នកជំនាញនៅមុនពេលពួកគាត់ស្តាប់សក្ខីកម្មនៅសវនាការ។

[០៩:៥៥:៣៧]

ដោយលក្ខណៈវិសេសនៃប្រព័ន្ធច្បាប់ស៊ីវិលឡដែលគ្រប់គ្រងកិច្ចដំណើរការនីតិវិធីនៅចំពោះមុខ អ.វ.ត.ក គឺថាសាក្សី អ្នកជំនាញ ភាគច្រើនដែលពាក់ព័ន្ធនឹងសវនាការនេះ គឺត្រូវបានសហចៅក្រមស៊ើបអង្កេតស្តាប់ចម្លើយរួចហើយ។ ដូច្នេះ សាក្សីទាំងអស់នេះគឺជាសាក្សីដែលធ្លាប់ជាកម្មវត្ថុនៃកិច្ចដំណើរការនីតិវិធីរបស់តុលាការ ហើយប្រសិនបើពួកគាត់ត្រូវបង្ហាញខ្លួនចំពោះមុខអង្គជំនុំជម្រះ សាក្សីទាំងនោះនឹងត្រូវចាត់ទុកថាជាសាក្សីរបស់តុលាការ។

នៅក្នុងករណីមួយចំនួន និងក្នុងករណីដែលអង្គជំនុំជម្រះមានភាពមន្ទិលពាក់ព័ន្ធនឹងភាពស៊ីសង្វាក់នៅចម្លើយទាំងនេះ ឬថាតើសាក្សី ឬអ្នកជំនាញអាចរំឭកចំណុចសំខាន់ៗនៃចម្លើយរបស់ខ្លួនកន្លងមក អង្គជំនុំជម្រះអាចចាត់វិធានការនានាដើម្បីបញ្ជាក់ចំណុចមន្ទិលនេះឲ្យបានច្បាស់។ គ្រប់ករណីទាំងអស់ភាគីនឹងបានទទួលការជូនដំណឹងអំពីគំនិតផ្តួចផ្តើមរបស់អង្គជំនុំជម្រះលើបញ្ហានេះ។ ប្រសិនបើអង្គជំនុំជម្រះទទួលយកសំណើសុំស្តាប់សក្ខីកម្មរបស់សាក្សីថ្មី ឬអ្នកជំនាញថ្មីអង្គជំនុំជម្រះនឹងពិនិត្យមើលថា តើសក្ខីកម្មរបស់សាក្សី ឬអ្នកជំនាញថ្មីទាំងនោះធ្វើទៅអនុលោមតាមវិធាន៨៧(៤) នៃវិធានផ្ទៃក្នុងដែរឬយ៉ាងណា?

[០៩:៥៧:១៤]

ក្នុងករណីមួយចំនួនអង្គជំនុំជម្រះក៏អាចធ្វើទំនាក់ទំនងជាមួយនឹងសាក្សី ឬអ្នកជំនាញដោយផ្ទាល់ ដើម្បីធានាថា តុលាការនឹងមិនបាត់បង់នូវពេលវេលាដ៏មានតម្លៃរបស់ខ្លួនក្នុងការកោះហៅសាក្សី ឬអ្នកជំនាញដែលសក្ខីកម្មរបស់ពួកគាត់អាចនឹងស្របតាមខ្លឹមសារនៃវិធាន៨៧ អនុវិធាន៤ នៃវិធានផ្ទៃក្នុង។

កន្លងមក អង្គជំនុំជម្រះធ្លាប់បានប្រកាសថា នៅពេលសមស្រប អង្គជំនុំជម្រះនឹងស្នើសុំឲ្យភាគីបញ្ជាក់អំពីឯកសារនានា ដែលខ្លួនយល់ថាពាក់ព័ន្ធនឹងអង្គហេតុដែលត្រូវធ្វើការជំនុំជម្រះដំបូងនេះ។ អង្គជំនុំជម្រះស្នើសុំឲ្យភាគីធ្វើការបញ្ជាក់ថាតើឯកសារ និងវត្ថុតាងណាខ្លះដែលមាននៅក្នុងបញ្ជីនិងឯកសារវត្ថុតាងដែលបានដាក់ពីពេលមុននោះ? ដែលភាគីយល់ថា មានភាពពាក់ព័ន្ធនឹងអង្គហេតុដែលត្រូវធ្វើការជំនុំជម្រះនៅដំណាក់កាលដំបូងនេះឲ្យបានត្រឹមថ្ងៃសុក្រ ទី២២ ខែកក្កដា ឆ្នាំ២០១១។ ការបញ្ជាក់ឲ្យដឹងជាមុននេះ គឺអនុញ្ញាតឲ្យអង្គភាពបកប្រែភាសាអាចបញ្ជាក់ពីភាពនៃការបកប្រែឯកសារសំខាន់ៗ ក៏ដូចជាអនុញ្ញាតឲ្យអង្គជំនុំជម្រះអាចកំណត់នូវបញ្ហាមួយចំនួនដែលមិនទាន់បានដោះស្រាយនៅក្នុងពេលឆាប់ៗតាមដែលអាចធ្វើទៅបាន។

[០៩:៥៨:៤៤]

អង្គជំនុំជម្រះក៏បានជូនដំណឹងដល់ភាគីផងដែរថា បន្ទាប់ពីការបរិច្ឆេទនេះអង្គជំនុំជម្រះនឹងកំណត់កាលបរិច្ឆេទសម្រាប់ការដាក់ឯកសារជាលាយលក្ខណ៍អក្សរជំទាស់ទៅនឹងឯកសារដែលពាក់ព័ន្ធទៅនឹងផ្នែកដំបូងនៃសវនាការនៃអង្គសេចក្តី។

ឥឡូវនេះ ភាគីនៅមានឱកាសដើម្បីលើកឡើងនៅចំណុចណាមួយដែលខ្លួនចង់បញ្ជាក់ពាក់ព័ន្ធនឹងបញ្ជីឈ្មោះសាក្សី ដើមបណ្តឹងរដ្ឋប្បវេណី និងអ្នកជំនាញបណ្តោះអាសន្ន និងដំណើរការនីតិវិធីដែលត្រូវបានអនុវត្តពាក់ព័ន្ធនឹងបញ្ហានេះ។

ប្រសិនបើភាគីចង់មានមតិយោបល់លើបញ្ហានេះ សូមអញ្ជើញ ដោយអញ្ជើញពីខាងសហព្រះរាជអាជ្ញា និង/ឬ មេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីមុន។ សូមអញ្ជើញ!

ក្រុមមេធាវីការពារ-- សូមអញ្ជើញៗ លោកជំទាវ!

**លោកស្រី ជា លាង៖**

សូមគោរពអង្គសវនាការទាំងមូល។ អ្វីដែលខាងប្រធានអង្គជំនុំជម្រះសាលាដំបូងបានលើក

ឡើងពាក់ព័ន្ធទៅនឹងសាក្សីនៅពេលនេះ។ ជាទូទៅ សហព្រះរាជអាជ្ញាឯកភាពនឹងគោលដៅដែលខាងអង្គជំនុំជម្រះសាលាដំបូងមានបំណងចង់ធ្វើ ប៉ុន្តែខ្ញុំគ្រាន់តែមានបញ្ហាតិចតួចពាក់ព័ន្ធមិនទាន់មានភាពច្បាស់លាស់ទៅលើបញ្ជីសាក្សី ដែលបានប្រគល់ឲ្យមកភាគីទាំងអស់ ក្នុងនោះរួមមាន ព្រះរាជអាជ្ញា និងមេធាវីការពារក្តីទាំងអស់ដែរ។ ខ្ញុំពិនិត្យមើលនៅក្នុង*លីស*ឈ្មោះទាំងអស់នេះ យើងគិតថា ជាទូទៅ យើងគិតថាជាបញ្ជីសាក្សីដែលសម្ងាត់ ហើយក្នុងការលើកឡើងអំពីមធ្យោបាយនៃការធ្វើ ខ្ញុំគិតថាខ្ញុំឯកភាព ដោយសារស្នើសុំជាសាធារណៈចុះ ដោយសារយើងគិតថាសវនាការរបស់យើងនេះ យើងគិតថា វាមានតម្លៃណាស់សម្រាប់សាធារណជន ក៏ដូចជាជនរងគ្រោះទាំងអស់។ គ្រាន់តែយើងនៅពេលចុងក្រោយ គឺថ្ងៃចុងក្រោយតែម្តង គឺហើយនិងមានការដាក់ជាការសម្គាល់ឈ្មោះទៅលើសាក្សី និងមិនបញ្ចេញឈ្មោះទេ ប៉ុន្តែដោយដាក់ជាសម្គាល់ដូចជាអក្សរអីមួយ ដើម្បីយើងពិភាក្សាគ្នា។

[១០:០១:៣០]

ហើយថ្ងៃចុងក្រោយ គឺថ្ងៃដែលយើង ខ្ញុំមើលនៅក្នុងរបៀបវារៈដែលខាង ធី.ស៊ី ប្រគល់ឲ្យនោះ យើងនឹងពិភាក្សាអំពីបញ្ជីទាំងអស់ដែលបានប្រគល់នេះ ថាតើចំពោះសាក្សីមួយណា ដែលយើងលើកយកមកពិភាក្សា ហើយនិងសុំមានជាលេខសម្គាល់សម្ងាត់ណាមួយ ដើម្បីកុំឲ្យមានការចេញឈ្មោះទៅលើសាក្សីហ្នឹង ជាសាធារណៈ អានេះជាគ្រាន់តែជាសំណូមពរតែប៉ុណ្ណឹង។ សូមអរគុណ។

[១០:០១:៥៩]

**ប្រធានអង្គជំនុំ៖**

បាទ, សូមអរគុណលោកជំទាវ ដែលបានធ្វើការកត់សម្គាល់បញ្ហានេះ។

សូមអញ្ជើញលោកសហមេធាវី-- សហព្រះរាជអាជ្ញាអន្តរជាតិ!

**លោក អាន់ឌ្រូ ខេលី៖**

សូមអរគុណលោកប្រធាន។ ខ្ញុំក៏មានយោបល់រួមដូចសហសេវិករបស់ខ្ញុំផងដែរ ប៉ុន្តែខ្ញុំចង់លើកចំណុចបន្ថែមមួយទៀត។ ចំណុចនោះគឺថា លោកប្រធានបានចាំហើយ យើងនៅពេលថ្មីៗនេះ បានដាក់ជូនជំនុំជម្រះបង្ហាញអំពីជំហររបស់យើង ជាពិសេសពាក់ព័ន្ធទៅនឹងសក្ខីកម្មរបស់ជនជាប់ចោទចំនួនបួន ប្រសិនបើពួកគេចង់លើកឡើង។ ដូច្នេះហើយ យើងខ្ញុំស្នើ ចង់ស្នើដាក់នូវបញ្ជីបណ្តោះអាសន្នទាំងអស់នេះ ដោយបង្ហាញអំពីជំហររបស់យើង ក្នុងករណីដែលជនជាប់ចោទនោះ គាត់ចង់ផ្តល់សក្ខីកម្ម។ យើងជឿជាក់ថា ប្រហែលជាជនជាប់ចោទទាំងបួននាក់នោះ អាចនឹងផ្តល់សក្ខីកម្មនៅក្នុងពេលធ្វើ

សវនាការលើអង្គសេចក្តី។ សូមអរគុណ។

[១០:០៣:០៩]

**ប្រធានអង្គជំនុំ៖**

សូមអរគុណសហព្រះរាជអាជ្ញាអន្តរជាតិ។

សូមអញ្ជើញលោក ពេជ អង្គ!

**លោក ពេជ អង្គ៖**

សូមទោស។ ទាក់ទងទៅនឹងការពិភាក្សាអំពីបញ្ជីឈ្មោះ ដើមបណ្តឹងរដ្ឋប្បវេណី សាក្សី ហើយ និងអ្នកជំនាញនេះ។ មេធាវីអ្នកនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីពុំមានអ្វីជំទាស់ នៅក្នុងការជជែកពិភាក្សាជាសាធារណៈឡើយ ដោយសារថាកូនក្តីមួយចំនួនដែលត្រូវបាន ឬក៏អ្នកជំនាញសាក្សីមួយចំនួនដែលត្រូវបានស្នើជា ដាក់ជាសម្ងាត់នោះ ត្រូវបានពិភាក្សាដោយមានរហស្សនាម។ ដូច្នេះ វានឹងមិនមានការប៉ះពាល់អ្វីឡើយ។ ដូច្នេះ មេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីសូមឯកភាព។

**ប្រធានអង្គជំនុំ៖**

អរគុណលោកមេធាវី។

សូមអញ្ជើញលោកមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីអន្តរជាតិ។

[១០:០៤:១៧]

**លោកស្រី អេលីហ្សាបេត ស៊ីម៉ុនណូហ្វត៖**

សូមគោរពលោកប្រធាន។ ខ្ញុំចង់បញ្ជាក់ជូនតុលាការថា យើងនឹងដាក់បញ្ជីដើមបណ្តឹងរដ្ឋប្បវេណី ហើយខ្ញុំសូមឆ្លៀតឱកាសនេះ ដើម្បីគូសបញ្ជាក់ថាឥឡូវនេះ យើងមានដើមបណ្តឹងរដ្ឋប្បវេណីជាង ៣.០០០នាក់ ហើយបញ្ជីរបស់យើងគឺអាស្រ័យទៅលើដើមបណ្តឹងរដ្ឋប្បវេណីថ្មីផងដែរ។ ហើយខ្ញុំក៏ចង់បញ្ជាក់ជូនផងដែរ យើងមានការពេញចិត្តចំពោះសាលដីការបស់អង្គបុរេជំនុំជម្រះ ដែលអនុញ្ញាតឲ្យជនរងគ្រោះជាច្រើនអាចចូលរួមនៅក្នុងដំណើរការនិងនីតិវិធីនៅតុលាការនេះ។ ដូច្នេះ វាមិនមែនជាឧបសគ្គសម្រាប់យើងនោះទេ គឺថាវាបានពង្រឹងនូវមូលដ្ឋាននៃការធ្វើអន្តរាគមន៍របស់ដើមបណ្តឹងរដ្ឋប្បវេណីនៅក្នុងដំណើរការក្តីនេះ។

[១០:០៥:២០]

ខ្ញុំក៏ចង់បញ្ជាក់ជូនអង្គជំនុំជម្រះផងដែរថា ក្នុងឋានៈជាតំណាងនៃក្រុមដើមបណ្តឹងរដ្ឋប្បវេណី

ដែលរួមគ្នាជាក្រុមតែមួយ គឺថានៅក្រោយនោះ នៅក្រោយដើមបណ្តឹងនោះ ក៏មានក្រុមជាក់លាក់ ហើយនៅពីក្រោយនៃក្រុមជាក់លាក់នោះ គឺមានមនុស្សដែលបានទទួលរងនូវការឈឺចាប់។ ដូច្នេះ យើងមានប្រុងប្រយ័ត្នធ្វើយ៉ាងណាឲ្យដើមបណ្តឹងរដ្ឋប្បវេណីទាំងអស់ គឺរក្សានូវតួនាទីរបស់ខ្លួន ជាភាគីនៅក្នុងដំណើរការក្តី ហើយគឺយើងមិនត្រូវមានការយល់ច្រឡំជាមួយនឹងឋានៈជាសាក្សី។ ហើយនៅខែមករានៅពេលដែលបានស្នើសុំឲ្យបង្កើតបញ្ជី តុលាការបានបែងចែកយ៉ាងច្បាស់អំពីដើមបណ្តឹងរដ្ឋប្បវេណីហើយនិងឋានៈជាសាក្សី។ ដូច្នេះ នៅក្នុងដំណាក់កាលជំនុំជម្រះ យើងមានការប្រុងប្រយ័ត្នចំពោះតួនាទីរបស់យើង ធ្វើយ៉ាងឲ្យដើមបណ្តឹងរដ្ឋប្បវេណីរក្សាបាននូវតួនាទីរបស់ខ្លួននៅក្នុងដំណាក់កាលជំនុំជម្រះក្តី។

ដូច្នេះ យើងនឹងដាក់បញ្ជីរបស់យើងនៅថ្ងៃព្រហស្បតិ៍ គឺជាបញ្ជីដែលមានការកាត់បន្ថយ។ យើងបានស្នើសុំការបំភ្លឺអំពីអង្គជំនុំជម្រះ យើងក៏ស្នើសុំអំពីការបំភ្លឺអំពីគោលនយោបាយរបស់កម្ពុជា ដើម្បីឲ្យយើងអាចធ្វើបញ្ជីយើងឲ្យបានច្បាស់លាស់។ ដូច្នេះ យើងរង់ចាំការបំភ្លឺរហូតទៅដល់ថ្ងៃព្រហស្បតិ៍ ប៉ុន្តែក៏ខ្ញុំសូមជម្រាបថា គឺថាយើងនឹងដាក់នូវបញ្ជីដើមបណ្តឹងរដ្ឋប្បវេណីនៅថ្ងៃព្រហស្បតិ៍ជាកំហិត។ សូមអរគុណ។

[១០:០៦:៤៥]

**ប្រធានអង្គជំនុំ៖**

បាទ, អរគុណលោកស្រីមេធាវី។

តើមានបញ្ហាអ្វីចង់កត់សម្គាល់ទៀតទេ? សិនជាមាន យើងមិនមានទេ យើងបន្តកិច្ចដំណើរការរបស់យើងតទៅទៀត។

រាល់បញ្ហាទាំងឡាយដែលភាគីបានលើកឡើង អង្គជំនុំជម្រះបានធ្វើកត់សម្គាល់ ហើយនិងធ្វើឆ្លើយតបនៅក្នុងអំឡុងពេលនាថ្ងៃចុងក្រោយនៃសវនាការបឋម ឬនៅពេលបន្ទាប់។

ជាកិច្ចបន្ត អង្គជំនុំជម្រះកំណត់នូវកាលបរិច្ឆេទសម្រាប់ធ្វើការទាញហេតុផលដោយផ្ទាល់មាត់នៅក្នុងសវនាការបឋម ពាក់ព័ន្ធទៅនឹងរាល់បញ្ហាទាំងអស់ដែលអង្គជំនុំជម្រះយល់ថា ស្ថិតនៅក្រោមវិសាលភាពវិធាន៨៩ នៃវិធានផ្ទៃក្នុង។ អង្គជំនុំជម្រះបានគូសបញ្ជាក់រួចហើយថា បញ្ហាផ្នែកច្បាប់មួយចំនួនដែលភាគីយល់ថា ជាបញ្ហាអញ្ញត្រកម្មដែលនោះ។ អង្គជំនុំជម្រះនឹងសម្រេចអំពីបញ្ហានេះ ដោយផ្អែកទៅលើសារណាជាលាយលក្ខណ៍អក្សរ ដែលបានភាគីបានដាក់ប៉ុណ្ណោះ។ កន្លងអង្គជំនុំជម្រះក៏ធ្លាប់

បានបញ្ជាក់ថាអញ្ញត្រកម្មរបស់លោក ខៀវ សំផន ទាក់ទងនឹងយុត្តាធិការរបស់ អ.វ.ត.ក លើរូបបុគ្គលចំពោះរូបគាត់ តម្រូវឲ្យមាននូវការវាយតម្លៃរួមគ្នា ទៅលើអង្គហេតុ និងអង្គច្បាប់។ ដូច្នេះ អង្គជំនុំជម្រះនឹងសម្រេចលើអញ្ញត្រកម្មនេះ នៅពេលក្រោយ។

[១០:០៨:១៨]

អង្គជំនុំជម្រះយល់ឃើញថាការបញ្ជាក់ជាមុន ទៅលើបញ្ហាផ្នែកច្បាប់មួយចំនួន នឹងជួយដល់ដំណើរការជំនុំជម្រះឲ្យប្រព្រឹត្តទៅដោយឆាប់រហ័សនិងយុត្តិធម៌។ ត្រង់ចំណុចនេះ អង្គជំនុំជម្រះសំដៅទៅលើបញ្ហាផ្នែកច្បាប់មួយចំនួនដែលបានលើកឡើងក្នុងឯកសារ ដែលភាគីបានដាក់។ យុត្តាធិការរបស់ អ.វ.ត.ក ចំពោះបទល្មើសអន្តរជាតិ អនុលោមតាមគោលការណ៍នីត្យានុកូលភាព។ ការអនុវត្តនូវសហឧក្រិដ្ឋកម្មរួម ការទទួលខុសត្រូវរបស់ថ្នាក់លើ ជាទម្រង់នៃការទទួលខុសត្រូវ ភាពអាចអនុវត្តបាននៃបទល្មើស ការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ ការរំលោភផ្លូវភេទនៅក្នុងបទល្មើសនៃការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ អំពើអមនុស្សធម៌ផ្សេងៗទៀត នៃការជម្លៀសដោយបង្ខំ និងការបាត់ខ្លួនដោយបង្ខំ ក៏ដូចជាការដាក់ក្នុងមន្ទីរឃុំឃាំង និងការធ្វើទារុណកម្ម ជាឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ។

[១០:០៩:២១]

ការកំណត់នូវអង្គហេតុ ដែលបង្កើតបានជាការរំលោភផ្លូវភេទ ដែលជាផ្នែកមួយនៅក្នុងឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ជាជាងការដាក់បញ្ចូលនូវបទល្មើសនេះ នៅក្នុងអំពើអមនុស្សធម៌នៃឧក្រិដ្ឋ-កម្មប្រឆាំងនឹងមនុស្សជាតិ។ តើឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ដែលអនុវត្តនៅអ.វ.ត.ក តម្រូវឲ្យមានទំនាក់ទំនងជាមួយនឹងជម្លោះប្រដាប់អាវុធដែរឬក៏យ៉ាងណា?

អង្គជំនុំជម្រះយល់ឃើញថា បញ្ហាមួយចំនួនធំដែលភាគីបានលើកឡើងថាជាផ្នែមួយនៃអញ្ញត្រ-កម្មរបស់ខ្លួននោះ គឺមានការពន្យល់គ្រប់គ្រាន់ហើយ។ អង្គជំនុំជម្រះមិនតម្រូវឲ្យមាននូវសារណាបន្ថែមទាក់ទងនឹងបញ្ហានេះទេ។ ពាក់ព័ន្ធនឹងចំណុចនៅសេសសល់ ដែលសហព្រះរាជអាជ្ញាបានលើកឡើងនាពេលថ្មីៗនេះ អង្គជំនុំជម្រះបានពន្យារពេលដល់ក្រុមមេធាវីការពារក្តីរហូតដល់ថ្ងៃសុក្រ ទី២២ ខែកក្កដា ឆ្នាំ២០១១ ដើម្បីឆ្លើយតបទៅនឹងឯកសារលេខ E95, E99, E100 និងសំណើមួយទៀតរបស់សហព្រះរាជអាជ្ញា គឺឯកសារលេខ E96។ សហព្រះរាជអាជ្ញាមានរយៈពេលដប់ថ្ងៃ ដើម្បីធ្វើការឆ្លើយតបទៅនឹងចម្លើយតបរបស់មេធាវីការពារក្តី ប្រសិនបើខ្លួនមានបំណងធ្វើដូច្នេះ។

បន្ទាប់ពីបានទទួលសារណាទាំងអស់ហើយនោះ អង្គជំនុំជម្រះនឹងដោះស្រាយនូវបញ្ហាទាំងនេះនៅពេលក្រោយ។

[១០:១០:៥១]

ពេលវេលា និងកាលបរិច្ឆេទនៃសវនាការណាមួយ ដែលអាចនឹងមានដើម្បីដោះស្រាយបញ្ហានេះនឹងកំណត់នៅពេលក្រោយ។ ឆ្លើយតបទៅនឹងសំណើមួយដែលតវ៉ាអំពីបញ្ហាសម្បទារបស់ជនជាប់ចោទចំនួនបីរូបក្នុងការចូលរួមដំណើរការសវនាការ អង្គជំនុំជម្រះបានចាត់តាំងសាស្ត្រាចារ្យ ចន កំប៉ែល ដែលអ្នកជំនាញផ្នែករោគមនុស្សចាស់ ឲ្យធ្វើការវាយតម្លៃទៅលើជនជាប់ចោទទាំងបីរូបនោះ។ សាស្ត្រាចារ្យ កំប៉ែល បានធ្វើការវាយតម្លៃ និងដាក់ជូនអង្គជំនុំជម្រះនូវរបាយការណ៍របស់គាត់ពាក់ព័ន្ធនឹងជនជាប់ចោទទាំងបីរូបខាងលើ។

អង្គជំនុំជម្រះបានបញ្ជូននូវរបាយការណ៍ជាភាសាអង់គ្លេសរបស់សាស្ត្រាចារ្យ កំប៉ែល ទៅឲ្យក្រុមមេធាវីការពារក្តីជនជាប់ចោទចំនួនពីររូប នៅថ្ងៃ១៣ ខែមិថុនា ឆ្នាំ២០១១ ហើយជាភាសាខ្មែរនៅថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០១១។ ឯកសារនេះ ត្រូវបានចាត់ថ្នាក់ជាប្រភេទឯកសារសម្ងាត់បំផុត។ ប្រសិនបើក្រុមមេធាវីការពារក្តីមាននូវយោបល់ណាមួយ ឬក៏ជំទាស់ទៅនឹងរបាយការណ៍នោះ មេធាវីអាចដាក់នូវសារណាជាលាយលក្ខណ៍អក្សររបស់ខ្លួនចំពោះមុខអង្គជំនុំជម្រះ ដោយមិនឲ្យលើសពីថ្ងៃសុក្រ ទី០៨ ខែកក្កដា ឆ្នាំ២០១១។

[១០:១២:១៤]

បន្ទាប់មកអង្គជំនុំជម្រះនឹងដាក់នូវរបាយការណ៍ ព្រមទាំងការជំទាស់របស់មេធាវីការពារក្តីដែលបានទទួលក្នុងអំឡុងពេលដែលបានកំណត់ខាងលើ នៅក្នុងសំណុំរឿង ដោយចាត់ថ្នាក់ជាប្រភេទឯកសារសម្ងាត់។ ភាគីដទៃទៀត អាចធ្វើការឆ្លើយតបទៅនឹងរបាយការណ៍និងការជំទាស់ណាមួយត្រឹមថ្ងៃសុក្រ ទី១៥ ខែកក្កដា ឆ្នាំ២០១១ ប្រសិនបើខ្លួនមានបំណងធ្វើដូច្នេះ។ របាយការណ៍របស់អ្នក--អញ្ជើញ!

**លោកស្រី កាលីង វ៉ាន់ដឺរូត៖**

លោកប្រធាន, ខ្ញុំមិនដឹងថានៅពេលនេះ គឺជាពេលដែលសមស្រប ខ្ញុំលើកអញ្ញត្រកម្មនេះដែរឬទេ? យើងបានបដិសេធមិនឲ្យដាក់របាយការណ៍របស់ ចន កំប៉ែល ដែលជាឯកសារសម្ងាត់។ តើលោកប្រធាន ខ្ញុំឲ្យចង់លើកបញ្ហានេះ នៅពេលនេះ ឬក៏យ៉ាងម៉េច?

**ប្រធានអង្គជំនុំ៖**

បញ្ហានេះ សូមបញ្ជាក់អ៊ីចេះថា បញ្ហាលោកស្រីដែលលើកឡើងនេះ ប្រសិនបើមានបំណងគឺលោកស្រីអាចប្រើប្រាស់ឯកសារនោះ ភ្ជាប់ជាមួយនឹងសារណារបស់លោកស្រី។

របាយការណ៍របស់អ្នកជំនាញពាក់ព័ន្ធនឹងជនជាប់ចោទទីបី បានចេញកាលពីថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០១១ ហើយនៅថ្ងៃដដែល អង្គជំនុំជម្រះសាលាដំបូង ក៏បានបញ្ជូនរបាយការណ៍ជាភាសាអង់គ្លេសយ៉ាងសម្ងាត់បំផុតទៅឲ្យក្រុមមេធាវីពារការក្តី ដែលពាក់ព័ន្ធ និងមានរបាយការណ៍នេះជាភាសាខ្មែរនៅពេលឆាប់ៗខាងមុខ។ ប្រសិនបើក្រុមមេធាវីការពារក្តី មានមតិយោបល់ ឬមានការជំទាស់ណាមួយទៅនឹងរបាយការណ៍នេះ មេធាវីអាចដាក់សេចក្តីសង្ខេតជាលាយលក្ខណ៍អក្សរដោយបញ្ជាក់ពីមូលហេតុនៃការជំទាស់ ជូនអង្គជំនុំជម្រះយ៉ាងយូរបំផុតត្រឹមថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០១១។

នៅថ្ងៃនោះអង្គជំនុំជម្រះនឹងយករបាយការណ៍នេះ ព្រមជាមួយនឹងសេចក្តីជំទាស់ណាមួយ ដែលខ្លួនបានទទួលទៅដាក់បញ្ចូលក្នុងសំណុំរឿងជាប្រភេទឯកសារសម្ងាត់។ ប្រសិនបើភាគីមានបំណងចង់ឆ្លើយទៅនឹងរបាយការណ៍ និងសេចក្តីជំទាស់ណាមួយពាក់ព័ន្ធនឹងរបាយការណ៍នេះ ខ្លួនអាចធ្វើបានត្រឹមថ្ងៃចន្ទ ទី២៥ ខែកក្កដា ឆ្នាំ២០១១។

ប្រសិនបើអង្គជំនុំជម្រះយល់ថា ចាំបាច់ត្រូវមានសវនាការបន្ថែមពាក់ព័ន្ធទៅនឹងសម្បទារបស់ជនជាប់ចោទណាម្នាក់ ក្នុងការទទួលបានការចូលរួមក្នុងការកាត់សេចក្តី កាលបរិច្ឆេទនៃសវនាការនេះនឹងកំណត់នៅពេលក្រោយ។ កិច្ចសវនាការនេះទំនងជាប្រព្រឹត្តទៅនៅក្នុងខែសីហា ឆ្នាំ២០១១។

[១០:១៥:៥២]

អង្គជំនុំជម្រះសូមជូនដំណឹងដល់ភាគីទាំងអស់ថា បន្ទប់រង់ចាំនៅខាងក្រោមសាលសវនាការដែលមានភ្ជាប់នូវប្រព័ន្ធសោតទស្សន៍ និងទូរស័ព្ទ ដែលអាចទំនាក់ទំនងបានពីបន្ទប់រង់ចាំនីមួយៗមកបន្ទប់សវនាការ គឺអាចដំណើរការបានទាំងស្រុង។ នៅគ្រប់ពេល ក្នុងអំឡុងពេលសវនាការនេះជនជាប់ចោទគ្រប់រូបអាចជ្រើសរើសការចូលរួមនៅក្នុងកិច្ចដំណើរការនីតិវិធីសវនាការនេះ តាមរយៈប្រព័ន្ធសោតទស្សន៍ ដោយមិនចាំបាច់ចូលរួមដោយផ្ទាល់ក្នុងបន្ទប់សវនាការក៏បាន។

នៅពេលដែលជនជាប់ចោទសម្រេចថា ខ្លួនត្រូវមានវត្តមាននៅក្នុងបន្ទប់សវនាការ ប៉ុន្តែតម្រូវឲ្យមានការឈប់សម្រាករយៈពេលខ្លី។ ឧទាហរណ៍ ត្រូវទៅបន្ទប់ទឹក ជនជាប់ចោទអាចត្រូវបានអនុរក្សមន្ទីរឃុំឃាំងនាំចេញពីបន្ទប់សវនាការទៅកាន់សវនាការបានគ្រប់ពេលវេលាទាំងអស់ ដោយមិនចាំបាច់

សុំការអនុញ្ញាតពីអង្គជំនុំជម្រះសាលាដំបូងនោះទេ។ ជនជាប់ចោទក៏មិនត្រូវបានតម្រូវឲ្យក្រោកឈរផងដែរ នៅពេលអង្គជំនុំជម្រះប្រកាសឈប់សម្រាក ឬបន្តកិច្ចដំណើរការនីតិវិធីសវនាការ។

[១០:១៧:១០]

ពាក់ព័ន្ធនឹងបញ្ហានេះ តើភាគីសហព្រះរាជអាជ្ញា សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី និងសហមេធាវីការពារក្តីមានមតិយោបល់អ្វីដែរឬទេ?

សូមអញ្ជើញលោកមេធាវី កាណាវាស!

**លោក ម៉ៃខល កាណាវាស៖**

អរុណសួស្តីលោកប្រធាន លោក លោកស្រីចៅក្រមជាទីគោរព។

ចំពោះការសង្កេតទាក់ទងទៅនឹងការដាក់ឯកសារថ្មីៗនេះ យើងអរគុណចំពោះការពន្យារពេល។ ការពន្យារនោះ គឺដោយសារតែយើងមិនមានពេលគ្រប់គ្រាន់។ យើងដឹងហើយថា សហព្រះរាជអាជ្ញាបានធ្វើការថ្លឹងថ្លែងបញ្ហាទាំងអស់នេះ បញ្ហាមួយចំនួននោះ គឺវាហួស វាស្ថិតនៅក្រៅរយៈពេលកំណត់របស់យើង ដែលយើងមិនអាចដាក់បាន។

ដូច្នេះហើយចំពោះយើង យើងត្រូវតែគិតពិចារណានៅពេលនេះ គឺឯកសារអស់បានទទួលបាន។ ឧទាហរណ៍ ចំពោះបញ្ហា ជេ.ស៊ី.អ៊ី សហឧក្រិដ្ឋកម្មរួម យើងមើលទៅលើខ្លឹមសារ។ ពាក់ព័ន្ធទៅនឹងសហឧក្រិដ្ឋកម្មរួមទីបី វាពាក់ព័ន្ធទៅនឹងយុត្តាធិការ។ ដូច្នេះហើយ សហព្រះរាជអាជ្ញារង់ចាំទៅដល់ដំណាក់កាលចុងក្រោយ។

[១០:១៨:៣៧]

ដូច្នេះហើយទើបខ្ញុំ ខ្ញុំស្នើសុំដាក់ឯកសារថា ភាគីក្នុងនាមជាមេធាវីការពារក្តី សូមសួរថាតើពេលណាដែលថា យុត្តាធិការនោះវាជាពេលវេលារារាំង? ដោយសារតែយើងត្រូវលើកឡើងអំពីចំណុចអង្គសេចក្តី។ យើងដឹងហើយថា សហព្រះរាជអាជ្ញាព្យាយាមធ្វើឲ្យប៉ះពាល់ទៅដល់កិច្ចដំណើរការនីតិវិធីនេះដោយលើកឡើងអំពីសហឧក្រិដ្ឋកម្មរួម។ ប្រសិនបើគេលើកឡើងថា សហឧក្រិដ្ឋកម្មរួមទីបីនោះ វាពាក់ព័ន្ធ គឺគួរតែបញ្ជាក់ឲ្យបានច្បាស់ ថាហេតុអ្វីគេចង់ឲ្យអ្នកដែលមិនមែនជាភាគីដាក់សារណា?

[១០:១៩:២៤]

វាជាតាក់ទិចមួយដែលជាការពន្យារនិងការរារាំងកិច្ចដំណើរការនីតិវិធី។ សហព្រះរាជអាជ្ញាបានលើកឡើងថា ទោះបីយ៉ាងណាក៏ដោយយើងអាចបន្តនីតិវិធីរបស់យើងបាន។ ខ្ញុំមើលទៅក្នុងរបាយ-

ការណ៍ យើងមិនអាចដំណើរការនីតិវិធីបានទេ លើកលែងតែយើងយល់ឲ្យបានច្បាស់ ថាតើសំណួរណាខ្លះដែលគេលើកឡើងនិងមិនលើកឡើង?

សហព្រះរាជអាជ្ញាមានរយៈពេលជាច្រើនខែ ក្នុងការដាក់ឯកសារទាំងអស់នោះ។ ខ្ញុំមិនជំទាស់ទេ ប៉ុន្តែយ៉ាងណាក៏ដោយ គាត់គួរតែដាក់ឲ្យបានត្រឹមត្រូវក្នុងរយៈពេលកំណត់។ ដូច្នេះហើយ សូមអង្គជំនុំជម្រះធ្វើការបង្គាប់ទៅដល់ភាគី ថាតើរយៈពេលណាដែលជារយៈពេលចុងក្រោយ? ធ្វើយ៉ាងណាក៏ដោយ ធ្វើយ៉ាងនេះដើម្បីឲ្យដំណើរការរបស់យើងនេះដំណើរការទៅបានល្អ កុំឲ្យមានការរាំងទៅដល់ដំណើរការនីតិវិធី។

[១០:២០:២៤]

សហព្រះរាជអាជ្ញាធ្វើយ៉ាងណាក៏ដោយ កុំធ្វើការរាំងកិច្ចការងាររបស់មេធាវីការពារក្តី ដើម្បីកុំឲ្យយើង-- ឲ្យយើងនឹងបានដំណើរការរបស់យើងបានត្រឹមត្រូវ។ សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញសហព្រះរាជអាជ្ញាអន្តរជាតិ!

**លោក អាន់ឌ្រូ ខេលី៖**

សូមអរគុណលោកប្រធាន។ ជាបឋមអនុញ្ញាតឲ្យខ្ញុំបញ្ជាក់ជូនអង្គជំនុំជម្រះឲ្យបានជ្រាបថា យើងមានសិទ្ធិក្នុងការដាក់សំណើទាំងឡាយដូចដែលលោក កាណាវាស បានលើកឡើង។ ខ្ញុំលើកឡើងថា ថា វាជាបញ្ហាលើកឡើងមួយជាការចោទប្រកាន់ថា យើងធ្វើការបំផ្លាញរាំងដំណើរការនីតិវិធី។

[១០:២១:១៣]

នៅក្នុងនីតិវិធីរបស់យើង ពេលខ្លះទៅវាៗមិនសមស្របទេក្នុងការលើកឡើងដូច្នេះ។ ខ្ញុំមិនអាចទទួលយកបាន។ ដូច្នេះខ្ញុំស្នើសុំឲ្យតុលាការបង្គាប់ទៅខាងមេធាវីការពារក្តីធ្វើការដាក់ចម្លើយតបរបស់ខ្លួនក្នុងរយៈពេលកំណត់ ទៅតាមការកំណត់របស់អង្គជំនុំជម្រះ ហើយបង្គាប់ឲ្យសហមេធាវីការពារក្តីលោក កាណាវាស ឈប់លើកឡើងបញ្ហាដែលមិនគួរសមបែបនេះ។ សូមអរគុណ។

[១០:២១:៥៤]

**ប្រធានអង្គជំនុំ៖**

បាទ, ឥឡូវនេះឃើញថា ពេលវេលាសមល្មមនឹងឈប់សម្រាកហើយ។ អង្គជំនុំជម្រះប្រកាសសម្រាកម្ភៃនាទី ចាប់ពីពេលនេះទៅរហូតដល់ម៉ោងដប់មួយខ្វះម្ភៃនាទី សូមអញ្ជើញចូលវិញ ដើម្បីបន្ត

កិច្ចដំណើរការនីតិវិធីរបស់យើង។

**លោកស្រី សែ គុលវុឌ្ឍី៖**

សូមអញ្ជើញក្រោកឈរ!

*(សវនាការសម្រាកពីម៉ោង ១០:២៣ នាទី ដល់ម៉ោង ១០:៤៨ នាទី)*

[១០:៤៩:00]

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញអស់លោក លោកស្រីអង្គុយចុះ! អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការកិច្ចនីតិវិធីសវនាការ។

សូមអញ្ជើញលោកសហព្រះរាជអាជ្ញាអន្តរជាតិ!

**លោក អាន់ឌ្រូ ខេលី៖**

សូមអរគុណលោកប្រធាន។ ខ្លីទេ ខ្ញុំសូមខ្លីទេ ហើយខ្ញុំមិនបានលើកឡើងអំពីបញ្ហានេះនៅព្រឹកមិញនេះ ព្រោះខ្ញុំដឹងថាតុលាការបានកំណត់នូវកាលវិភាគរបស់ខ្លួនសម្រាប់សវនាការនេះហើយ។ ហើយយើងបានស្តាប់ដោយយកចិត្តទុកដាក់អំពីការលើកឡើងដោយមេធាវីសម្រាប់លោក នួន ជា ហើយយើងខ្ញុំមានការព្រួយបារម្ភមួយចំនួនអំពីបញ្ហាដែលបានលើកឡើងនៅក្នុងអំឡុងពេលដែលមេធាវីបានលើកឡើង។ ជាពិសេសដោយសារតែកិច្ចដំណើរការនីតិវិធីនេះ យើងធ្វើជាសាធារណៈ ហើយបញ្ហាទាំងអស់នេះត្រូវបានគេរាយការណ៍នៅក្នុងបណ្តាញសារព័ត៌មាន ហើយយើងដឹងថា ខ្ញុំចង់សុំឲ្យមានឱកាសនៅក្នុងពេលណាមួយនៅក្នុងថ្ងៃនេះ ដើម្បីកុំឲ្យយើងមានការរំខានទៅដល់កិច្ចដំណើរការនីតិវិធីដើម្បីឲ្យខាងខ្ញុំជាព្រះរាជអាជ្ញាហ្នឹងបានឆ្លើយតបទៅនឹងបញ្ហាហ្នឹង ដែលខ្ញុំជឿជាក់ថាមានបញ្ហាអត់មានសុក្រឹតភាពនៅក្នុងព័ត៌មានចំនួនដែលបានលើកឡើងដោយខាងមេធាវីការពារក្តីនេះ ដើម្បីឲ្យយើងខ្ញុំអាចបង្ហាញនូវរូបភាពពិតប្រាកដអំពីបញ្ហាដែលបានលើកឡើងនេះ។ សូមគោរពអនុញ្ញាតពីតុលាការដូច្នេះសូមអរគុណ។

[១០:៥០:៤៥]

**ប្រធានអង្គជំនុំ៖**

បាទ, អរគុណលោកសហព្រះរាជអាជ្ញា យើងកត់សម្គាល់នូវបញ្ហានេះ ហើយនិងពិចារណាសម្រេចនៅពេលក្រោយ។

សូមអញ្ជើញលោកមេធាវី ផាត់ ពៅស៊ាង!

**លោក ផាត់ ពៅស៊ាង៖**

សូមអរគុណដល់លោកប្រធានដែលបានអនុញ្ញាតឲ្យខ្ញុំបាទ។ ជាបឋម ខ្ញុំបាទសូមគោរពជូនក្រុមប្រឹក្សាអង្គជំនុំជម្រះសាលាដំបូងថា ដោយសារបញ្ហាសុខភាព កូនក្ដីខ្ញុំបាទមិនអាចស្ថិតនៅក្នុងសាលសវនាការបានក៏សុំការអនុញ្ញាតត្រឡប់ទៅមន្ទីរឃុំឃាំងវិញ ហើយនិងសុំមិនចូលរួមរហូតដល់ថ្ងៃ៣០ រហូតដល់បញ្ចប់នៃសវនាការបឋមនេះបាទ ដោយសារបញ្ហាសុខភាព។

[១០:៥១:៣៧]

**ប្រធានអង្គជំនុំ៖**

បាទ, អរគុណលោកមេធាវី។ ដោយមានសំណើសមស្រប ហើយបញ្ជាក់ពីមូលហេតុនៃបញ្ហាសុខភាព ហើយម្យ៉ាងនេះជាសិទ្ធិរបស់ជនជាប់ចោទចូលរួម ឬក៏មិនចូលរួមផ្ទាល់នៅក្នុងកិច្ចដំណើរការសវនាការ អង្គជំនុំជម្រះអនុញ្ញាតតាមការស្នើសុំ។

អនុរក្សមន្ទីរឃុំឃាំងឲ្យនាំលោកស្រី អៀង ធីរិទ្ធ ត្រឡប់ទៅកាន់មន្ទីរឃុំឃាំងវិញចុះ! ហើយប្រសិនជាអាចដំណើរការបាន សូមខាងជំនាញសោតទស្សន៍ធ្វើការភ្ជាប់នូវប្រព័ន្ធសោតទស្សន៍នៃកិច្ចដំណើរការនីតិវិធីរបស់យើង ដែលបានរៀបចំរួចហើយ សម្រាប់ឲ្យគាត់នៅមន្ទីរឃុំឃាំង។

*(ជនជាប់ចោទចាកចេញពីសាលសវនាការ)*

សូមអញ្ជើញ!

[១០:៥៣:០០]

**លោក វិចទ័រ កូប៉េះ៖**

សូមគោរពលោកប្រធាន លោកចៅក្រម យើងមានសំណើចំនួនពីរសម្រាប់ធ្វើការបញ្ជាក់ឡើងវិញទាក់ទងទៅនឹងបញ្ហាសាក្សីដែលយើងនឹងត្រូវពិភាក្សានៅថ្ងៃព្រហស្បតិ៍នោះ។ សំណួររបស់ខ្ញុំនៅទីនេះ គឺថា ថាតើយើងធ្វើការពិភាក្សានៅថ្ងៃព្រហស្បតិ៍នេះត្រឹមតែសាក្សី ដែលបានលើកឡើងនៅក្នុងបញ្ជីនៃសាក្សីដែលលោកចៅក្រមបានត្រៀម ឬក៏យើងពិភាក្សាទៅលើសាក្សី ដែលនៅក្នុងដំណាក់កាលនេះ ដែលយើងគិតថាត្រូវបានគេបដិសេធដោយអង្គជំនុំជម្រះសាលាដំបូង។ នេះគឺជាសំណើទីមួយរបស់យើងខ្ញុំ សម្រាប់ឲ្យមានការបញ្ជាក់ឡើងវិញ។ ហើយសំណើទីពីរសម្រាប់ការសុំការបញ្ជាក់នោះ គឺដូចខាងក្រោមនេះ។

ថាតើលោកចៅក្រមអាចផ្តល់នូវការបញ្ជាក់ ថាតើហេតុអ្វីបានជានៅថ្ងៃព្រហស្បតិ៍នេះ យើងនឹងចាំបាច់ត្រូវតែប្រើប្រាស់នូវឈ្មោះ រហស្សនាមដែលត្រូវបានដាក់នៅក្នុងបញ្ជីឈ្មោះសាក្សីនៅក្នុងបញ្ជីនោះ។ យើងខ្ញុំចង់ដឹងអំពីហេតុផលសម្រាប់សេចក្តីសម្រេចនេះ នៅក្នុងដំណាក់កាលនេះ ខ្ញុំអាចបន្ថែមថាជំហររបស់ខាងខ្ញុំ គឺថាចំណុចនេះគឺមិនចាំបាច់មានហេតុផលអីត្រូវប្រើរហស្សនាមសម្រាប់សាក្សីនោះទេ ដែលសាក្សីយើងត្រូវពិភាក្សានៅថ្ងៃព្រហស្បតិ៍នេះ។

ដូច្នេះ ខ្ញុំមានសំណើពីរនេះ សូមឲ្យមានការបញ្ជាក់ឡើងវិញ។ សូមអរគុណ។

[១០:៥៤:២០]

**ប្រធានអង្គជំនុំ៖**

អរគុណលោកមេធាវីដែលបានធ្វើការកត់សម្គាល់នូវបញ្ហាដ៏មានសារៈសំខាន់នេះ ហើយបញ្ហានេះអង្គជំនុំជម្រះនឹងធ្វើការជម្រាបជូនដល់លោកមេធាវីនៅក្នុងអំឡុងពេលសមស្របខាងមុខនេះឲ្យបានមុននូវថ្ងៃកំណត់កាលបរិច្ឆេទនៃដំណើរការជជែកពិភាក្សាចំពោះបញ្ហាសាក្សី បញ្ជីសាក្សី អ្នកជំនាញ និងដើមបណ្តឹងរដ្ឋប្បវេណី។

[១០:៥៥:៤៥]

បន្ទាប់ពីបានពិភាក្សាជាមួយលោកស្រីចៅក្រម ខ្ញុំសូមឆ្លើយនឹងសំណូមពររបស់លោកមេធាវីការពារក្តីលោក នួន ជា អម្បាញ់មិញនេះ។ បញ្ហាដូចជាខាងអង្គជំនុំជម្រះបានបង្ហាញសមល្មមនឹងអាចស្តាប់បានហើយនូវហេតុផលទាំងឡាយនៃការដែលមិនទាន់ដល់ដំណាក់កាលត្រូវបង្ហាញខ្លួន-- អត្តសញ្ញាណ ជាសាធារណៈនូវសាក្សី អ្នកជំនាញ ដើមបណ្តឹងរដ្ឋប្បវេណី ដោយយើងគោរពនូវគោល-ការណ៍នៃវិធានការការពារសាក្សី អ្នកជំនាញ ឬដើមបណ្តឹងរដ្ឋប្បវេណី រហូតដល់ពេលនេះអង្គជំនុំជម្រះមិនទាន់បានទទួលនូវរបាយការណ៍ពីអង្គភាពគាំពារសាក្សី អ្នកជំនាញ ក្នុងកិច្ចដំណើរការនៅឡើយទេ អំពីស្ថានភាពនិងតម្រូវការ ថាតើសាក្សី អ្នកជំនាញ ដើមបណ្តឹងរដ្ឋប្បវេណីណាខ្លះដែលគេនឹងស្នើសុំវិធានការការពារ។ ហើយតើហានិភ័យនៃបញ្ហានោះកម្រិតណា ដែលអង្គជំនុំជម្រះនឹងពិចារណាបន្តបន្តបន្ទាប់។

ដូច្នេះហេតុផលនេះ គឺអង្គជំនុំជម្រះនឹងមិនអនុញ្ញាតឲ្យដំណើរការបញ្ចេញឈ្មោះសាក្សី អ្នកជំនាញ ដើមបណ្តឹងរដ្ឋប្បវេណី ដែលបាន-- ជាបណ្តោះអាសន្នដែលអង្គជំនុំជម្រះបានជម្រាបជូនដល់ភាគីរួចហើយនោះ ជាសាធារណៈទេ គឺត្រូវរក្សាជាការងារសម្ងាត់។ ហើយដំណើរការប្រព្រឹត្តទៅ

គឺដូចបាន-- អង្គជំនុំជម្រះបានបញ្ជាក់រួចហើយថា នីតិវិធីអាចប្រព្រឹត្តទៅជាសាធារណៈបាន លុះត្រាតែភាគីយល់ស្របថា នៅក្នុងកិច្ចជជែកពិភាក្សាសម្រេចអំពីបញ្ហានេះ ភាគីនឹងរក្សានូវការប្រើប្រាស់រហស្សនាមរបស់សាក្សី អ្នកជំនាញ ដើមបណ្ដឹងរដ្ឋប្បវេណីទាំងនោះ។ អ៊ីចឹងដូចជាច្បាស់លាស់ហើយលើបញ្ហាបញ្ជីឈ្មោះសាក្សី អ្នកជំនាញ និងដើមបណ្ដឹងរដ្ឋប្បវេណីនេះ។ ហើយរហស្សនាម គឺអង្គជំនុំជម្រះបានគ្រោងទុករួចហើយ កំណត់នៅក្នុងបញ្ជីឈ្មោះនោះស្រេច។

អញ្ជើញលោក ស សូវាន តើមានបញ្ហាអ្វីទេ?

[១០:៥៨:២០]

**លោក ស សូវាន៖**

សូមអរគុណលោកប្រធាន សូមគោរពអង្គជំនុំជម្រះ ខ្ញុំបាទសូមមានការកត់សម្គាល់ពីរចំណុច មិនឲ្យរំខានដំណើរការ។ ចំណុចចង់ឆ្លើយតបទៅនឹងមេធាវីជាតិ និងអន្តរជាតិខាងជនរងគ្រោះ។

ខ្ញុំអបអរសាទរពីព្រោះកុំឲ្យតុលាការនេះ ច្រឡំតួនាទីសាក្សី និងតួនាទីជនរងគ្រោះ ហើយខ្ញុំសូមកត់សម្គាល់ថា មានជនរងគ្រោះជាងមួយលាននាក់ ប៉ុន្តែសូមជម្រាបថា មានតែ៣៨០០ ជាជនរងគ្រោះតំណាងដោយមេធាវីប្រាំបួននាក់នេះ។

ដូច្នេះខ្ញុំសូមសង្កត់មួយទៅទៀតថា នៅខាងមុខខ្ញុំនេះមានមេធាវីប្រាំបួននាក់ ជនរងគ្រោះ៣០០៨ នាក់។ ខាងស្ដាំខ្ញុំ លោកអគ្គព្រះរាជអាជ្ញាជាតិ និងសហព្រះរាជអាជ្ញាអន្តរជាតិ ជាអ្នកដើរតួនាទីចោទប្រកាន់កូនក្ដីខ្ញុំ។ ដូច្នេះខ្ញុំក៏សុំដែរថា នៅក្នុងតួនាទីមេធាវីការពារជនជាប់ចោទ ខ្ញុំសូមថាព្រះរាជអាជ្ញាជាតិ និងអន្តរជាតិ នៅក្នុងការវែកញែក យើងរកយុត្តិធម៌ ដើម្បីឲ្យរាស្ត្រខ្មែរហ្នឹងទាញហេតុផល។ ដូច្នេះខ្ញុំ កូនក្ដីខ្ញុំ មិនខ្លាចការពិត។ ឥឡូវនេះ ខ្ញុំបញ្ចប់ត្រឹមហ្នឹងហើយ សូមសំណូមពរថា អង្គអគ្គព្រះរាជអាជ្ញា សូមមេត្តាថា លោកអ្នកចោទ ចោទចុះ ពីព្រោះតុលាការនេះបានសម្រេចហើយ រឿងខ្ញុំសូមលោកឆ្លើយជាភាសា ជាអក្សរ ខ្ញុំថារឿងកាប់សម្លាប់ប្រល័យពូជសាសន៍ មិនយកមកអនុវត្តលើប្រធានរដ្ឋទេ ដូចស្ដេចរាល់ថ្ងៃហ្នឹង លោកមានដឹងអី។ ប៉ុន្តែគេថាមិនមែនអ៊ីចឹងទេ កូនក្ដីខ្ញុំមានជាប់ពាក់ព័ន្ធតាមអំពើ។ អត់អីទេយើងយកមកអំពើ យើងអត់ខ្លាចទេ។ ដូច្នេះខ្ញុំសូមបញ្ចប់ត្រឹមហ្នឹង។

[១១:០១:១២]

ចំណុចទីពីរ ខ្ញុំសូមលោកប្រធាន និងអង្គតុលាការនេះ មេត្តាអនុញ្ញាតឲ្យកូនក្ដីខ្ញុំមានលទ្ធភាពកាលណាគាត់ហត់ ពីព្រោះបួននាក់ បីនាក់ហ្នឹងគេអត់មកទេ មានតែកូនក្ដីខ្ញុំទេ គាត់មកព្រោះគាត់សុខ

ភាពល្អ ហើយគាត់ចង់សហការដើម្បីរកការពិត។ តើរបបកម្ពុជាប្រជាធិបតេយ្យហ្នឹង មានអ្នកណាខ្លះកាប់សម្លាប់។ ដូច្នេះខ្ញុំសូមឱ្យលោកប្រធានមេត្តាអនុញ្ញាតឱ្យកូនក្តីខ្ញុំ ឥឡូវហ្នឹង គាត់សូមចេញក្រៅ ប៉ុន្តែគាត់មកវិញ។ ប៉ុន្តែនៅក្នុងបួនថ្ងៃនេះ កាលណាគាត់សុំចេញ ខ្ញុំនឹងជម្រាបលោកប្រធាន ពីព្រោះគាត់ម្នាក់ឯង គាត់សុខចិត្តសហការ អត់ឈប់ទេ។ ប៉ុន្តែអំមិញឥឡូវនេះ គាត់ចង់ចេញទៅមួយភ្លែត គាត់មកវិញ។ តើលោកប្រធានសុខចិត្តទេ? សូមទោស។

[១១:០២:០៩]

**ប្រធានអង្គជំនុំ៖**

អម្បាញ់មិញ មុនពេលសម្រាកអង្គជំនុំជម្រះបានជម្រាបដល់សាធារណជន ដល់អង្គសវនាការទាំងមូលជ្រាបហើយ ច្បាស់លាស់ហើយ អំពីនីតិវិធីនៃដំណើរការប្រព្រឹត្តទៅចំពោះស្ថានភាពជនជាប់ចោទ ដែលមានបញ្ហាសុខភាព មានបញ្ហាចាស់ជរានេះ អង្គជំនុំជម្រះអនុញ្ញាតឱ្យគាត់ចាកចេញពីបន្ទប់សវនាការនេះទៅកាន់កន្លែងណាដែលសមស្របនៅក្នុងទីនេះ ដូចជាបន្ទប់ទឹកដោយមិនមានចាំបាច់មានការអនុញ្ញាតពីអង្គជំនុំជម្រះទេ។ ទីពីរ សូម្បីតែក្រោកឈរ អង្គជំនុំជម្រះបានអនុញ្ញាតថាមិនចាំបាច់ក្រោកឈរទេនៅពេលដែលអង្គជំនុំជម្រះចូលមកកាន់អាសនៈរបស់ខ្លួន ឬក៏ចាកចេញពីអាសនៈដែលជានីតិវិធីនៅក្នុងដំណើរការសវនាការរបស់តុលាការ សាធារណជន និងភាគីទាំងអស់ដែលនៅក្នុងសវនា-ការ ត្រូវគោរព ត្រូវការក្រោកឈរ ជាការគោរពដល់អង្គជំនុំជម្រះ។ ប៉ុន្តែដោយសារពិនិត្យនូវស្ថានភាពនៃបញ្ហាដែលលើកឡើងអម្បាញ់មិញ អង្គជំនុំជម្រះដូចជាបានប្រាប់ច្បាស់លាស់រួចហើយ។

[១១:០៣:៣៥]

ទីបី គឺប្រសិនបើភាគីដែលមានបំណងលើក គឺសូមលើកកំណត់ចំបញ្ហាដែលជាកម្មវត្ថុនៃការជជែកនៃការចង្អុលបង្ហាញរបស់អង្គជំនុំជម្រះ។ អម្បាញ់មិញនេះ អង្គជំនុំជម្រះជជែកពិភាក្សាពាក់ព័ន្ធនឹងបញ្ជីឈ្មោះសាក្សី អ្នកជំនាញ ដើមបណ្តឹងប្បវេណី នីតិវិធីនៃការប្រព្រឹត្តទៅយ៉ាងដូចម្តេចដែលភាគីយល់ថាវាត្រឹមត្រូវបំផុតសមស្របបំផុត ដើម្បីអង្គជំនុំជម្រះក្តាប់បាននូវទស្សនៈ នូវគំនិតយោបល់នោះយកមកវិភាគ ដើម្បីកំណត់នូវកិច្ចដំណើរការនីតិវិធីដេញដោលពាក់ព័ន្ធនឹងបញ្ជីឈ្មោះសាក្សី អ្នកជំនាញទៅថ្ងៃមុខ នៅថ្ងៃចុងក្រោយនៃសវនាការនោះឱ្យបានត្រឹមត្រូវ ធានានូវនីតិវិធី ដែលត្រឹមត្រូវបំផុត។

ជាកិច្ចបន្ត ឈានចូលដល់របៀបវារៈការទាញហេតុផលដោយផ្ទាល់មាត់ ទាក់ទងទៅនឹងអញ្ញត្រកម្មស្តីពីការគោលការណ៍ គ្មានការកាត់ទោសពីរដង។ ថ្ងៃនេះអង្គជំនុំជម្រះចាប់ផ្តើមនូវការទាញ

ហេតុផលដោយផ្ទាល់មាត់ ទាក់ទងនឹងបញ្ហាអញ្ញត្រកម្មមួយចំនួនរបស់ក្រុមមេធាវីការពារក្តី។

បញ្ហាទីមួយសម្រាប់ធ្វើការពិចារណា គឺអញ្ញត្រកម្មពាក់ព័ន្ធនឹងគោលការណ៍គ្មានការ កាត់ទោសពីរដង ឬការហាមឃាត់មិនឲ្យមានការចោទប្រកាន់ច្រើនដងចំពោះបទល្មើសតែមួយ។ អញ្ញត្រកម្មនេះត្រូវបានលើកឡើងដោយក្រុមមេធាវីការពារក្តី អៀង សារី។ ក្រុមមេធាវីការពារក្តី អៀង សារី មានរយៈពេលមួយម៉ោងសម្រាប់ធ្វើការបង្ហាញអំពីអញ្ញត្រកម្មនេះ។ បន្ទាប់មក សហព្រះរាជអាជ្ញាមានរយៈពេល៤៥នាទី ហើយសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីមានរយៈពេល៣០នាទី ដើម្បីធ្វើសេចក្តីថ្លែងការណ៍តប។ បន្ទាប់មកក្រុមមេធាវីការពារក្តី អៀង សារី មានរយៈពេល១៥នាទី ដើម្បីធ្វើការឆ្លើយតបវិញ។

[១១:០៥:៤២]

អង្គជំនុំជម្រះសូមរំឭកដល់ភាគីទាំងអស់ថា អង្គជំនុំជម្រះបានយល់ច្បាស់ហើយអំពីខ្លឹមសារនៃសារណាជាលាយលក្ខណ៍អក្សរនានា ដែលភាគីបានដាក់រហូតមកដល់ពេលនេះ។

ដូច្នេះ អង្គជំនុំជម្រះសូមបញ្ជាក់ថា ភាគីទាំងអស់មិនត្រូវលើកឡើងដដែលៗនូវចំណុចដែលមាននៅក្នុងសារណាលាយលក្ខណ៍អក្សរនោះទៀតទេ។

សូមអញ្ជើញមេធាវីការពារក្តីលោក អៀង សារី ឡើងធ្វើបទបង្ហាញស្តីពីបញ្ហាអញ្ញត្រកម្មគោលការណ៍គ្មានការកាត់ទោសពីរដងចំពោះបទល្មើសតែមួយ។ សូមអញ្ជើញ!

**លោក អាង ឧត្តមៈ**

សូមគោរពលោកចៅក្រមប្រធាន សូមគោរពលោក លោកស្រីចៅក្រមសមាជិក។ ក្នុងនាមជាសហមេធាវីការពារក្តីលោក អៀង សារី។ លោក ម៉ៃខល និងខ្ញុំបាទមានកិត្តិយស និងមានមោទកភាពណាស់ដែលបានអនុញ្ញាតឲ្យការពារក្តីជូនលោក អៀង សារី។ ក្នុងរយៈពេលពីរបីថ្ងៃទៅនេះ យើងខ្ញុំនឹងថ្លែងប្រាស្រ័យពីបណ្តឹងអញ្ញត្រកម្មមួយចំនួន ដែលយើងខ្ញុំមានចំពោះយុត្តាធិការរបស់អង្គជំនុំជម្រះនេះ។ ថ្ងៃនេះយើងខ្ញុំនឹងថ្លែងប្រាស្រ័យពីគោលការណ៍មិនជំនុំជម្រះទោសពីរដងចំពោះបទល្មើសតែមួយ ហើយនិងបង្ហាញពីបញ្ហាស្តីពីព្រះរាជក្រឹត្យលើកលែងទោស និងអនុគ្រោះទោសដល់លោក អៀង សារី។ នៅថ្ងៃស្អែក យើងខ្ញុំនឹងថ្លែងប្រាស្រ័យពីអាជ្ញាយុកាលនៃការរំលោភបំពានធ្ងន់ធ្ងរលើអនុសញ្ញាទីក្រុងហ្សឺណែវ ហើយនិងពីអាជ្ញាយុកាលចំពោះបទឧក្រិដ្ឋកម្មថ្នាក់ជាតិផងដែរ។

[១១:០៨:០០]

សំណើសុំការពិចារណាដោយផ្ទាល់មាត់ចំពោះបញ្ហាទាំងនេះនឹងធ្វើឡើងដោយសង្ខេបខ្លី ដោយហេតុថាយើងខ្ញុំបានកំណត់យ៉ាងច្បាស់លាស់រួចហើយពីគោលជំហររបស់យើងខ្ញុំនៅក្នុងសំណើសុំការពិចារណាជាលាយលក្ខណ៍អក្សររបស់យើងខ្ញុំ។ យ៉ាងណាក្តីយើងខ្ញុំមានការយកចិត្តទុកដាក់ថា នេះជាលើកទីមួយហើយដែលបញ្ហាទាំងនេះត្រូវបានថ្លែងប្រាស្រ័យដោយផ្ទាល់មាត់នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូងនេះ។ ហើយយើងខ្ញុំសូមថ្លែងអំណរគុណចំពោះឱកាសនេះ ដោយមានការអនុគ្រោះយោគយល់ពីលោកចៅក្រមប្រធាន លោក លោកស្រីចៅក្រមសមាជិក យើងខ្ញុំស្នើសុំជូនបទសង្ខេបខ្លីមួយដែលនឹងជាជំនួយដល់ការតាមដានកិច្ចការពារក្តីរបស់យើងខ្ញុំ។ ហេតុដូចនេះនៅក្នុងបណ្តឹងអញ្ញត្រកម្មនីមួយៗ ខ្ញុំបាទនឹងធ្វើការណែនាំបង្ហាញជូនជាសង្ខេបពីបញ្ហា និងចំពោះទឡ្ហីករណ៍នីមួយៗរបស់យើងខ្ញុំ។ រីឯសហភាតារបស់ខ្ញុំ ម៉ែខល កាណាវាស លោកនឹងបន្តធ្វើការវិភាគលម្អិតព្រមទាំងឆ្លើយនូវសំណួរទាំងឡាយដែលលោកប្រធាន និងលោក លោកចៅក្រមមាន។

[១១:០៩:៥៩]

ខ្ញុំបានធ្វើការកត់សម្គាល់នៅខណៈនេះផងដែរ ដែលយើងខ្ញុំសូមមេត្តាពិចារណាថា វាប្រហែលជាមានប្រយោជន៍និងមានប្រសិទ្ធភាពច្រើនប្រសិនបើសំណួរដែលលោក លោកស្រីនឹងដាក់មកលើយើងខ្ញុំធ្វើឡើងនៅចុងបញ្ចប់នៃផ្នែកនីមួយៗនៃសេចក្តីសន្និដ្ឋានរបស់យើងខ្ញុំ។ ការធ្វើបែបនេះជួយឲ្យអ្នកបកប្រែភាសាទីនេះមិនចាំបាច់ឆ្លាស់គ្នាជាប្រចាំ សម្រាប់បកប្រែភាសាឲ្យភាគីនៃរឿងក្តីនេះឡើយ។ ការធ្វើបែបនេះនឹងចៀសវាងពីស្ថានភាពដែលថា សំណួរត្រូវបានសួរមុនពេលដែលសំណួរណាមួយនោះ អាចត្រូវបានឆ្លើយនៅក្នុងដំណើរការទូទៅនៃសំណើសុំការពិចារណានេះ។

យើងខ្ញុំជឿជាក់ថា ទាំងអយ្យការទាំងមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី ក៏ប្រាថ្នាចង់ប្រកាន់យកដំណោះស្រាយរបៀបនេះដែរ ដើម្បីជាផលប្រយោជន៍ និងប្រសិទ្ធភាព។ ហើយនិងនៅក្នុងចេតនាចង់លើកទឡ្ហីករណ៍ទាំងអស់ដាក់នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូងផងដែរ។

ឥឡូវខ្ញុំបត់ចូលដល់ប្រធានបទទាក់ទងនឹងបណ្តឹងអញ្ញត្រកម្មរបស់យើងខ្ញុំ ស្តីពីគោលការណ៍មិនជំនុំជម្រះទោសពីរដងចំពោះបទល្មើសតែមួយ *ណាមិស អាទីដឹម* ។

[១១:១២:០៧]

ខ្ញុំបាទនឹងចាប់ផ្តើមដោយលើកបង្ហាញពីទឡ្ហីករណ៍របស់យើងខ្ញុំ ស្តីពីបញ្ហាទាក់ទងនឹងគោល-ការណ៍មិនជំនុំជម្រះទោសពីរដងចំពោះបទល្មើសតែមួយ។ ហើយសហភាតារបស់ខ្ញុំគឺលោក ម៉ែខល

កាណាវាស នឹងបន្តដោយការពន្យល់លម្អិតពិស្តារបន្ថែមទៀតអំពីទឡ្ហីករណ៍របស់យើងខ្ញុំ ហើយលោក នឹងថ្លែងប្រាស្រ័យពីសំណួរទាំងឡាយណាដែលលោក លោកស្រីអាចនឹងមាន។ អនុលោមតាមគោល-ការណ៍មិនជំនុំជម្រះទោសពីរដងចំពោះបទល្មើសតែមួយគឺថា បុគ្គលម្នាក់មិនត្រូវយកមកជំនុំជម្រះទោសជាថ្មីម្តងទៀតចំពោះអំពើដដែល ដែលពីមុនមកជននោះត្រូវបានតុលាការសម្រេចសេចក្តីឲ្យរួចខ្លួន ឬក៏ឲ្យជាប់ទោសរួចហើយនោះឡើយ។

[១១:១៣:២០]

លោក អៀង សារី ត្រូវបានជំនុំជម្រះ និងផ្តន្ទាទោសដោយកំបាំងមុខ កាលពីខែសីហា ឆ្នាំ១៩៧៩ ពីបទប្រព្រឹត្តអំពើប្រល័យពូជសាសន៍ បន្ថែមនិងបទល្មើសដទៃៗទៀតច្រើនទៀត។ គាត់ត្រូវបានតុលាការកាត់ទោសប្រហារជីវិតបន្ថែមនិងបទល្មើសដទៃៗទៀតជាច្រើន។ ហើយបង្គាប់ឲ្យរឹបអូសទ្រព្យសម្បត្តិទាំងអស់របស់គាត់។ ការយកលោក អៀង សារី មកកាត់ទោសសាជាថ្មីទៀត គឺរំលោភបំពានលើគោលការណ៍មិនជំនុំជម្រះទោសពីរដងចំពោះបទល្មើសតែមួយ ដែលមានចែងក្នុងច្បាប់ជាតិរបស់កម្ពុជា កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋនិងសិទ្ធិនយោបាយ ដែលក្នុងនោះប្រទេសកម្ពុជាជាភាគីមួយ និងវិធាននីតិវិធីដែលបានបង្កើតឡើង ក្នុងកម្រិតអន្តរជាតិក្នុងការកាត់ទោសលោក អៀង សារី សាជាថ្មីនៅអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាយើងនេះ។ សូមអនុញ្ញាតឲ្យយើងខ្ញុំពិចារណាពីចំណុចនីមួយៗ ខាងលើនេះ។

[១១:១៥:០០]

ទីមួយ ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា មាត្រា៧ នៃក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា តម្រូវឲ្យបណ្តឹងអាជ្ញាត្រូវផុតរលត់ខណៈដែលបណ្តឹងនោះស្ថិតក្នុងលក្ខខណ្ឌអាជ្ញាអស់ជំនុំ ឬអាចនិយាយម្យ៉ាងទៀតថា ខណៈដែលបណ្តឹងអាជ្ញានោះត្រូវបានដោះស្រាយជាស្ថាពររួចហើយដោយសេចក្តីសម្រេចរបស់តុលាការ។ ករណីរបស់លោក អៀង សារី គឺអាជ្ញាអស់ជំនុំ។ ការជំនុំជម្រះក្តីនៅពេលបច្ចុប្បន្ននេះទាក់ទងនឹងអំពើដែលត្រូវបានដោះស្រាយយ៉ាងច្បាស់លាស់រួចហើយដោយសេចក្តីសម្រេចរបស់តុលាការ កាលពីឆ្នាំ១៩៧៩។

ដូច្នេះមាត្រា៧ បានរារាំងការកាត់ទោសនាពេលបច្ចុប្បន្ននេះប្រឆាំងនឹងលោក អៀង សារី។ មាត្រា១២ នៃក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជាចែងថា ដោយអនុវត្តតាមគោលការណ៍អាជ្ញាអស់ជំនុំ ជនណាដែលត្រូវបានតុលាការសម្រេចឲ្យរួចខ្លួនជាស្ថាពរហើយ ជននោះមិនអាចត្រូវ

បានចោទប្រកាន់ទោសទៀតទេ ចំពោះអំពើដដែល ទោះបីជាក្រោមការកំណត់បទល្មើសថ្មីផ្សេងក្ដី។ មាត្រា១២ មិនបានកំណត់ពីអាជ្ញាអស់ជំនុំសម្រាប់គោលបំណងនៃមាត្រា៧ ឬដាក់កំហិតដល់ការអនុវត្តរបស់វាឡើយ។ ផ្ទុយទៅវិញមាត្រានេះធានាថា គោលការណ៍អាជ្ញាអស់ជំនុំត្រូវបានយកមកបកស្រាយទូលំទូលាយដើម្បីក្ដោបស្រូបបញ្ចូលនូវការកាត់ក្ដីឲ្យរួចខ្លួន និងក្ដោបស្រូបបញ្ចូលនូវស្ថានភាពនានា ដែលជនជាប់ចោទត្រូវបានចោទប្រកាន់ទោស ពីអំពើប្រព្រឹត្តដដែលដូចក្នុងករណីមុនដែរ ប៉ុន្តែបណ្ដឹងចោទប្រកាន់បែបនេះ ស្ថិតក្រោមការកំណត់បទល្មើសផ្សេង។ វាមិនចាំបាច់ដែលត្រូវបកស្រាយមាត្រា១២ នៅក្នុងករណីនេះ ពីព្រោះការជំនុំជម្រះក្ដីលោក អៀង សារី នៅពេលបច្ចុប្បន្ននេះត្រូវបានហាមឃាត់ដោយផ្អែកលើគោលការណ៍ទូលំទូលាយជាងនេះ ដែលមាននៅក្នុងមាត្រា៧ នៃក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា។

[១១:១៨:៤៣]

លោកប្រធាន លោក លោកស្រីចៅក្រមជាទីគោរព! ទោះបីជាអង្គជំនុំជម្រះសាលាដំបូងយល់ឃើញថា វាចាំបាច់ដែលត្រូវអនុវត្តមាត្រា១២ រួមជាមួយនឹងមាត្រា៧ក្ដី ក៏មាត្រា១២នេះចាំបាច់ត្រូវតែបានបកស្រាយ ដើម្បីអនុវត្តចំពោះជនណាដែលត្រូវបានតុលាការកាត់ក្ដីឲ្យជាប់ទោសជាស្ថាពរ ក៏ដូចជាជនណាដែលត្រូវបានតុលាការសម្រេចឲ្យរួចខ្លួនជាស្ថាពរផងដែរ។ ព្រោះបើកំណត់ត្រឹមតែជនណាដែលត្រូវបានតុលាការសម្រេចឲ្យរួចខ្លួនជាស្ថាពរនឹងនាំឲ្យមានលទ្ធផលដែលមិនសមហេតុផល។ គោលបំណងនៃគោលការណ៍មិនជំនុំជម្រះទោសពីរដងចំពោះបទល្មើសតែមួយ ត្រូវយកមកអនុវត្តដោយស្មើភាពគ្នា ទោះវាស្ថិតនៅក្នុងករណីណាក្ដីក្នុងចំណោមនេះ។

[១១:២០:០៦]

គោលការណ៍មិនជំនុំជម្រះទោសពីរដងចំពោះបទល្មើសតែមួយនេះ មានបំណងដើម្បីការពារស្ថានភាពនៃសាលក្រមសម្រេចក្ដីចុងក្រោយរបស់តុលាការ។ នេះមានន័យថា ប្រសិនណារឿងក្ដីមួយត្រូវបានតុលាការដោះស្រាយចប់សព្វគ្រប់ហើយ រឿងក្ដីដដែលនោះមិនត្រូវបើកសំណុំរឿងសាឡើងវិញឡើយ ព្រោះវានឹងធ្វើឲ្យអន្តរាយធ្ងន់ធ្ងរដល់ការគោរពដំណើរការនីតិវិធីតុលាការ និងប្រព័ន្ធតុលាការជាទូទៅ។ តម្រូវការឲ្យ អ.វ.ត.ក បំពេញកិច្ចជាតុលាការគំរូសម្រាប់កម្ពុជាដោយការប្រកាន់ខ្ជាប់នូវនីតិវិធីគឺ-- សូមទោស នូវនីតិរដ្ឋគឺវិធាននៃច្បាប់ និងគោលការណ៍នីត្យានុកូលភាព ហើយត្រូវបង្កើនការគោរពចំពោះតុលាការ និងដំណើរការនីតិវិធីតាមផ្លូវតុលាការ។ នោះការតម្រូវបែបនេះ នាំឲ្យអង្គជំនុំជម្រះ

វិសាមញ្ញក្នុងតុលាការកម្ពុជា ត្រូវគោរពនិងគួរអនុវត្តគោលការណ៍មិនជំនុំជម្រះទោសពីរដងចំពោះបទល្មើសតែមួយ។

[១១:២១:៥៩]

គោលបំណងមួយទៀតនៃគោលការណ៍មិនជំនុំជម្រះទោសពីរដងចំពោះបទល្មើសតែមួយ គឺដើម្បីការពាររារាំងបុគ្គលកុំឲ្យទទួលរងនូវភាពលំបាកធុញថប់ តានតឹងផ្លូវចិត្ត ខាងអារម្មណ៍ចំពោះរាងកាយ និងផ្នែកថវិកាដែលរួមពាក់ព័ន្ធនឹងការជំនុំជម្រះក្ដីពីរដងនោះ។ គោលការណ៍នេះមិនតម្រូវតែអនុវត្តនៅពេលដែលជនជាប់ចោទត្រូវបានតុលាការកាត់ឲ្យរួចខ្លួនប៉ុណ្ណោះទេ។ ភាពថប់អារម្មណ៍ និងភាពធុញទ្រាន់ដែលបង្កឡើងការ-- ដោយការកាត់ទោសច្រំដែលប៉ះពាល់ដល់គ្រួសារ សាក្សី និងសូម្បីដល់ជនរងគ្រោះថែមទៀតផង។ ហើយវាទំនងជានឹងធ្វើឲ្យមានភាពធ្ងន់ធ្ងរឡើងថែមទៀត ដោយសារចំណាប់អារម្មណ៍ពីប្រព័ន្ធផ្សព្វផ្សាយ។

គោលបំណងទាំងនេះនៃគោលបំណងមិនជំនុំជម្រះទោសពីរដង ចំពោះបទល្មើសតែមួយបង្ហាញថា វានឹងមិនសមហេតុសមផលឡើយដែលត្រូវកំណត់គោលការណ៍មិនជំនុំជម្រះទោសពីរដងចំពោះបទល្មើសតែមួយ ដែលបានផ្ដល់ឲ្យដោយក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ចំពោះតែជនណាដែលត្រូវបានតុលាការកាត់ឲ្យរួចខ្លួនជាស្ថាពរ។ បន្ទាប់មក សូមអនុញ្ញាតឲ្យយើងខ្ញុំពិចារណាពីកតិកាសញ្ញាអន្តរជាតិ ស្ដីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ។ មាត្រា១៤(៧) នៃកតិកាសញ្ញាអន្តរជាតិស្ដីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយចែងថា គ្មានជនណាម្នាក់ត្រូវយកមកចោទប្រកាន់ ឬយកមកផ្ដន្ទាទោសសាជាថ្មីឡើយ ចំពោះបទល្មើសដែលបានផ្ដន្ទាទោសជាស្ថាពរ ឬបានលើកលែងទោសដោយស្របច្បាប់ និងនីតិវិធីព្រហ្មទណ្ឌរបស់រដ្ឋនីមួយៗរួចហើយ។

[១១:២៤:៥៣]

មាត្រានេះអាចអនុវត្តបាននៅអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាយើង និងរារាំងការកាត់ទោសនៅពេលបច្ចុប្បន្ននេះប្រឆាំងនឹងលោក អៀង សារី។ ពីព្រោះកម្ពុជាជាភាគីមួយនៃកតិកាអនុសញ្ញានេះ។ ហើយរដ្ឋធម្មនុញ្ញរបស់កម្ពុជាប្រគល់អាណត្តិឲ្យកម្ពុជាគោរពកតិកាសញ្ញា និងអនុសញ្ញានានាដែលទាក់ទងនឹងសិទ្ធិមនុស្ស ដែលក្នុងនោះកម្ពុជាគឺជារដ្ឋភាគី។ ជួនកាលមានបញ្ហាមួយចំនួន ដែលអនុវត្តបទប្បញ្ញត្តិនេះ នៅពេលដែលតុលាការនៃរដ្ឋមួយត្រូវបានស្នើសុំឲ្យទទួលស្គាល់សាលក្រមពីមុនរបស់តុលាការក្នុងរដ្ឋមួយផ្សេងទៀត។ ពេលខ្លះគេយល់ឃើញថា បទប្បញ្ញត្តិនេះមិនត្រូវអនុវត្តក្នុង

ស្ថានភាពបែបនេះឡើយ។ យ៉ាងណាក្តីក៏ស្ថានភាពបែបនេះ មិនកើតមាននៅក្នុងករណីនេះឡើយ។ ការជំនុំជម្រះក្តីកាលពីឆ្នាំ១៩៧៩ ត្រូវបានប្រព្រឹត្តឡើងនៅក្នុងប្រទេសកម្ពុជា ដោយតុលាការកម្ពុជា ហើយអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាក៏ជាតុលាការកម្ពុជាដែរ។ អ.វ.ត.ក មិនដូចតុលាការចំពោះកិច្ចដទៃៗទៀត ដែលមិនត្រូវកំណត់អាណ្តិតឲ្យគោរពកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយឡើយ។

នៅទីបញ្ចប់សូមអនុញ្ញាតឲ្យខ្ញុំបាទ ថ្លែងប្រាស្រ័យពីវិធាននីតិវិធីដែលបានបង្កើតឡើងនៅកម្រិតអន្តរជាតិ គេត្រូវការលើកយកប្រធាននីតិវិធីដែលបង្កើតឡើងនៅកម្រិតអន្តរជាតិមកពិចារណាតែល្ពឹកណានីតិវិធីដែលមានស្រាប់មិនអាចដោះស្រាយបាននូវបញ្ហាជាក់លាក់ណាមួយប៉ុណ្ណោះ ឬតែល្ពឹកណាប្រសិនបើមានភាពមិនច្បាស់លាស់ទាក់ទងនឹងការបកស្រាយ ឬការអនុវត្ត ឬប្រសិនណាមានចំណោទបញ្ហាមួយទាក់ទងនឹងភាពស៊ីសង្វាក់គ្នាជាមួយនឹងបទដ្ឋានអន្តរជាតិតែប៉ុណ្ណោះ។

[១១:២៨:១៧]

នេះមិនមែនជាករណីចោទនៅក្នុងស្ថានភាពបច្ចុប្បន្ននេះឡើយ។ ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជណាចក្រកម្ពុជា និងកតិកាសញ្ញាអន្តរជាតិ ស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ អាចល្មមគ្រប់គ្រាន់និងដោះស្រាយបញ្ហានេះ។ ហើយក៏គ្មានភាពមិនជាក់លាក់ច្បាស់លាស់ទាក់ទងនឹងការបកស្រាយ ឬការអនុវត្តនីតិវិធី និងកតិកាសញ្ញានេះឡើយ។ ទាំងក្រមនីតិវិធីព្រហ្មទណ្ឌ និងកតិកាសញ្ញាអន្តរជាតិ នេះគឺមានភាពច្បាស់លាស់ ហើយអាចអនុវត្តបាន។ ទោះជាយ៉ាងនេះក្តីប្រសិនបើអង្គជំនុំជម្រះសាលាដំបូងសម្រេចថា ខ្លួនត្រូវតែពិចារណាពីវិធាននីតិវិធីដែលបង្កើតឡើងក្នុងកម្រិតអន្តរជាតិនោះ អង្គជំនុំជម្រះសាលាដំបូងត្រូវតែអនុវត្តតាមគោលការណ៍ណែនាំក្នុងលក្ខន្តិកៈរបស់តុលាការព្រហ្មទណ្ឌអន្តរជាតិអាយ.ស៊ី.ស៊ី។ ដោយហេតុថា លក្ខន្តិកៈនេះត្រូវបានផ្តល់សច្ចាប័នដោយរដ្ឋជាភាគីមួយចំនួនធំ ហើយវាក៏តំណាងឲ្យការយល់ស្របគ្នាជាអន្តរជាតិច្រើនជាងលក្ខន្តិកៈរបស់តុលាការព្រហ្មទណ្ឌដទៃៗទៀត។

[១១:៣០:០៥]

លក្ខន្តិកៈរបស់តុលាការព្រហ្មទណ្ឌអន្តរជាតិនេះ មានចែងពីបទប្បញ្ញត្តិ មិនជំនុំជម្រះទោសពីរដងចំពោះបទល្មើសតែមួយ ដែលនឹងៗរារាំងការជំនុំជម្រះក្តីប្រឆាំងនឹងលោក អៀង សារី នៅពេលបច្ចុប្បន្ននេះ។

សរុបសេចក្តីមកក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា កតិកាសញ្ញាអន្តរជាតិស្តីពី

សិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ ហើយនិងការពិចារណាពីវិធាននីតិវិធីអន្តរជាតិ ទាំងអស់សុទ្ធតែតម្រូវឲ្យអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាលុប និងបញ្ចប់ការកាត់ទោសនាពេលបច្ចុប្បន្ននេះ ប្រឆាំងនឹងលោក អៀង សារី ។ ហើយត្រូវយល់ឃើញថា អ.វ.ត.ក មិនមានយុត្តាធិការក្នុងការកាត់ទោសលោក អៀង សារី ចំពោះបទឧក្រិដ្ឋដែលបានចោទប្រកាន់ដោយផ្អែកលើមូលដ្ឋាននៃគោលការណ៍មិនជំនុំជម្រះទោសពីរដង ចំពោះបទល្មើសតែមួយ។ សំណើ និងសេចក្តីសន្និដ្ឋានរបស់ខ្ញុំបាទ ចប់តែត្រឹមនេះ ហើយសហភាតារបស់ខ្ញុំគឺលោក ម៉ៃខល កាណាវាស ដែលជាសហមេធាវីរបស់លោកអៀង សារី ដែរ នឹងឡើងមកថ្លែងប្រាស្រ័យបន្តលម្អិតពីបញ្ហាអនុញ្ញត្រកម្មទាំងឡាយដែលខ្ញុំបាទ ទើបតែបានលើក។

សូមអរគុណលោកប្រធាន លោក លោកស្រីចៅក្រមដែលបានយកចិត្តទុកដាក់ស្តាប់ទឡ្ហីករណ៍របស់ខ្ញុំបាទ។

[១១:៣២:០៧]

**លោក ម៉ៃខល កាណាវាស៖**

សូមគោរពលោកចៅក្រម សូមគោរពអ្នកទាំងគ្នាដែលមានវត្តមាននៅជុំវិញសវនាការនេះ។ ខ្ញុំព្យាយាមធ្វើនូវសេចក្តីថ្លែងខ្លីទេ មិននិយាយឡើងវិញនូវអ្វីដែលសហភាតារបស់ខ្ញុំបានលើកឡើងទេ។ ហើយយើងបានសរសេរនៅក្នុងសារណារបស់យើងខ្ញុំអាចច្រើនហើយដែរ អំពីអំណះអំណាង។ អង្គជំនុំជម្រះសាលាដំបូងស្នើសុំឲ្យយើងខ្ញុំលើកឡើងនូវបញ្ហាចំនួនពីរដែលជាបញ្ហាសំខាន់ ដែលជាបញ្ហាបន្ថែមទៀតនោះ។ ទីមួយ គឺទាក់ទងទៅនឹងសេចក្តីសម្រេចរបស់អង្គបុរេជំនុំជម្រះ ហើយមួយទៀតទាក់ទងទៅនឹងការពិចារណាថា តើសវនាការនឹងសេចក្តីសម្រេចរបស់តុលាការឆ្នាំ១៩៧៩ ដោយតុលាការបដិវត្តន៍ប្រជាជនកម្ពុជាហ្នឹង បានប្រព្រឹត្តទៅតាមបទដ្ឋានសវនាការយុត្តិធម៌ត្រឹមត្រូវទៅតាមក្របខ័ណ្ឌច្បាប់ដែលខ្លួនបានឈរលើមូលដ្ឋាននៅក្នុងការកាត់សេចក្តីនេះ។ ដូច្នេះខ្ញុំគិតថា វាជា-- ខ្ញុំនឹងដោះស្រាយទៅលើបញ្ហាទីពីរមុន មុនពេលដែលខ្ញុំត្រឡប់ទៅនិយាយពីអំពីបញ្ហាសេចក្តីសម្រេចទាំងមូលរបស់អង្គបុរេជំនុំជម្រះកន្លងមក។

[១១:៣៣:២៥]

អ៊ីចឹងថាតើសវនាការឆ្នាំ១៩៧៩ គឺជាសវនាការមួយដែលត្រឹមត្រូវ ឬក៏យ៉ាងណា យ៉ាងហោចណាស់ក៏ថា បើយើងពិនិត្យមើលទៅលើក្របខ័ណ្ឌច្បាប់ដែលមានអាទិភាពនៅពេលនោះ។ ថាតើមាននរណាម្នាក់នៅក្នុងចំណោមយើងទាំងអស់គ្នានៅក្នុងតុលាការនេះ នៅក្នុងការទទួលបានសវានាការបែប

នោះឬទេ? ខ្ញុំអាចសួរជាសំណួរនេះ ចម្លើយប្រាកដជាថាអត់ទេ យើងមិនចង់បានសវនាការនេះទេ។ ថាតើសវនាការហ្នឹងល្អឥតខ្ចោះទេ? ថាអត់ទេ គេធ្វើទៅតាមដំណើរការនីតិវិធី ដែលវាមាននៅពេលនោះ។ ប៉ុន្តែចំណុចសំខាន់ជាងនោះទៅទៀត ខ្ញុំគិតថា វាគឺជាបញ្ហាមួយដែលយើងចាំបាច់ត្រូវតែធ្វើការឆ្លើយតប ហើយខ្ញុំសូមដាក់ជូននូវអង្គជំនុំជម្រះ ថាបញ្ហានេះមិនទាន់បានលើកឡើងពីមុនទេថា ប្រសិនបើលោក អៀង សារី គាត់បាន ត្រូវបានគេកាត់ទោស ឬក៏ត្រូវបានគេចាប់ឃុំឃាំងនោះ គឺថាគាត់ត្រូវបានគេសម្លាប់បាត់ហើយ ពីព្រោះគាត់ត្រូវបានគេកាត់ទោសប្រហារជីវិត។ ប៉ុន្តែ ចម្លើយរឿងបញ្ហាហ្នឹងគឺថាអាចធ្វើបាន។ អ៊ីចឹងគឺយើងត្រូវតែរកមកបង្ហាញថា តើការកាត់សេចក្តីនោះត្រូវបានគេពិចារណាថាជាការកាត់សេចក្តីដ៏ត្រឹមត្រូវ ឬក៏អត់? ហើយជាសេចក្តីសម្រេចស្ថាពរឬក៏យ៉ាងណា? ព្រះរាជអាជ្ញាឬក៏អង្គបុរេជំនុំជម្រះ ឬក៏អង្គការសហប្រជាជាតិ មុនពេលលោក អៀង សារី បានបង្ហាញខ្លួនហ្នឹងគឺថាគ្មាននរណាម្នាក់ចេញមកនិយាយថាសវនាការបែបនុ៎ង គឺជាសវនាការមួយគ្រាន់តែជាសវនាការឲ្យល្អមើលទេ! ហើយការកាត់សេចក្តីនោះទៀត មិនត្រូវបានគេអនុវត្តទេ បើសិនបើលោក អៀង សារី ត្រូវបានគេចាប់ឃុំខ្លួនរហូតទៅដល់ពេលដែលគាត់ហ្នឹងត្រូវបានគេអនុញ្ញាតឲ្យទទួលបាននូវការលើកលែងទោស និងការអនុគ្រោះទោសពីព្រះមហាក្សត្រ។ ហើយតាំងពីនោះមក គឺរដ្ឋធម្មនុញ្ញត្រូវបានផ្លាស់ប្តូរខ្លះហើយ ប៉ុន្តែអង្គហេតុវានៅតែនៅដដែល ថាបើទោះបីជាគាត់ហ្នឹងត្រូវបានគេឃាត់ខ្លួន បន្ទាប់ពីមានការកែប្រែទៅលើរដ្ឋធម្មនុញ្ញនេះក៏ដោយ ការកាត់ទោសប្រហារជីវិតនោះនឹងអាចផ្ទេរទៅជាការឃុំខ្លួនពេញមួយជីវិតទៅវិញ ការជាប់ឃុំមួយជីវិតទៅវិញ។

[១១:៣៥:៣៣]

ដូច្នេះ សវនាការនេះគឺយើងឃើញថា អ្វីវាមាននូវការកំហិតមួយដែលថា ថាតើយើងគិតថាយ៉ាងដូចម្តេចជាសវនាការដែលត្រឹមត្រូវហ្នឹង បើយើងប្រៀបធៀបវាជាមួយនឹងសវនាការដែល សាដាំ ហ៊ូសេន គាត់បានទទួលនោះ គឺថាជាការពិត យើងឃើញថាវាគឺជាសវនាការមួយដែលមិនបានល្អទេ។ បើយើងមើលអំពីការពិចារណាពីសវនាការលើ សាដាំ ហ៊ូសេន គេគិតថាវាមិនស្មើភាព វាមិនយុត្តិធម៌ចំពោះគាត់ទេ។ ប៉ុន្តែគាត់ត្រូវបានគេកាត់ទោសប្រហារជីវិត ហើយគាត់គិតថា គាត់ត្រូវបានគេប្រហារជីវិតមុនពេលដែលគាត់ទៅដល់កាត់សេចក្តីគាត់នៅក្នុងតុលាការកំពូល។

ដូច្នេះ យើងត្រូវពិនិត្យមើលទៅលើថាតើ ក្របខ័ណ្ឌច្បាប់នៅពេលនោះយ៉ាងដូចម្តេច? ហើយថាតើដំណើរការសវនាការហ្នឹងយ៉ាងដូចម្តេច? ហើយចម្លើយទៅនឹងសំណួរនោះ គឺថាវាអាចជាសវនាការ

មួយដែលល្អដែរ ប្រសិនបើការកាត់សេចក្តីនោះត្រូវបានគេយកទៅអនុវត្ត។ ដូច្នេះហើយបានជាខ្ញុំលើកឡើងនូវទឡ្ហីករណ៍របស់ខ្ញុំមួយទៀត ហើយគឺថាលោក អៀង សារី គាត់ធ្វើការចរចាជាមួយនឹងរាជរដ្ឋាភិបាល ហើយរដ្ឋាភិបាលបានមកជួបជាមួយនឹងលោក អៀង សារី ហើយនិងសូមឲ្យមានការផ្តល់នូវការលើកលែងទោស និងការអនុគ្រោះទោស ពីការកាត់សេចក្តីនៅក្នុងឆ្នាំ១៩៧៩។ ហើយការអនុគ្រោះទោស និងការលើកលែងទោសនោះត្រូវបានគេអនុវត្ត។

[១១:៣៦:៤៩]

ខ្ញុំគិតថា ខ្ញុំមិនមានអ្វីដែលត្រូវបន្ថែមទៀតទេ ទៅលើចំណុចនេះ ហើយខ្ញុំនឹងទទួលសំណួរអំពីលោកចៅក្រម។ ខ្ញុំយល់ថា លោកព្រះរាជអាជ្ញាបានលើកឡើងថា នៅក្នុងហ្នឹងគឺជាសវនាការចុងក្រោយនៅក្នុងឆ្នាំ១៩៧៩ ហ្នឹង វាអត់មានអង្គជំនុំជម្រះអ្វីបន្ថែមទៀតទេ។ ហើយគាត់ត្រូវបានគេកាត់ទោសកំបាំងមុខនៅពេលនោះ ហើយដូចតុលាការនៅ លីបង់ គេផ្តល់ឲ្យ អនុញ្ញាតឲ្យមានការកាត់ទោសកំបាំងមុខ ហើយប៉ុន្តែប្រព័ន្ធនេះគឺថា ផ្តល់ឲ្យមាននូវការកាត់ទោសកំបាំងមុខនៅពេលហ្នឹង។ ហើយរហូតមកដល់ពេលបច្ចុប្បន្ននេះ ខ្ញុំអាចនិយាយបានថានៅក្នុងប្រទេសកម្ពុជា ការកាត់ទោសកំបាំងមុខហ្នឹង អាចប្រព្រឹត្តទៅបាន វាអត់មានជាការតម្រូវទៅតាមផ្លូវច្បាប់ដែលត្រូវតែមានវត្តមានរបស់ជនជាប់ចោទនៅមុខនោះទេ បើតាមមើលទៅលើវិធាននីតិវិធីហ្នឹង ដែលសវនាការអាចធ្វើទៅបាន។

អ៊ីចឹងខ្ញុំមិនចាំបាច់លើកឡើងអំពីថា ថាតើជនជាប់ចោទហ្នឹងគាត់ចាំបាច់ត្រូវសម្រេចថាតើ តើចង់ឲ្យមានសវនាការឡើងវិញ ឬក៏មិនមាននោះទេ។ ដូច្នេះ ខ្ញុំយល់ថាខាងអយ្យការ គាត់បានលើកឡើងនូវមាត្រាមួយចំនួន នៅក្នុងក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា ហើយយើងខ្ញុំសុំលើកឡើងថា បើសិនយើងក្រឡេកមើលមាត្រា ៣៦៦ និង ៣៦៨ ហើយនិង ៤៨៩ ហើយនិង ៤៩៣ យើងនឹងអាចឃើញច្បាស់ថា ព្រះរាជអាជ្ញាហ្នឹងមានការយល់ច្រឡំទៅលើចំណុចមួយចំនួនដែលថាយើងអាចធ្វើទៅបានឬអត់ នីតិវិធីនៅក្រោមក្រមនីតិវិធីព្រហ្មទណ្ឌនៅព្រះរាជាណាចក្រកម្ពុជា។ ប៉ុន្តែយើងមិនចាំបាច់និយាយដល់ដែលថា ក្រមនីតិវិធីព្រហ្មទណ្ឌនៅពេលនោះមិនទាន់បានមានអត្ថិភាព ក៏ដោយ។

ហើយដូច្នេះ ខ្ញុំសូមសង្ខេបតែប៉ុណ្ណេះ លើកលែងតែលោកអង្គចៅក្រម លោកមានជាសំណួរអីចំពោះខ្ញុំ ហើយបើសិន-- ដោយសារតែមិនមានសំណួរទេ ខ្ញុំសូមបន្តទៅបញ្ហាទីពីររបស់ខ្ញុំ។

[១១:៣៨:៤៤]

ទឡ្ហីករណ៍របស់ខ្ញុំហាក់បីដូចជារាងដាច់ៗពីគ្នា វាមិនមិនទំនាក់គ្នាទេ ដូចសហសេវិករបស់ខ្ញុំ

បានលើកឡើង ពីព្រោះខ្ញុំ ខ្ញុំចង់លើកឡើងតែទៅលើបញ្ហាមួយចំនួនដែលសហភាតារបស់ខ្ញុំមិនបានលើកឡើងនៅក្នុងសេចក្ដីថ្លែងរបស់គាត់។

ដូច្នេះ ខ្ញុំចង់ធ្វើការកំហិតទៅលើការលើកឡើងរបស់ខ្ញុំ តែចំពោះបញ្ហាដែលព្រះរាជអាជ្ញាបានលើកឡើងជាការឆ្លើយតបតែប៉ុណ្ណោះ។ ដូច្នេះ បានន័យថា ការកត់សម្គាល់របស់ខ្ញុំហ្នឹង គឺជាឆ្លើយតបទៅលើអ្វីដែលព្រះរាជអាជ្ញានឹងមាន ហើយខ្ញុំជឿជាក់ថា ព្រះរាជអាជ្ញាក៏គាត់មាននូវឱកាសនៅក្នុងការឆ្លើយតបទៅលើអ្វីដែលយើងខ្ញុំបានលើកឡើងវិញដែរ។

ពាក់ព័ន្ធទៅនឹង គោលការណ៍នៃការមិនកាត់ទោសពីរដង ខ្ញុំគិតថា ខ្ញុំមិនចាំបាច់និយាយអំពីភាពជាក់លាក់របស់វា គោលបំណង ឬក៏បំណងរបស់វាទេ។ ព្រះរាជអាជ្ញា គឺគាត់ក្នុងទឡ្ហីករណ៍ទាំងមូលរបស់ខ្លួនហ្នឹង បើសិនជាខ្ញុំអាចនិយាយចំពោះព្រះរាជអាជ្ញាបាន គឺថាគាត់ផ្អែកទៅលើថា គាត់ក្រឡេកមើលទៅលើមាត្រាទី១២ ជាជាងមាត្រាទី៧ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ហើយពួកគាត់បានលើកឡើងថា ខ្ញុំគិតថាក្នុងកថាខណ្ឌទី១១ ទាក់ទងទៅនឹងចម្លើយ ទៅនឹងសេចក្ដីសន្និដ្ឋានរបស់យើង។ មាត្រាទី៧ គឺបានលើកឡើងអំពីអាជ្ញាអស់ជំនុំ-- មាត្រា១២ សូមទោស អ៊ីចឹង នៅក្នុងមាត្រាទី៧ នេះក៏មានការពាក់ព័ន្ធអំពីចំណុចហ្នឹងដែរ ហើយយើងបានលើកឡើងថា នៅក្នុងមាត្រាទី១២ គឺគាត់ពង្រីកបន្ថែមទៅលើអ្វីដែលជាវិសាលភាពនៅក្នុងមាត្រាទី៧។ ដូច្នេះ យើងអាចលើកឡើងថា បើយើងធ្វើការវិភាគវែកញែកអំពីមាត្រាទាំងពីរនេះជាមួយគ្នាទៅ ដូចដែលបានលើកឡើងដោយលោក អាង ឧត្ដម។ យើងផ្អែកទៅលើមាត្រាទី៧ និងមាត្រាទី-- ហើយយើងនឹងលើកឡើងថា យើងមិនចាំបាច់ ក្រឡេកមើលមាត្រាទី១២ទេ យើងមើលតែមាត្រាទី៧ គឺគ្រប់គ្រាន់ហើយ។

អ៊ីចឹង គឺព្រះរាជអាជ្ញា បើយើងអាចលើកឡើងថា ព្រះរាជអាជ្ញាមិនត្រឹមត្រូវទេ បើសិនជាគាត់លើកឡើងថា យើងបានទទួលនូវខ្លឹមសារនៃមាត្រាទី១២ ជាជាងមាត្រាទី៧ ដោយសារតែយើងមិនបានលើកឡើងអំពីបញ្ហាហ្នឹងច្បាស់។ បើអ្នកទាំងអស់គ្នាឃើញ នៅកថាខណ្ឌទី១១ ហើយនៅក្នុងហ្នឹងនៅក្នុងសេចក្ដីសន្និដ្ឋានរបស់ព្រះរាជអាជ្ញា។

[១១:៤១:១២]

ព្រះរាជអាជ្ញា គឺគាត់បានលើកឡើងទាំងខុសជំហរមួយដែលថា នៃមាត្រាទី១២ហ្នឹង ហើយបញ្ហានេះ គឺជាជំហរមួយដែលត្រូវបានគេទទួលដោយអង្គបុរេជំនុំជម្រះរួចហើយ។ ហើយព្រះរាជអាជ្ញាក៏បានលើកឡើងកថាខណ្ឌ១២០ នៃសេចក្ដីសម្រេចរបស់អង្គបុរេជំនុំជម្រះ អំពីបណ្ដឹងឧទ្ធរណ៍ប្រឆាំង

ជាមួយដីកាដំណោះស្រាយ។

ដូច្នេះ គឺយើងផ្អែកទៅលើមាត្រាទី១២០ នៅក្នុងការគាំទ្រទៅលើការបញ្ជាក់អះអាងរបស់ព្រះរាជអាជ្ញា។ ឥឡូវកថាខណ្ឌនេះបានលើកឡើងនូវមាត្រាទី១២ ប៉ុន្តែគេអត់បានរកឃើញនូវរបកគំហើញអ្វីមួយទាក់ទងទៅនឹងទំនាក់ទំនងរបស់វាជាមួយនឹងមាត្រាទី៧។ ហើយជាការពិត នេះគឺជាអ្វីដែលអង្គបុរេជំនុំជម្រះបានលើកឡើង ហើយខ្ញុំគ្រាន់តែលើកឡើងដោយសង្ខេប។ អង្គបុរេជំនុំជម្រះបាននិយាយថា មាត្រាទី១២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ គឺដូចបានលើកឡើងនៅក្នុងកថាខណ្ឌទី៤៥ គឺអាចត្រូវបានគេចាត់ទុកថា ជាឧទាហរណ៍មួយនៃការអនុវត្តនូវលទ្ធិមួយនៃ ឬក៏ទ្រឹស្តីមួយ នៃទ្រឹស្តីអាជ្ញាអស់ជំនុំនេះ។

នេះគ្រាន់តែជាឧទាហរណ៍មួយ គឺថាគេផ្អែកទៅលើហ្នឹង ហើយយើងគួសបញ្ជាក់អំពីចំណុចនេះ ពីព្រោះយើងខ្ញុំជឿជាក់ថា នៅទីនេះ គឺព្រះរាជអាជ្ញាគាត់មិនបានចាត់ថ្នាក់ឲ្យបានត្រឹមត្រូវ ឬក៏គាត់មិនបានរៀប បង្ហាញអំពីជំហរដែលអង្គបុរេជំនុំជម្រះហ្នឹងបានសម្រេច។

ដូច្នេះ ខ្ញុំមិនចង់និយាយអំពីបញ្ហានៃការវាយប្រហារទៅបុគ្គលដែលបានលើកឡើងនៅពេលនោះទេ ប៉ុន្តែខ្ញុំជឿជាក់ថា ហ្នឹងគ្រាន់តែជាការផ្ទុះបញ្ចាំងអំពីជំហរមួយនៃការយល់ខុសរបស់ព្រះរាជអាជ្ញាអំពីអ្វីដែលអង្គបុរេជំនុំជម្រះបានសម្រេច។

[១១:៤៣:០៧]

ហើយនៅក្នុងមាត្រាទី៧នេះ គឺថាវាមិនអាចត្រូវបានគេពិចារណាដោយដាច់ដោយឡែកតែឯងបានទេ ពីព្រោះខ្ញុំគិតថាវាអត់មានភាពជាក់លាក់ពេញលេញដែលអង្គជំនុំជម្រះសាលាដំបូង។ ដូច្នេះ គឺថាគាត់ត្រូវតែក្រឡេកមើលទៅលើគោលការណ៍ដែលគេអនុវត្តជាអន្តរជាតិ។

យើងខ្ញុំសូមលើកឡើងថា បញ្ហានេះក៏ជាបញ្ហាមួយដែលមិនត្រឹមត្រូវដែរ នៅពេលដែលក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជាមិនបានកំណត់និយមន័យអំពីបញ្ហាអាជ្ញាអស់ជំនុំនេះ។ ប៉ុន្តែនៅទីនេះ គឺមិនមែនមានន័យថា បច្ចេកសព្ទនេះ គឺថាវាអត់មានលក្ខណៈជាក់លាក់គ្រប់គ្រាន់នោះទេ។ ហើយយើងខ្ញុំក៏សុំលើកឡើងថាបញ្ហាអាជ្ញាអស់ជំនុំនេះ គឺបច្ចុប្បន្ននេះត្រូវបានគេឲ្យនិយមន័យមួយទៅតាមផ្លូវច្បាប់។ ហើយបើទោះបីជាព្រះរាជអាជ្ញាគាត់អាចថាត្រឹមត្រូវនៅក្នុងការកំណត់និយមន័យ ឥឡូវយើងសន្មតថា ពួកគាត់ត្រឹមត្រូវថា អង្គជំនុំជម្រះសាលាដំបូង គឺគួរតែក្រឡេកមើលទៅលើគោលការណ៍អន្តរជាតិដើម្បីធ្វើការកំណត់និយមន័យនៃអាជ្ញាអស់ជំនុំ។ គឺថាវាអត់ត្រូវបានគេបកស្រាយដោយក្រឡេកមើលទៅតាមវិធាននីតិវិធី ដែលត្រូវបានបង្កើតឡើងនៅក្នុងកម្រិតអន្តរជាតិពាក់ព័ន្ធជាមួយនឹងគោល-

ការណ៍នៃការមិនកាត់ទោសពីរដង។ អាជ្ញាអស់ជំនុំ គឺជាគោលការណ៍ជាទូទៅនៃច្បាប់។ អ៊ីចឹង យើងអាចក្រឡេកមើលទៅលើថា តើតុលាការដទៃៗទៀតហ្នឹងគេអាចកំណត់និយមន័យយ៉ាងដូចម្ដេច? ដូច្នេះ យើងសុំលើកឡើងថា បើយើងក្រឡេកមើលទៅលើវិធាននីតិវិធីទាំងឡាយដែលមាន អត្ថិភាពអនុវត្តនោះ គឺថាវាអត់មានភាពច្បាស់លាស់ទៅលើការបកស្រាយ ទៅលើខ្លឹមសារនៃអាជ្ញាអស់ ជំនុំនេះទេ។

[១១:៤៤:៥៤]

វាជាការពិតណាស់ បើសិន ថាតើប្រព័ន្ធតុលាការនៅក្នុងប្រទេសកម្ពុជាដំណើរការយ៉ាងម៉េច មុនពេលដែលយើងបង្កើតអង្គជំនុំជម្រះវិសាមញ្ញនេះ ថាតើមេធាវី ព្រះរាជអាជ្ញាគាត់យល់យ៉ាងដូចម្ដេចដែរ អំពីអត្ថន័យនៃអាជ្ញាអស់ជំនុំហ្នឹង។ ជាការពិតណាស់ ថាតើពួកគាត់ដឹងថាតើត្រូវអនុវត្តនូវគោល-ការណ៍នេះយ៉ាងដូចម្ដេច?

ដូច្នេះ យើងចាំបាច់ត្រូវការបង្កើតនូវស្ថាប័ននេះ ដើម្បីយើងអាចចូល ទាញនូវសេចក្ដីសន្និដ្ឋានថា វាអាចបកស្រាយ និងទទួលបាននៅក្នុងកម្រិតអន្តរជាតិ នូវអត្ថន័យនៃពាក្យ “អាជ្ញាអស់ជំនុំនេះ” ហើយ និងការកំណត់អំពីការអនុវត្តនូវគោលការណ៍ អាជ្ញាអស់ជំនុំ នេះ។ ជាពិសេស ចំពោះករណីនៅចំពោះមុខយើង ដែលយើងទាំងអស់គ្នាទទួលស្គាល់ថា ឧក្រិដ្ឋកម្មដែលត្រូវបានគេចាត់ទុកថា ជាឧក្រិដ្ឋកម្មដែលមានសញ្ញាណជាអន្តរជាតិនេះ។

[១១:៤៥:៤៦]

ឥឡូវអង្គបុរេជំនុំជម្រះ ប្រសិនបើខ្ញុំអាចលើកឡើង ឡើងវិញហើយនិងការកត់សម្គាល់មួយចំនួនអង្គបុរេជំនុំជម្រះនៅក្នុងកថាខណ្ឌ១២២ នៅក្នុងសេចក្ដីសម្រេចរបស់ខ្លួន នៅលើសេចក្ដីសម្រេចទាក់ទងទៅនឹងបណ្ដឹងឧទ្ធរណ៍របស់យើង បានឃើញ យើងបកស្រាយថា មាត្រាទី១២នេះ មិនត្រូវបានគេយកទៅអនុវត្តចំពោះការកាត់ទោសពីមុនមកទេ។

ដូច្នេះ គឺគាត់ប្រើថា គាត់ត្រូវបានគេលើកលែង កាត់ឲ្យរួចទោសជាស្ថាពរ ហើយយើងពង្រីកនូវវិសាលភាពមាត្រាទី១២ ហ្នឹងដើម្បីបញ្ចូលទៅលើអ្នកដែលត្រូវបានគេកាត់ឲ្យមានពិរុទ្ធ ដោយវាអាចប្រឆាំងជាមួយនឹងបទប្បញ្ញត្តិដទៃទៀតនៅក្នុងក្រមព្រហ្មទណ្ឌកម្ពុជា និងក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជាដែលអាចអនុញ្ញាតឲ្យកិច្ចដំណើរការនីតិវិធីហ្នឹងត្រូវបានគេបើកឡើងវិញនៅក្នុងករណីដែលមានការកាត់ទោសឲ្យជាប់ពិរុទ្ធនោះ។

[១១:៤៦:៤២]

ដូច្នេះ គឺយើងផ្តោតទៅលើចំណុចទាំងពីរនេះ គឺថាការកាត់ឲ្យរួចទោសជាស្ថាពរ។ ដូច្នេះ អ្នកបុគ្គលម្នាក់ត្រូវតែត្រូវបានគេកាត់ឲ្យរួចទោសជាស្ថាពរ ដើម្បីឲ្យមានគោលការណ៍អាជ្ញាអស់ជំនុំនេះត្រូវបានយកមកអនុវត្ត។ ហើយអង្គបុរេជំនុំជម្រះក៏បានបន្តលើកឡើងទៀតថា នៅក្នុងកថាខណ្ឌ១២៣ នៃសេចក្តីសម្រេចរបស់គាត់ ហើយខ្ញុំសូមលើកឡើងបន្តិច គឺថាការពង្រីកនៃវិសាលភាពនៃមាត្រាទី១២ នៃក្រមនីតិវិធីព្រហ្មទណ្ឌដើម្បីបញ្ចូលជនដែលត្រូវបានកាត់ឲ្យជាប់ពិរុទ្ធនោះ គឺថាវាអាចប្រទាំងទិសជាមួយនឹងក្រមនីតិវិធីព្រហ្មទណ្ឌព្រះរាជាណាចក្រកម្ពុជា ដែលអនុញ្ញាតឲ្យកិច្ចដំណើរការនីតិវិធីហ្នឹងអាចបើកឡើងវិញនៅក្នុងករណីដែលមានការកាត់ទោសឲ្យជាប់ទោស ជាពិសេស នៅក្នុងករណីក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជាហ្នឹង គឺបានផ្តល់នូវលទ្ធភាពឲ្យគេអាចពិនិត្យមើលទៅលើកិច្ចដំណើរការនីតិវិធីឡើងវិញនៅក្នុងករណីដែលមានការកាត់ឲ្យជាប់ទោស។ ហើយនិងទីពីរ សម្រាប់អ្នកដែលត្រូវបានគេកាត់ទោសឲ្យជាប់ទោសកំបាំងមុខហ្នឹង ដើម្បីឲ្យគាត់អាចធ្វើការតវ៉ាឡើងវិញចំពោះសេចក្តីសម្រេចរបស់គាត់ និងដើម្បីសុំឲ្យមានការកាត់ទោសឡើងវិញ។ ហើយគេមិនទាន់និយាយថា នៅក្នុងការអនុវត្តមាត្រាទី១២ហ្នឹង ចំពោះការកាត់ឲ្យជាប់ទោស និងយើងមិនអាចបង្កឲ្យមានការបង្កើតនូវនីតិវិធីឡើងវិញដោយអនុលោមទៅតាមវិធានទី៥ នៃក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា។ ហើយការចោទប្រកាន់ហ្នឹងគឺថាមិនអាចបន្តទៅទៀតបាន ឬក៏ត្រូវតែបញ្ចប់តែម្តង។

ដូចដែលខ្ញុំបានបញ្ជាក់ពីខាងដើមអ៊ីចឹង គោលបំណងនៃការ គោលការណ៍មិនកាត់ទោសពីរដងនេះ គឺសម្រាប់ឲ្យជនជាប់ចោទហ្នឹង គាត់អាចធ្វើយ៉ាងម៉េចឲ្យខ្លួនគាត់ហ្នឹង គាត់អាចទទួលបាននូវការការពារមួយចំពោះការកាត់ទោសគាត់ពីរដង។

[១១:៤៨:៣៨]

ដូច្នេះ គឺវាស្របជាមួយនឹងបទប្បញ្ញត្តិដទៃទៀតដែរ ជាពិសេសក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា និងក្រមព្រហ្មទណ្ឌកម្ពុជា ដែលមានបំណងការពារនូវសិទ្ធិរបស់ជនជាប់ចោទនេះ។ ដូច្នេះ ខ្ញុំសូមលើកឡើងនៅក្នុងកិច្ចដំណើរការនីតិវិធីនេះថា លោក អៀង សារី គាត់មិនគួរត្រូវបានគេនាំមកកាត់ទោសពីរដងចំពោះឧក្រិដ្ឋកម្មតែមួយនោះទេ គឺឧក្រិដ្ឋកម្មដែលត្រូវបានគេកាត់ទោសរួចទៅហើយ ហើយពេលនោះជាការ ជាសេចក្តីសម្រេចស្ថាពរ ហើយមាននីតិវិធី ដែលមាននៅក្នុងច្បាប់។ ហើយវាគឺតុលាការពេលនោះ ដែលមានសមត្ថភាពនៅក្នុងការដឹកនាំសវនាការ ហើយនិងអាចអនុវត្តនៅក្នុងសេចក្តីសម្រេច ហើយនិងការកាត់ឲ្យជាប់ទោសនោះទៀតផង។

[១១:៤៩:២៣]

ដូច្នេះ សហភាតារបស់ខ្ញុំក៏បានលើកឡើងច្រើនមកហើយអំពីអនុសញ្ញា ហើយនិងកតិកាសញ្ញាអន្តរជាតិ ខ្ញុំមិនចង់លើកឡើងឲ្យបានច្រើនអំពីបញ្ហាហ្នឹងបន្ថែមទៀតទេ។ ខ្ញុំគិតថា យើងទាំងអស់គ្នាសុទ្ធតែបានយល់ថាតើលិខិតុបករណ៍អន្តរជាតិទាំងអស់នោះអាចអនុវត្តបានឬអត់? ដូច្នេះគឺថា យើងមានច្បាស់ហើយ មាននៅក្នុងរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ហើយក៏មានបញ្ជាក់អំពីកាតព្វកិច្ចនៅ ក្នុងការអនុវត្តនូវសន្ធិសញ្ញា និងកតិកាសញ្ញាទាំងអស់ហ្នឹងដែរ។

[១១:៥០:00]

ហើយខ្ញុំឃើញថាមាត្រាទី៤១៧ នៃកតិកាសញ្ញានៃសិទ្ធិពលរដ្ឋ និងនយោបាយ។ គឺថាគេបានលើកឡើងអំពីការអនុវត្តជាអន្តរជាតិទៅលើការអនុវត្តនូវខ្លឹមសារនៃមាត្រានៅក្នុងកតិកាសញ្ញាទាំងអស់នេះ ដែលវាមានឥទ្ធិពលធំជាងអ្វីដែលមានចែងនៅក្នុងលិខិតុបករណ៍ជាតិ។ ដូច្នេះ កតិកាសញ្ញាអន្តរ-ជាតិនេះគឺថា មានឥទ្ធិពលធំធេង។ ដូច្នេះហើយយើងមិនចាំបាច់មានការពន្យល់ថា តើហេតុអ្វីបានយើងឃើញថា ចំណុចទាំងអស់នេះគឺថាមានការអនុវត្តជាអន្តរជាតិនោះ។ ដូច្នេះយើងបានលើកឡើងថានៅក្នុងករណីនេះ អង្គបុរេជំនុំជម្រះគឺមានការយល់មិនបានត្រឹមត្រូវទេ ខ្ញុំគិតថាមិនមានបញ្ហាទាក់ទងទៅនឹងការអនុវត្តឆ្លងកាត់ជាអន្តរជាតិនៅក្នុងបរិបទនេះទេ។ ខ្ញុំគិតថាមិនមានតែម្តង។ ហើយខ្ញុំជឿជាក់ថា យើងបានលើកឡើងបានច្បាស់ហើយ នៅក្នុងសេចក្តីសន្និដ្ឋានរបស់យើង ហើយខ្ញុំមិនចាំបាច់លើកឡើងនូវទឡ្ហីករណ៍នោះឡើងវិញទេ។ ប៉ុន្តែខ្ញុំគ្រាន់តែចង់បញ្ជាក់ថា នៅក្នុងឆ្នាំ១៩៧៩ សវនាការហ្នឹងគឺបានកើតឡើងនៅក្នុងតុលាការកម្ពុជា។ ហើយដូចដែលករណីបច្ចុប្បន្នដែលកំពុងតែធ្វើដែរ គឺយើងធ្វើក្នុងបរិបទនៃតុលាការកម្ពុជា។ ហើយដូច្នេះ ខ្ញុំសូមលើកឡើងបញ្ហាបន្ទាប់មួយទៀត ដែលខ្ញុំអាចលើកឡើងនៅពេលនេះ ឬក៏ខ្ញុំអាចក៏ខ្ញុំអាចលើកឡើងនៅពេលណាមួយនៅក្នុងអំឡុងពេលពីរ ទៅបីថ្ងៃទៅមុខទៀតនេះ ឬក៏ខ្ញុំអាចត្រឹមតែជូនជាយោបល់មួយចំនួន ហើយយើងនឹងពិនិត្យមើលថា តើអ្វីដែលយើងមាននៅក្នុងសេចក្តីសន្និដ្ឋានរបស់យើងខ្ញុំ ដែលខ្ញុំបានតែងតែដាក់នៅក្នុងរយៈពេលពីរបីឆ្នាំកន្លងមកនេះ។ ថាតើអង្គជំនុំជម្រះវិសាមញ្ញ គឺជាតុលាការជាតិ? ឬក៏ជាតុលាការអន្តរជាតិ? ឬក៏តុលាការនេះ គឺជាតុលាការកូនកាត់?

វាគឺជារឿងមួយ វាជាតុលាការមួយ ដែលវាស្ថិតនៅរវាងតុលាការអន្តរជាតូបនីយកម្មទាក់ទងទៅនឹងចំណុចនេះ ខ្ញុំគិតថា រឿងបែបនេះមិនមានអត្ថិភាពទេ។ ជាពិសេសនៅមុខអង្គជំនុំជម្រះវិសាមញ្ញ

នេះ ព្រោះអ្វីដែលរដ្ឋាភិបាលកម្ពុជាកំពុងតែធ្វើនេះ គឺយើងកំពុងតែទទួលនូវជំនួយ ទាំងជំនួយខាងផ្នែកថវិកា ក៏ដូចជាជំនួយបច្ចេកទេសសម្រាប់ដំណើរការសវនាការនេះ។ បើទោះបីជាស្ថាប័នមួយនេះ គឺទទួលខុសត្រូវចំពោះនាំមកកាត់ទោសនូវឧក្រិដ្ឋកម្មអន្តរជាតិ។ ក៏ប៉ុន្តែវាមិនមែនបានន័យថា វាគឺជាតុលាការអន្តរជាតូបនីយកម្មដែរ។

[១១:៥២:៥៥]

ដូច្នេះខ្ញុំចង់លើកបញ្ហានេះ ប៉ុន្តែខ្ញុំគិតថា ខ្ញុំអាចលើកបញ្ហានេះនៅពេលណាក្រោយមួយ ហើយឬខ្ញុំអាចដាក់ជូននេះ ដូចដែលខ្ញុំចង់ដឹងថា តុលាការនេះគឺជាតុលាការជាតិ ហ្នឹង គឺជាគោលបំណងដំបូងរបស់វា រដ្ឋាភិបាលកម្ពុជាក៏បានយល់ព្រមទៅលើចំណុចហ្នឹងដែរ។ ហើយហ្នឹងគឺជាគោលការណ៍ដែលត្រូវបានព្រមព្រៀងដោយអង្គការសហប្រជាជាតិដែរ។ ហើយមាននូវដំណាក់ស្រង់មួយចំនួនអំពីការជជែកពិភាក្សាគ្នាអំពីការបង្កើតតុលាការនេះ។ ដូច្នេះ ខ្ញុំលើកឡើងថា ដើម្បី-- បើយើងចង់ឲ្យវាក្លាយទៅជាតុលាការអន្តរជាតូបនីយកម្ម ដែលយើងអាចមាននៅកន្លែងណាមួយ ដែលយើងអាចថា តុលាការហ្នឹងជាតុលាការអន្តរជាតូបនីយកម្ម ហើយអ៊ីចឹងគេអាចមិនពិចារណាទៅលើចំណុចណាមួយនោះ ឬក៏បញ្ហាច្បាប់ណាមួយដូចជាបញ្ហា ការលើកលែងទោស ឬក៏ការអនុគ្រោះទោសរបស់ព្រះមហាក្សត្រហ្នឹង គឺខ្ញុំគិតថា វាយើងមិនអាចយកបញ្ហាហ្នឹង យកមកបន្ទច់បង្អាក់ទៅលើកករណីហ្នឹងទេ ហើយបើធ្វើដូច្នោះមែនគឺជាការមិន ត្រឹមត្រូវនោះឡើយ។

[១១:៥៤:០៤]

ហើយខ្ញុំគ្រាន់តែសូមជូនយោបល់ និងការសង្កេតមួយចំនួនតូចទៀតតែប៉ុណ្ណោះ។ លោកប្រធានប្រសិនបើការអនុញ្ញាត ខ្ញុំគ្រាន់តែចង់ធ្វើការសរុបមកវិញដោយលើកនិយាយថា ទទ្បីករណ៍របស់ព្រះរាជអាជ្ញា។ ព្រះរាជអាជ្ញា គឺបានលើកឡើងអំពីករណីរបស់ខ្លួនពាក់ព័ន្ធជាមួយនឹងសវនាការពីមុនមកទៅលើលោក អៀង សារី ដែលគាត់គិតថាមិនបានធ្វើឡើងទៅតាមនីតិវិធីច្បាប់ឲ្យបានត្រឹមត្រូវ ហើយសេចក្តីសម្រេចនោះ គឺមិនមែនជាសេចក្តីសម្រេចស្ថាពរទៅទៀត។ ហើយវា គឺជាសវនាការកំបាំងមុនហើយមិនមាននូវសាលាឧទ្ធរណ៍ ឬក៏-- ដើម្បីឲ្យគាត់តវ៉ា។

ហើយខ្ញុំមិនចាំបាច់និយាយ អំពីបញ្ហាសវនាការនៅក្នុងតុលាការឧទ្ធរណ៍សម្រាប់ពេលនោះទេ។ ពេលនោះ គឺថា-- ប៉ុន្តែយើងសូមសន្មតថា សម្រាប់ការពិភាក្សារបស់យើងនេះបើសិនជាមាននូវសាលាឧទ្ធរណ៍មែនសម្រាប់ឲ្យ ធ្វើម៉េចឲ្យសេចក្តីសម្រេចនោះជាស្ថាពរហ្នឹង។ អ៊ីចឹង គឺថានៅពេលហ្នឹងគឺ

រាល់សេចក្ដីសម្រេចរបស់តុលាការដែលគេធ្វើសវនាការចាប់ពីឆ្នាំ១៩៧៩ហ្នឹង នៅក្នុងបរិបទជាតិនៅក្នុងឆ្នាំ១៩៧៩ រហូតទៅដល់ពេលមួយ ដែលប្រទេសកម្ពុជាមាននូវប្រព័ន្ធតុលាការជាប្រព័ន្ធឧទ្ធរណ៍ ឬក៏សាលាកំពូល ហើយដើម្បីធ្វើឲ្យសេចក្ដីសម្រេចហ្នឹងទៅជាសេចក្ដីសម្រេចស្ថាពរ។ អ៊ីចឹងគឺថា បានន័យថាតើករណីដទៃៗទៀតដែលត្រូវបានគេកាត់ទោសនៅពេលហ្នឹង សុទ្ធតែជាកាត់ទោសថា គាត់អត់មានសិទ្ធិទាំងអស់ ឬក៏យ៉ាងណា? ដូចគ្នាទាំងអស់។ ថាតើវាពិតជាមានការផ្ដល់នូវយុត្តិធម៌ដែលមិនត្រឹមត្រូវសម្រាប់អ្នកដែលទទួលបានការកាត់ទោសនៅពេលនោះដែរ ឬក៏យ៉ាងណា? ដូច្នេះវាជាបញ្ហាមួយ ដែលយើងឃើញថាៗតើបុគ្គលទាំងអស់ហ្នឹងគាត់សុទ្ធតែបានបោះបង់នូវសិទ្ធិរបស់គាត់នៅក្នុងការធ្វើបណ្ដឹងឧទ្ធរណ៍ឡើងទៅសាលាឧទ្ធរណ៍ ឬសាលាកំពូល ឬអត់?

[១១:៥៦:០៩]

ដូចនេះ គឺជាសវនាការមួយដែលស្ថាពរ ឬយ៉ាងម៉េច? ហើយសវនាការ ឬក៏សេចក្ដីសម្រេចចុងក្រោយដែលលោក អៀង សារីហ្នឹង គាត់ត្រូវបានគេកាត់ទោសឲ្យគាត់ជាប់នៅពេលនោះ។

ខ្ញុំគិតថា ខ្ញុំមិនមានអ្វីបន្ថែមទៀតទេទៅលើចំណុចនេះ ហើយខ្ញុំត្រៀមខ្លួននឹងឆ្លើយទៅនឹងសំណួរទាំងអស់ប្រសិនបើអង្គចៅក្រមលោកមានជាសំណួរអ្វីមួយ។ បើមិនដូច្នោះទេ ខ្ញុំមានសំណើសុំមួយ ថាប្រសិនបើយើងមិនចំណាយពេលវេលាមួយម៉ោង ដែលលោកចៅក្រមបានអនុញ្ញាតឲ្យយើងខ្ញុំសម្រាប់ធ្វើសេចក្ដីសន្និដ្ឋានបើកនេះ។ ខ្ញុំគិតថា តើយើងអាចមានពេលហ្នឹង ដើម្បីសន្សំពេលហ្នឹង ឲ្យយើងខ្ញុំលើកនៅពេលក្រោយ ដើម្បីយើងខ្ញុំលើកពេលនេះសុំសន្សំពេលហ្នឹង ដើម្បីលើកឡើងក្នុងនៅពេលណាមួយដែលមានចាំបាច់។ ខ្ញុំដឹងថាប្រហែលវាមិនចាំបាច់ទេ ប៉ុន្តែបើសិនជាក្នុងករណីដែលយើងខ្ញុំចាំបាច់ខ្ញុំចង់ប្រើប្រាស់ពេលវេលាដែលយើងប្រើមិនអស់នេះ សម្រាប់ឲ្យយើងអាចលើកនូវបញ្ហាជាក់លាក់ណាមួយដែលយើងខ្ញុំចង់លើកនោះ។

សូមអរគុណលោកប្រធាន សូមអរគុណអង្គចៅក្រមដែលបានអនុញ្ញាតឲ្យខ្ញុំលើកឡើង។

[១១:៥៧:១៧]

**ប្រធានអង្គជំនុំ៖**

បាទ, អរគុណលោកមេធាវីដែលបានធ្វើបទបង្ហាញពាក់ព័ន្ធទៅនឹងបញ្ហាអញ្ញត្រកម្មមានការកាត់ទោសពីរដងចំពោះបទល្មើសតែមួយនេះ។ ហើយឥឡូវនេះដល់ពេលត្រូវសម្រាកដើម្បីពិសាអាហារថ្ងៃត្រង់ល្មមតែម្ដង។ អ៊ីចឹង គឺអង្គជំនុំជម្រះសូមប្រកាសសម្រាកដើម្បីពិសាថ្ងៃត្រង់ចាប់ពីពេលនេះតទៅ

រហូតដល់ម៉ោងដប់បី និងសាមសិបនាទី។ សូមអញ្ជើញភាគី សាធារណជនចូលមកកាន់ទីកន្លែងរៀងៗខ្លួនវិញ ដើម្បីបន្តកិច្ចដំណើរការសវនាការ និងសូមបញ្ជាក់ថា សូមអញ្ជើញឲ្យបានមុនម៉ោង ម៉ោងដប់បីនិងសាមសិបនាទី។

អនុរក្សមន្ទីរឃុំឃាំងនាំជនជាប់ចោទ ខៀវ សំផន និងលោក អៀង សារី ទៅកាន់បន្ទប់រង់ចាំសម្រាកនៅខាងក្រោម ហើយបង្គាប់ឲ្យនាំគាត់មកកាន់សាលសវនាការឲ្យបានមុនម៉ោង ម៉ោងដប់បីនិងសាមសិបនាទី ជាកំណត់។

**លោកស្រី សែ កុលវុឌ្ឍី៖**

សូមអញ្ជើញក្រោកឈរ!

*(ចៅក្រមចាកចេញពីបន្ទប់សវនាការ)*

*(សវនាការសម្រាកពីម៉ោង ១១:៥៩ នាទី ដល់ម៉ោង ១៤:០៥នាទី)*

[១៤:០៥:១១]

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញអស់លោក លោកស្រីអង្គុយចុះ! អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការតទៅទៀត។

មុននឹងចាប់ផ្ដើមកិច្ចដំណើរការអង្គជំនុំជម្រះសូមជម្រាបជូនដល់ជនជាប់ចោទនិងមេធាវីការពារក្ដីថា តាមបទប្បញ្ញត្តិវិធានផ្ទៃក្នុង៨១(៣) ៨១(៤) និង៨១(៥) តម្រូវឲ្យមានវត្តមានជនជាប់ចោទនៅក្នុងអំឡុងពេលកិច្ចដំណើរការសវនាការ គឺមានវត្តមាននៅក្នុងបន្ទប់សវនាការនេះ។

ដោយឡែក នៅក្នុង លក្ខខណ្ឌផ្សេងៗដែលមានចែងនៅក្នុងវិធាន៨១(៣) ៨១(៤) ៨១(៥) វាអាស្រ័យទៅលើស្ថានភាពនៃបញ្ហាសុខភាពរបស់ជនជាប់ចោទដែលមិនអាចចូលរួមបាន ដោយមានភស្តុតាងបញ្ជាក់ច្បាស់លាស់ស្នើសុំមកអង្គជំនុំជម្រះ អង្គជំនុំជម្រះនឹងពិចារណាសម្រេចអំពីបញ្ហានេះ។

បញ្ហាមួយទៀត អង្គជំនុំជម្រះសូមជម្រាបថា ជនជាប់ចោទជារៀងរាល់ថ្ងៃនៃសវនាការត្រូវតែបង្ហាញខ្លួននៅចំពោះមុខអង្គជំនុំជម្រះជាបឋម មុននឹងបង្ហាញនូវមូលហេតុផ្សេងៗដែលនាំឲ្យខ្លួនអាចស្នើសុំដកថយ ទៅស្ដាប់តាមដានកិច្ចដំណើរការសវនាការនៅបន្ទប់រង់ចាំខាងក្រោមបន្ទប់សវនាការនេះដែលបានរៀបចំនូវប្រព័ន្ធសោតទស្សន៍សម្រាប់ធ្វើសវនាការពីចម្ងាយ។

[១៤:០៧:៥៥]

ដូច្នេះ ចាប់ពីពេលនេះទៅគឺ សុំឲ្យភាគីអនុវត្តឲ្យបានត្រឹមត្រូវតាមការណែនាំនេះ ពីព្រោះបញ្ហានេះជាវិធានដែលកំណត់។ ហើយដើម្បីទុកឱកាសឲ្យអង្គជំនុំជម្រះពិនិត្យពិចារណាថ្លឹងថ្លែងពីស្ថានភាពជាក់ស្តែងដែលអនុញ្ញាត ឬមិនអនុញ្ញាត?

ហើយចំណុចចុងក្រោយគឺជនជាប់ចោទដែលត្រូវបានតុលាការអនុញ្ញាតឲ្យចាកចេញទៅ គឺត្រូវនៅបន្តតាមដានកិច្ចដំណើរការសវនាការនៅបន្ទប់ ដែលបានរៀបចំប្រព័ន្ធសោតទស្សន៍ធ្វើសវនាការពីចម្ងាយនៅក្រោមបន្ទប់សវនាការនេះ លើកលែងតែមូលហេតុមានជំងឺ ឬក៏ស្ថានភាពធ្ងន់ធ្ងរផ្នែកសុខភាពដែលអង្គជំនុំជម្រះនឹងពិចារណាសម្រេចតាមករណីជាក់ស្តែង។

[១៤:០៨:៥៨]

អង្គជំនុំជម្រះសង្ឃឹមថាជនជាប់ចោទ និងមេធាវីការពារក្តីនឹងយល់ពីបញ្ហានេះ។ សូមអញ្ជើញលោកមេធាវី ស សុវាន។

**លោក ស សុវាន៖**

សូមអរគុណលោកប្រធាន។ ខ្ញុំបាទស្តាប់ច្បាស់លាស់ ហើយខ្ញុំនឹងត្រៀមខ្លួនគោរព ប៉ុន្តែក្នុងពេលនេះកូនក្តីខ្ញុំបាទមានការហត់នឿយបន្តិច បានគាត់សុំឲ្យលោកប្រធាន និងអង្គជំនុំជម្រះសាលាដំបូងមេត្តាឲ្យគាត់ទៅនៅខាងក្រោម ហើយស្អែកគាត់នឹងខិតខំមកវត្តមាននៅសវនាការ ដោយហេតុថា គាត់ល្ងាចនេះ ខ្ញុំនៅម្នាក់ខ្ញុំ តាមសវនាការនេះដោយមិនពាក់ព័ន្ធនឹងរូបគាត់ បានគាត់ទុកពេលនេះសម្រាកដើម្បីស្អែកគាត់មានកម្លាំងបានតទៅទៀត បានសហការជាមួយតុលាការ។ សូមអង្គជំនុំជម្រះសាលាដំបូង លោកប្រធានជាពិសេស មេត្តាអនុញ្ញាតតាមពាក្យសុំ។ សូមអរគុណ។

*(ចៅក្រមពិភាក្សាគ្នា)*

[១៤:១១:១៣]

**ប្រធានអង្គជំនុំ៖**

ដោយស្តាប់នូវសំណើសុំរបស់មេធាវី ស សុវាន ហើយនិងស្តាប់នូវមូលហេតុនៃការស្នើសុំនេះ អង្គជំនុំចម្រះយល់ឃើញថា ស្ថានភាពនៃបញ្ហាសុខភាពរបស់ជនជាប់ចោទលោក ខៀវ សំផន មិនមានសញ្ញាណ ឬក៏មិនមានអ្វីដែលធ្ងន់ធ្ងរនោះឡើយ។ ដូច្នេះ អង្គជំនុំជម្រះមិនអនុញ្ញាតទេ។

**លោក មៃខល កាណាវាស៖**

សូមគោរពលោកប្រធាន, ប្រសិនបើខ្ញុំអាចលើកឡើងចំពោះកូនក្តីរបស់ខ្ញុំពាក់ព័ន្ធនឹងចំណុចដែល

លើកឡើងនេះ ខ្ញុំគិតថាវាជាបញ្ហាមួយធ្ងន់ធ្ងរ។ ខ្ញុំសូមអនុញ្ញាតលើកឡើងរៀបរាប់ថា តើមានអ្វីកើតឡើងនៅតុលាការ អាយ.ស៊ី.ធី.វ៉ាយ ដោយសារតែសហព្រះរាជអាជ្ញានៅទីនោះអាចលើកឡើងថា តើវាមានករណីយ៉ាងណាខ្លះនៅទីនោះ? ហើយយើងអាចយកមកធ្វើជាបទដ្ឋានណែនាំបាន។

ខ្ញុំក៏សូមលើកឡើងទៅលើបញ្ហានេះបន្តិចបន្តួច និងគោលការណ៍អន្តរជាតិមួយចំនួន៖

ចំណុចទីមួយ: ខ្ញុំសូមលើកឡើងថា នៅពេលដែលជាប់ចោទមានអារម្មណ៍ថា ខ្លួនមិនមានអារម្មណ៍ល្អនៅក្នុងតុលាការនោះទេ ហើយគាត់បោះបង់សិទ្ធិចូលរួមនៅក្នុងសវនាការ អង្គជំនុំជម្រះមានសិទ្ធិក្នុងការសម្រេច។ នៅតុលាការ អាយ.ស៊ី.ធី.វ៉ាយ មិនមាននរណាម្នាក់ត្រូវបានគេបង្ខំឱ្យមកចូលរួមក្នុងសវនាការនោះទេ។ គេអាចមើលនៅក្នុងបន្ទប់ឃុំឃាំងតាមរយៈសោតទស្សន៍។ ដូច្នេះ ពួកគេអាចអង្គុយនៅបន្ទប់ឃុំឃាំង មើលដំណើរការសវនាការពីទីនោះបាន។ ឬក៏ក្នុងករណីដែលជនជាប់គាត់មិនមានឆន្ទៈក្នុងការចូលរួមនៅក្នុងនេះ ក្នុងបន្ទប់សវនាការ ដូច្នេះ គឺគាត់អាចតាមដានពីទីកន្លែងនោះមក។

[១៤:១៣:៣៩]

ដូច្នេះ នៅពេលដែលជានជាប់ចោទគាត់បោះបង់សិទ្ធិរបស់គាត់ហើយ វាជាសិទ្ធិរបស់គាត់។ ខ្ញុំនៅធ្វើការនៅទីនេះ ខ្ញុំឃើញថា ជនជាប់ចោទ-- ដែលខ្ញុំធ្វើការនៅ អាយ.ស៊ី.ធី.វ៉ាយ ជនជាប់ចោទមួយចំនួននោះ គឺគាត់មានបំណងមិនមកចូលរួម។ មិនមែនថាពួកគេមិនអាចមកចូលរួមនោះទេ គឺពួកគេបោះបង់សិទ្ធិមិនចូលរួមតែម្តង រួមទាំងកូនក្តីរបស់ខ្ញុំនៅទីនោះក៏គេមិនមានបំណងមកចូលរួម។ ខ្ញុំមិនលើកឡើងថា បទដ្ឋាននៅទីនោះជាបទដ្ឋានល្អទេ ប៉ុន្តែខ្ញុំគ្រាន់តែចង់បញ្ជាក់ជូនអង្គជំនុំជម្រះសាលាដំបូងនៅពេលនេះ។

យើងខ្ញុំសូមលើកឡើងក្នុងសំណើដោយគោរពឱ្យអង្គជំនុំជម្រះពិចារណាទៅលើបញ្ហានេះ ដោយសារតែបុគ្គលជនជាប់ចោទនីមួយៗមានវ័យចាស់ មើលរូបរាងរបស់គាត់ហាក់ដូចជារឹងមាំ ប៉ុន្តែគាត់មានវ័យចាស់។ ចំពោះកូនក្តីរបស់ខ្ញុំ គាត់មិនអាចអង្គុយយូរបានទេ ហើយគាត់ក៏ត្រូវការប្រើប្រាស់បន្ទប់ទឹករៀងរាល់កន្លះម៉ោងម្តង។ ហើយគាត់ក៏មិនអាចផ្តោតអារម្មណ៍យូរផងដែរ គាត់ក៏មិនអាចផ្តល់ការណែនាំដល់មេធាវីការពារក្តីរបស់ខ្លួន។ ដូច្នេះប្រសិនបើអង្គជំនុំជម្រះអនុវត្តវិធីសាស្ត្រនេះ វាហាក់ដូចជាវាមិនគប្បី ហើយយើងមានបន្ទប់រង់ចាំរួចទៅហើយ ដែលសម្រាប់ត្រៀមសម្រាប់គាត់ពិនិត្យមើលនីតិវិធីពីទីកន្លែងនោះ។

[១៤:១៥:១៣]

កូនក្តីរបស់ខ្ញុំមិនមែនថាគាត់មិនចូលរួមសវនាការបឋមនោះទេ។ ប៉ុន្តែ យ៉ាងណាក៏ដោយខ្ញុំសូមស្នើថា ប្រសិនបើជនជាប់ចោទគាត់មានមេធាវី គាត់តំណាងហើយ។ ហើយប្រសិនបើ ជនជាប់ចោទគាត់សរសេរលិខិតជាលាយលក្ខណ៍អក្សរបោះបង់សិទ្ធិរបស់គាត់ គឺបោះបង់សិទ្ធិមានមេធាវីរបស់គាត់ ហើយដាក់ជូនទៅអង្គជំនុំជម្រះសាលាដំបូង ហើយព្យាយាមនិយាយការពិតវិញនោះ យើងជឿជាក់ថា អង្គជំនុំជម្រះគួរតែផ្តល់តម្លៃនេះ និងគួរតែឲ្យតម្លៃនៃការបោះបង់សិទ្ធិរបស់ជនជាប់ចោទនេះ។ បើសិនជាជនជាប់ចោទមិនមានបំណងមកទីនេះហើយ វាមិនមែនជាដំណោះស្រាយដែលយើងចាប់បង្ខំគាត់ឲ្យមកនៅទីនេះឡើយ។

ប្រសិនបើជនជាប់ចោទគាត់មានបំណងមកចូលរួមទោះបីជាហេតុផលណាក៏ដោយ វាមិនមែនជាសេចក្តីសម្រេចអ្នកណាផ្សេងធ្វើនោះទេ គឺជនជាប់គាត់ស្នើសុំ ហើយអង្គជំនុំជម្រះត្រូវតែធ្វើការសម្រេច។

[១៤:១៦:២៨]

ដូច្នេះហើយ ជនជាប់ចោទនៅក្នុងបន្ទប់សវនាការ ពេលខ្លះទៅគាត់មិនអាចមកនៅទីនេះបានដោយសារតែបញ្ហាសម្បទារបស់គាត់ ដូច្នេះហើយខ្ញុំសូមលើកឡើងថា ពេលខ្លះប្រសិនបើយើងបដិសេធវាជាការបដិសេធសិទ្ធិជំនុំជម្រះដោយយុត្តិធម៌របស់ជនជាប់ចោទ។ ខ្ញុំដឹងថានេះមិនមែនជាចេតនារបស់អង្គជំនុំជម្រះសាលាដំបូងនោះទេ ហើយខ្ញុំគិតថា អង្គជំនុំជម្រះសាលាដំបូងមិនមានបំណងដាក់សេចក្តីបង្គាប់នោះទេ។

ប៉ុន្តែយ៉ាងណាក៏ដោយ ខ្ញុំសូមឲ្យអង្គជំនុំជម្រះសាលាដំបូងពិចារណាបន្ថែម ហើយយើងត្រូវតែមានលក្ខណៈបត់បែន ហើយដោយយើងគោរពទៅលើកូនក្តីរបស់យើងទាំងអស់គ្នាដែលមានវ័យចំណាស់ កូនក្តីរបស់ខ្ញុំនៅក្នុងរសៀលនេះ គឺបង្គាប់ឲ្យគាត់មកចូលរួម ដូច្នេះគាត់នៅតែមកចូលរួមដដែល គាត់នៅទីនេះនៅពេលនេះ។ គាត់មកបំណងចូលរួមពេញមួយរសៀលនេះ ជាពិសេសចង់នៅក្នុងបន្ទប់រង់ចាំតាមដានពីតិវិធីដែលរៀបចំសម្រាប់រូមគាត់។ ដូច្នេះ យើងខ្ញុំស្នើសុំដោយគោរពថា សំណើសុំរបស់កូនក្តីរបស់យើងខ្ញុំទទួលយកដោយអង្គជំនុំជម្រះ។

ចំណុចមួយទៀត ដែលខ្ញុំសូមលើកឡើងដើម្បីឲ្យមានការបំភ្លឺកាលពីព្រឹកមិញផងដែរ ខ្ញុំក៏មានចំណុចហ្នឹងលើកឡើងផងដែរដើម្បីបញ្ជាក់ឲ្យបានច្បាស់ទៅលើអ្វីដែលបានខ្ញុំបានលើកឡើងកាលពីព្រឹកមិញ។ សូមអរគុណ។

*(ចៅក្រមពិភាក្សាគ្នា)*

[១៤:១៩:០០]

**ប្រធានអង្គជំនុំ៖**

លោកមេធាវី កាណាវាស ខ្ញុំស្តាប់មើលទៅហើយអរគុណច្រើនដែលលោកមេធាវីធ្វើការបង្ហាញនូវបទពិសោធន៍នៅបណ្តាតុលាការព្រហ្មទណ្ឌអន្តរជាតិ ដែលមានជនជាប់ចោទនៅក្នុងរឿងក្តីនៅទីនោះដែលមានស្រដៀងនៅទីនេះដែរ ហើយនូវលក្ខខណ្ឌមួយចំនួនដែលការតម្រូវបង្ខំឱ្យចូលរួមនៅកិច្ចដំណើរការនីតិវិធីសវនាការ ឬមានវិធានការផ្សេងដោយឡែកដូចជា តាមមធ្យោបាយប្រព័ន្ធសោតទស្សន៍ជាដើម ដូចលោកបានលើកឡើងអម្បាញ់មិញ។ ប៉ុន្តែ ជាចុងក្រោយ លោកបាននិយាយថាសំណើសុំៗឱ្យអង្គជំនុំជម្រះដោះស្រាយនូវសំណើសុំរបស់លោក ហើយតាមជាភាសាដូចជាការបង្ហាញហ្នឹងដូចជាមិនមានអីជាសំណើច្បាស់លាស់ទេ។ តើលោកស្នើថាយ៉ាងម៉េចទៅឥឡូវនេះ? ហើយមានមូលហេតុអីនៃការស្នើសុំដើម្បីឱ្យអង្គជំនុំជម្រះហ្នឹងពិចារណាសម្រេចអំពីបញ្ហានេះ គឺកំណត់ជុំវិញបញ្ហាតែតម្រូវឱ្យមានវត្តមានជនជាប់ចោទនៅក្នុងអំឡុងពេលនៃដំណើរការនេះតែប៉ុណ្ណោះ។ អម្បាញ់មិញនេះ គឺលោកបានបញ្ជាក់ថាកូនក្តីរបស់លោកគឺនឹងបន្តនៅក្នុងការចូលរួមនៅក្នុងកិច្ចដំណើរការនៅវសៀលនេះ ប៉ុន្តែចុងក្រោយ គឺលោកបានស្នើសុំឱ្យអង្គជំនុំជម្រះហ្នឹង សម្រេចអំពីបញ្ហា វាមិនដឹងថាតើបញ្ហាអីដែលច្បាស់លាស់។

**លោក ម៉ៃខល កាណាវាស៖**

ខ្ញុំសូមអភ័យទោសដែលខ្ញុំលើកឡើងមិនច្បាស់លាស់។ នៅក្នុងរសៀលថ្ងៃនេះ សំណើខ្ញុំទីមួយនោះ គឺថាសុំឱ្យលោក អៀង សារី នេះ សុំឱ្យគាត់ទៅចូលរួម ចាកចេញពីបន្ទប់សវនាការនេះ ឱ្យគាត់ទៅបន្ទប់រង់ចាំខាងក្រោមដើម្បីតាមដានសវនាការវិញ។ ហើយចំពោះសំណើសុំមួយទៀតនោះ គឺខ្ញុំសូមឱ្យអង្គសាលាដំបូងពិចារណាទៅលើសេចក្តីបង្គាប់របស់អង្គជំនុំជម្រះសាលាដំបូង ប្រហែលជាខ្ញុំយល់ខុស ដោយសារតែបកប្រែមិនពេញលេញឬក៏យ៉ាងណា។ ទោះបីជាជនជាប់ចោទ មិនអាចមានលទ្ធភាពមកតុលាការ ឬក៏មិនចង់មកតុលាការនោះ គឺអង្គជំនុំជម្រះអាចចាប់បង្ខំជនជាប់ចោទមកចូលរួមសវនាការ។ ដូច្នេះ បើសិនជាដូច្នោះមែន ខ្ញុំយល់ឃើញថា នៅពេលដែលមេធាវីរបស់លោក ខៀវ សំផន លើកឡើងថា គាត់ចង់ឱ្យលោក ខៀវ សំផន ចាកចេញនោះ គឺសំណើនេះត្រូវបានបដិសេធចោល។

[១៤:២២:១១]

ដូច្នេះ លោក ខៀវ សំផន ត្រូវបានតុលាការបង្ខំឲ្យចូលរួមនៅក្នុងនីតិវិធីនេះ។ ខ្ញុំមិនមែនទស្សន៍ទាយទៅលើសេចក្ដីសម្រេចនោះទេ ប៉ុន្តែខ្ញុំយល់ឃើញថាវាហាក់ដូចជាសំណើត្រូវបានបដិសេធចោល។ ដូច្នេះ ផ្នែកទៅលើចំណុចនេះ វាជាឧទាហរណ៍មួយ ជាគំរូមួយសម្រាប់យើងទាំងអស់គ្នា។ ដូច្នេះ ខ្ញុំស្នើថា នីតិវិធីក្រោយៗ ប្រហែលជាអង្គជំនុំជម្រះសាលាដំបូងអាចពិចារណាបញ្ហានេះឡើងវិញ ដើម្បីកែប្រែ កែតម្រូវទៅលើការបង្គាប់នេះ។

ខ្ញុំដឹងថា បញ្ហាជាក់លាក់នៅក្នុងនីតិវិធីពេលខ្លះវាមិនអាចជាផលប្រយោជន៍ ប៉ុន្តែវាក៏-- ខ្ញុំជឿថាវាក៏ជាប្រយោជន៍សម្រាប់យើង។ ហើយប្រសិនបើកូនក្ដីរបស់យើងចង់មិនចង់ចូលរួមនៅក្នុងតុលាការនោះទេ យើងមិនអាចចាប់បង្ខំគាត់នោះទេ។ ខ្ញុំអាចធ្វើការស្រាវជ្រាវបន្ថែមទៀតទៅលើចំណុចហ្នឹង។ ការបង្ខំជនជាប់ចោទចូលក្នុងបន្ទប់សវនាការ ហើយនៅពេលនោះ គឺជនជាប់ចោទមិនមានឆន្ទៈចូលរួមផងនោះ ដូច្នេះវាហាក់ដូចជាការរំលោភទៅលើសិទ្ធិរបស់គាត់។ វាជាការរំលោភសិទ្ធិមនុស្សរបស់គាត់ដែរថា ចាប់បង្ខំឲ្យជនជាប់ចោទចូលរួមក្នុងបន្ទប់សវនាការ ហើយជនជាប់ចោទនោះ គាត់មិនមានលទ្ធភាព ឬគាត់មិនចង់ចូលរួមផងនោះ។ នេះគឺជាសំណើដែលខ្ញុំលើកឡើង ហើយខ្ញុំយល់ថាអ្វីដែលខ្ញុំលើកឡើងគឺច្បាស់លាស់។

ដូច្នេះ នៅពេលនេះខ្ញុំស្នើសុំឲ្យលោក អៀង សារី ចាកចេញពីបន្ទប់សវនាការទៅបន្ទប់រង់ចាំខាងក្រោម។ ខ្ញុំមិនចង់លើកឡើងចំណុចមួយទៀតនោះទេ ប៉ុន្តែយ៉ាងម៉េចណាក៏ដោយ នៅពេលដែលលោក លោកស្រីចៅក្រមបានជួបប្រជុំគ្នា ខ្ញុំដឹងថាមិនមែនចៅក្រមគ្រប់រូបបានចូលរួមពិភាក្សាគ្នាទាំងអស់គ្នានោះទេ។ ខ្ញុំដឹងថា ការពិភាក្សានោះ អំម្បាញ់មិញ គឺធ្វើឡើងមុនពេលបើកសវនាការនេះ។ វាជាចំណុចមួយសំខាន់ វាជាចំណុចមួយមូលដ្ឋាន វាជាចំណុចមួយដែលត្រូវសម្រេច ថាតើយើងត្រូវអនុវត្តនីតិវិធីនេះតាមរបៀបណា? ខ្ញុំចង់លើកឡើងដូច្នេះ ដោយសារតែចង់ឲ្យកត់ត្រាក្នុងកំណត់ប្រតិចារឹក។

[១៤:២៤:៤៦]

ជនជាប់ចោទកូនក្ដីរបស់ខ្ញុំចង់ចូលរួមណាស់នៅក្នុងនីតិវិធីនេះ។ ប៉ុន្តែប្រសិនបើគាត់មិនចង់ចូលរួមទេ គាត់នឹងជម្រាបមកមេធាវីរបស់គាត់ ហើយខ្ញុំនឹងជម្រាបបន្តទៅកាន់អង្គជំនុំជម្រះ ហើយឲ្យអង្គជំនុំជម្រះធ្វើការពិចារណា។ ទាំងអស់នេះហើយ គឺជាអ្វីដែលលើកឡើងជាសំណើរបស់ខ្ញុំ ហើយត្រូវការឲ្យអង្គជំនុំជម្រះពិចារណានិងសម្រេច។

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញសហព្រះរាជអាជ្ញាអន្តរជាតិ!

[១៤:២៥:២០]

**លោក អាន់ទ្រូ ខេលី៖**

សូមគោរពលោកប្រធាន ហើយសូមអរគុណ។ ហើយខ្ញុំនឹងឆ្លើយតបដោយសង្ខេបទៅមេធាវីការពារ។ ហើយមានមូលហេតុនៅក្នុងនីតិវិធី ហើយនិងលក្ខខណ្ឌតម្រូវជាមូលដ្ឋានដែលថាជនជាប់ចោទត្រូវចូលរួមសវនាការ ដូចដែលលោក កាណាវាស បានលើកជូនជាឧទាហរណ៍ នៅតុលាការយូហ្គោស្លាវីនោះ ដែលថាបុគ្គលមួយចំនួនមិនបានចូលរួមក្នុងសវនាការនោះ ហើយមានឧទាហរណ៍មួយចំនួនពីរឿងហ្នឹង។ ភាគីច្រើននៃជន--

[១៥:២៥:៤៧]

**លោក អាង ឧត្តម៖**

សូមទោសៗ។ ដោយសារមានសំណើសហភាតារបស់ខ្ញុំមានពីរ សំណើសំខាន់បំផុតតែទាំងពីរនោះ តុលាការមិនបានសម្រេចទេ។ ឥឡូវ ខ្ញុំសុំម្តងទៀត សុំដោយសង្ខេប សូមអនុញ្ញាតឲ្យលោក អៀង សារី ទៅសម្រាកនៅបន្ទប់រង់ចាំនៅខាងក្រោម ដោយសារគាត់មានបញ្ហាឈឺចង្កេះអង្គុយលែងបានហើយ សូមលោកមេត្តាសម្រេចពេលនេះ។ សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

អញ្ជើញបន្តលោកសហព្រះរាជអាជ្ញអន្តរជាតិ!

**លោក អាន់ទ្រូ ខេលី៖**

សូមអរគុណលោកប្រធាន។ ដូចដែលខ្ញុំបញ្ជាក់ គឺថាវាមានគោលការណ៍ជាមូលដ្ឋានដែលថាជនជាប់ចោទត្រូវវត្តមាន គឺមានការលើកលែងមួយចំនួន ទាក់ទងទៅនឹងតុលាការ យូហ្គោស្លាវី ដែលបុគ្គលម្នាក់ៗមិនអាចចូលរួមបាន ហើយឬក៏បដិសេធមិនព្រមចូលរួមនោះ។ ឥឡូវនេះ ខ្ញុំគិតថា ជាឧទាហរណ៍មួយសំខាន់ ឧទាហរណ៍ថា ជនជាប់ចោទណាម្នាក់មិនមានលទ្ធភាពក្នុងការចូលរួម ដោយហេតុខ្លួនមានវ័យចំណាស់ មានជំងឺខាងរាងកាយ ឬក៏បញ្ញាស្មារតី តុលាការត្រូវតែមានសាក្សីពីអ្នកជំនាញដើម្បីនឹងចេញសេចក្តីសម្រេច មិនមែនស្តាប់តែសម្តីរបស់មេធាវីការពារ ហើយសម្រេចនោះទេ។ ហើយនៅក្នុងករណីថា ជនជាប់ចោទមិនវត្តមាននៅក្នុងសាលសវនាការ នៅក្នុងដំណើរការនីតិវិធីទេ

ប្រសិនបើតុលាការត្រូវឆ្លើយតបទៅនឹងសំណើរបស់គាត់នោះ គឺថាត្រូវតែមានមូលហេតុឲ្យច្បាស់ ហេតុថាអ្វីបានជាជនជាប់ចោទរូបនេះមិនចូលរួម? តើគាត់មិនចង់ចូលរួម ដូចជាករណីលោក នួន ជា ព្រឹកមិញនេះ ឬក៏គាត់មិនមានលទ្ធភាពដោយសារថាមានជំងឺរូបកាយ ឬក៏ផ្លូវចិត្តនោះ?

ខ្ញុំគិតថា នៅក្នុងអត្ថប្រយោជន៍នៃកំណត់ត្រាក្នុងនីតិវិធីនេះ ខ្ញុំសូមធានាថា គឺថានឹងមានការតវ៉ានៅពេលក្រោយទៀត ដូចដែលថាគាត់មិនចង់ចូលរួមនៅក្នុងនីតិវិធីផ្ទាល់ខ្លួនរបស់គាត់។ ប៉ុន្តែគ្រប់ពេលដែលគេបានដកខ្លួនចេញហ្នឹង គឺត្រូវមានមូលហេតុ ហើយមូលហេតុត្រូវកត់ត្រាឲ្យបានត្រឹមត្រូវ ដូចដែលលោក កាណាវាស បានលើកឡើងថា បើមានការបោះសិទ្ធិត្រូវមានតែលិខិតអំពីបញ្ហានោះ។ ខ្ញុំគិតថា នេះជាកត្តាសំខាន់ត្រូវមានកំណត់ត្រា។ ហើយនេះហើយដែលយើងអាចនឹងពិនិត្យនៅពេលក្រោយថាឃើញមានជនជាប់ចោទបានលើកឡើងថា ខ្លួនមិនចូលរួមបាន ដោយសារករណីអ្វីមួយ។ ប៉ុន្តែ ជាគោលការណ៍គ្រឹះ ខ្ញុំសូមជម្រាបតុលាការថា នៅក្នុងយុត្តាធិការទាំងអស់ នៅក្នុងតុលាការប្រទេសខ្ញុំក្តី នៅក្នុងអង់គ្លេស ហើយនៅក្នុងយុត្តាធិការអន្តរជាតិក៏ដោយ គឺថាជនជាប់ចោទ គឺតុលាការរំពឹងឲ្យចូលរួមនៅក្នុងដំណើរការប្រឆាំងរូបគាត់។ សូមអរគុណ។

[១៤:២៨:៤៧]

**លោក ម៉ៃខល កាណាវាស៖**

សូមឆ្លើយតប នោះគឺថាវាមានការរំពឹងបែបនោះមែន។

**ប្រធានអង្គជំនុំ៖**

ប៉ុណ្ណឹងបានហើយ ហើយអង្គជំនុំជម្រះនឹងចាប់ពិចារណាលើបញ្ហាសំណើសុំរបស់លោក។ ដោយឡែកបញ្ហាកត់សម្គាល់របស់លោកមេធាវី កាណាវាស អំពីបទពិសោធន៍នៃបណ្តាតុលាការព្រហ្មទណ្ឌអន្តរជាតិ ដែលលោកខ្លួនឯងក៏បានលើកឡើងអំមិញ ថានឹងប្រឹងប្រែងដើម្បីធ្វើការសិក្សាស្វែងយល់បញ្ហានេះបន្ថែមទៀត ដើម្បីមានមូលដ្ឋានពេញលេញនៅក្នុងការជួយដល់កិច្ចដំណើរទៅថ្ងៃមុខឲ្យបានល្អប្រសើរ។ យើងគិតថា អង្គជំនុំជម្រះបានកត់សម្គាល់នូវគំនិតយោបល់របស់លោកហើយ ទាំងសហព្រះរាជអាជ្ញាផង ប៉ុន្តែបញ្ហានេះ នៅពេលនេះមិនមែនដោះស្រាយបញ្ហានេះទេ បញ្ហានេះអង្គជំនុំជម្រះនឹងយកទៅពិចារណាថ្លឹងថ្លែងដើម្បីមានវិធានការច្បាស់លាស់អំពីថា តម្រូវឲ្យមានវត្តមាន ឬក៏ករណីគ្មានវត្តមាននៅក្នុងលក្ខខណ្ឌណាខ្លះដែលត្រឹមត្រូវតាមវិធាន និងសមស្របបំផុតទៅតាមច្បាប់ជាតិ និងច្បាប់អន្តរជាតិ។

អ៊ីចឹង បញ្ហានេះយើងមិនអនុញ្ញាតដេញដោលគ្នាទៀតទេ។

[១៤:៣០:០៤]

**លោក ម៉ៃខល កាណាវាស៖**

សូមអរគុណលោកប្រធាន។

ហើយយើងអាចនឹងបានសេចក្ដីសម្រេចនូវសំណើទីមួយរបស់យើង ហើយនៅពេលនេះគឺថាសុំអនុញ្ញាតឲ្យលោក អៀង សារី បានថយទៅបន្ទប់រង់ចាំតាមដាន ដើម្បីគាត់មិនអាចអង្គុយបានទេ ពីព្រោះគាត់មានបញ្ហាជំងឺ ឈឺឆ្អឹងខ្នង។ ដោយសារថាលោកសហព្រះរាជអាជ្ញា អាន់ឌ្រូ ខេលី បានលើកឡើងពីបញ្ហានេះ ថាតើត្រូវមានកោសល្យវិច័យខាងពេទ្យដែរឬទេ នៅពេលនេះ?

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោកស្រីចៅក្រម!

**ចៅក្រម ស៊ីលវៀ ខាតវ៉ាយថ៍៖**

សូមឲ្យគាត់រក្សានៅទីនេះសិន ទុកឲ្យចៅក្រមពិភាក្សាបន្តិច សូមលោកអញ្ជើញអង្គុយសិន។

[១៤:៣០:៥៥]

*(ចៅក្រមពិភាក្សាគ្នា)*

[១៤:៣៣:២៣]

**ប្រធានអង្គជំនុំ៖**

សូមបញ្ជាក់ជាថ្មីម្ដងទៀត ដោយភាពមិនទាន់ច្បាស់លាស់លើមូលហេតុនៃសំណើសុំរបស់មេធាវី អៀង សារី អ៊ីចឹងសុំលោកមេធាវីបង្ហាញនូវមូលហេតុឲ្យបានច្បាស់លាស់ ហើយដើម្បីអាចចៅក្រមនៃអង្គជំនុំជម្រះហ្នឹងសួរបញ្ជាក់បន្ថែម ដើម្បីជាមូលដ្ឋាននៅក្នុងការសម្រេចលើសំណើសុំនេះ។

**លោក អាង ឧត្តម៖**

សូមអរគុណលោកប្រធាន។

ព្រឹកមិញករណីពីរ គ្រាន់តែករណីលោកស្រី អៀង ធីរិទ្ធ និងករណីលោក នួន ជា សូមការអនុញ្ញាតចេញពីបន្ទប់សវនាការដោយមិនមែនមូលហេតុ លោកចៅក្រមសាលាដំបូងសម្រេចភ្លាម។ តែករណីលោក អៀង សារី គាត់មានករណីធ្ងន់ធ្ងរណាស់។ សូមជម្រាបថា គាត់មានជំងឺធ្ងន់ធ្ងរបីក្នុងចំណោមហ្នឹង គឺជំងឺឈឺចង្កេះ គាត់អង្គុយអត់បានទេ។ ខ្ញុំសុំតុលាការមេត្តាអនុញ្ញាតគាត់ចេញពីបន្ទប់

សវនាការ ឬគាត់នៅបន្ទប់ឃុំឃាំងវិញ ឬគាត់ទៅស្នាក់នៅបន្ទប់ជាន់ក្រោម។ សូមតុលាការមេត្តាអនុញ្ញាតពេលនេះ។

**ប្រធានអង្គជំនុំ៖**

អស់លោក លោកស្រីចៅក្រម តើមានអ្វីសំណួរអ្វីសួរបញ្ជាក់អំពីមូលហេតុនៃការស្នើសុំនេះឲ្យបានកាន់តែច្បាស់លាស់ទេ? ពីព្រោះអំមិញមានប្រើពាក្យ ឬទៀត ថែមមួយទៀត គឺលក្ខណៈ ឬ នៅបន្ទប់រង់ចាំខាងក្រោម ឬទៅមន្ទីរឃុំឃាំងនៃអ.វ.ត.ក។

[១៤:៣៥:០០]

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៍៖**

ដើម្បីបំភ្លឺរឿងរ៉ាវនេះបន្តិចទៅ ខ្ញុំគិតថា អង្គជំនុំជម្រះចង់ទាក់ទាញអារម្មណ៍របស់ភាគីទាំងអស់លើការណ៍ដែលថា វិធានផ្ទៃក្នុងចែងស្ថានភាពពីរខុសគ្នា។ ស្ថានភាពទីមួយដែលចែងនោះ គឺថាមានវិធាន៨១(១) កថាខណ្ឌទី៣។ វិធាននេះទាក់ទងករណីដែលថា ជនជាប់ចោទជំទាស់មិនព្រមបង្ហាញខ្លួន។ ហើយក្នុងរកណីនេះ គឺថាគេអាចបញ្ជូនគាត់មកអង្គជំនុំជម្រះ ហើយនិងគេបង្ហាញពីសិទ្ធិរបស់គាត់ដែលថាទទួលបានមេធាវីមួយការពារ។ ហើយគាត់ក៏អាចមិនព្រមទទួលមកបង្ហាញខ្លួនផងដែរ។ ក៏ប៉ុន្តែដើម្បីឲ្យច្បាស់លាស់មែនទែននោះ មានតម្លាភាពនោះ អង្គជំនុំជម្រះចង់ឲ្យថា រាល់ថ្ងៃគឺថាមុនចាប់ផ្ដើមសវនាការជារៀងរាល់ថ្ងៃនោះ គឺជនជាប់ចោទទាំងអស់នោះត្រូវតែមកបង្ហាញខ្លួន ដើម្បីបង្ហាញ ឬក៏បញ្ជាក់ពីឆន្ទៈរបស់ខ្លួនដែលថាមិនចង់មកបង្ហាញខ្លួននោះ។ តើច្បាស់លាស់ដែរឬទេ?

[១៤:៣៦:៤៧]

ការសន្និដ្ឋានទីពីរ គឺថាជាការសន្និដ្ឋានដែលចែងនូវកថាខណ្ឌទី៤ ឬថាមានចែងលទ្ធភាព គឺថាការមិនចង់មកចូលរួម-- មិនមែនទេគឺថាចង់ចូលរួមពីចម្ងាយ។ ការចូលរួមពីចម្ងាយនេះអាចគិតគ្រោងទៅបានគឺនៅក្នុងករណីដែលជនជាប់ចោទអាចបង្ហាញមូលហេតុសុខភាព ឬក៏មូលហេតុធ្ងន់ធ្ងរណាមួយ។ ដូច្នេះ បើសិនជាអង្គ-- ដើម្បីឲ្យអង្គជំនុំជម្រះអាចធ្វើសេចក្ដីសម្រេចបាន ត្រូវតែមានមូលហេតុសុខភាព ឬក៏មូលហេតុធ្ងន់ធ្ងរផ្សេងៗ ដែលជាមូលដ្ឋាននៃការចូលរួមពីចម្ងាយនេះ។

[១៤:៣៧:៤២]

ហើយទាក់ទងទៅនឹងជនជាប់ចោទទាំងពីរ ដែលមានវត្តមាននៅក្នុងសាលសវនាការនេះ អង្គជំនុំជម្រះយល់ឃើញថា ប្រហែលជាមានភាពខុសគ្នានៃស្ថានភាពរវាងជនជាប់ចោទ ខៀវ សំផន ហើយ

និងជនជាប់ចោទ អៀង សារី។ ជនជាប់ចោទ អៀង សារី ដូចដែលបានបង្ហាញឡើងអំពីមេធាវីរបស់ខ្លួននោះ គឺថាគាត់មានបញ្ហាផ្នែកសុខភាព ហើយទាក់ទងទៅនឹងជនជាប់ចោទ ខៀវ សំផន នោះ រហូតដល់ថ្ងៃនេះអង្គជំនុំជម្រះបានទទួលដំណឹងដែល--មិនមានទទួលដំណឹងអំពីបញ្ហាសុខភាពនោះទេ។ ហេតុដូច្នេះ គឺថាគាត់ជំទាស់ពីការពិនិត្យសុខាភិបាល ដោយសារគាត់ពុំមានបញ្ហាសុខភាព។

[១៤:៣៨:២៩]

ដើម្បីបញ្ជាក់បំភ្លឺអំពីបញ្ហានេះ គឺថាអង្គជំនុំជម្រះសូមឲ្យភាគីទាំងអស់ចាប់អារម្មណ៍ទៅនឹងភាពខុសគ្នារវាងកថាខណ្ឌ៣ និងកថាខណ្ឌ៤ នៃវិធានផ្ទៃក្នុង។ គឺកថាខណ្ឌ៤ និងកថាខណ្ឌ៥។

**លោក ម៉ៃខល កាណាវាស៖**

សូមអរគុណលោកចៅក្រម ហើយខ្ញុំនឹងលើកឡើងបញ្ហាមួយចំនួននៅពេលដែលខ្ញុំចូលរួម ខ្ញុំមិនមានចេតនានឹងធ្វើឲ្យរាំងស្ទះដំណាក់កាលណាមួយទេ ខ្ញុំចង់ចូលរួម ហើយខ្ញុំក៏បានសូមអភ័យទោសដែលថាលោកចៅក្រមណែនាំឲ្យខ្ញុំអង្គុយ។ ប៉ុន្តែ បើសិនជាករណីហ្នឹងជាការចាំបាច់ ខ្ញុំសូមអរគុណ។

ចំពោះខ្ញុំ ខ្ញុំយល់ថា កូនក្ដីរបស់ខ្ញុំមិនដែលបដិសេធថា មិនឲ្យពិនិត្យសុខភាពនោះទេ ហើយគាត់ក៏មិនដែលបដិសេធការពិនិត្យសុខភាពដែរ ហើយគឺវាចេញមកពីការបកប្រែ។

[១៤:៣៩:៣៩]

ឥឡូវនេះ វាមានហេតុការណ៍លំដាប់ទីបីមួយទៀតដែលខ្ញុំជូនជាឧទាហរណ៍ដែរ ក្នុងករណីដែលជនជាប់ចោទមិនចូលរួម គាត់មានចេតនា គឺថាដោយសារមិនមែនថាមានបញ្ហាសុខភាពទេ អាហ្នឹងមិនមែនជាបញ្ហាដែលយើងលើកឡើងនៅថ្ងៃនេះទេ។ ម្យ៉ាងវិញទៀត គាត់មិនបានទៅមន្ទីរពេទ្យទេ ប៉ុន្តែគាត់នៅតែមានបំណងនៅទីនេះ ដើម្បីឲ្យគាត់បានតាមដំណើរការនីតិវិធីអាចទៅមុខបាន។ កូនក្ដីរបស់ខ្ញុំនៅក្នុងកំណត់ត្រាវេជ្ជសាស្ត្រដែលអង្គជំនុំជម្រះក៏មានដែលនោះ គាត់មានជំងឺមួយចំនួនដែលជាប្រចាំកាយ។ គាត់អាយុ៨០ឆ្នាំហើយ ខ្ញុំមិនចាំបាច់ឲ្យឌុកទ័រប្រាប់ខ្ញុំនោះទេ ថាលោក អៀង សារី មានបញ្ហាដោយដូចថា មិនអាចផ្ដោតអារម្មណ៍បាននូវការស្ដាប់សវនាការ។ ខ្ញុំបានជួបគាត់បីឆ្នាំហើយ ពាក្យរបស់ខ្ញុំមិនអាចជាកត្តាគ្រប់គ្រាន់នោះទេ ហើយខ្ញុំ-- ដែលព្រះរាជអាជ្ញាលើកឡើងដោយខ្លួនឯងនេះ ខ្ញុំមិនប្រឌិតទេ។

[១៤:៤០:៤៧]

នៅក្នុងដំណាក់នីមួយៗ ដែលខ្ញុំថា ដែលថាជារៀងរាល់ថ្ងៃដែលពេលព្រឹក ឬពេលល្ងាច ដែលថា

ជនជាប់ចោទម្នាក់មិនអាចមកបាន វាត្រូវតែមានកំណត់ត្រាលាយលក្ខណ៍អក្សរដែលចុះហត្ថលេខាដោយជនជាប់ចោទ។ ដោយថាគាត់លើកបោះបង់សិទ្ធិដោយស្ម័គ្រចិត្តមិនចូលរួម។ ខ្ញុំមិនឯកភាពការសម្រេចណាដែលបង្ខំឱ្យជនជាប់ចោទណាម្នាក់វត្តមាននៅក្នុងសវនាការដោយគាត់មិនអាចចូលរួមបាននោះ។ ខ្ញុំគិតថា គឺជាការបំពានសិទ្ធិជនជាប់ចោទ បើសិនជាយើងបង្ខំគាត់ បើសិនជាគាត់មិនចង់ បើគាត់មិនចូលរួមទេ គាត់ជាជម្រើសរបស់គាត់ ជាសិទ្ធិរបស់គាត់។

[១៤:៤១:៣០]

ចំពោះករណីលោក អៀង សារី ល្ងាចនេះ គាត់មានជំងឺ គាត់ឈឺចុកចាប់ ហើយដូចជាមានការបង្ខំឱ្យគាត់អង្គុយ ហើយគាត់បានស្នើ ហើយសំណើនោះយ៉ាងច្បាស់ គាត់ចង់ចូលរួមក្នុងសវនាការល្ងាចនេះ។ គាត់ទៅបន្ទប់ខាងក្រោម នៅក្នុងបន្ទប់ដែលអង្គការសហប្រជាជាតិចំណាយលុយរៀបចំបន្ទប់នេះ ដើម្បីឱ្យដោះស្រាយនូវបញ្ហាករណីនេះ ដែលថានៅទីតាំងមួយដែលគាត់អាចទៅចូលរួម តម្រេតមើលតាមទូរទស្សន៍បាននោះ។

តាមពិត គាត់គឺថាមិនមានលទ្ធភាពចូលរួមបានទេ នៅថ្ងៃស្អែកគាត់នឹងប្រាប់មកយើងខ្ញុំ យើងខ្ញុំអាចនឹងពិនិត្យ ឬក៏ធ្វើសំណើ យើងនឹងជូនសំណើទៅអង្គជំនុំជម្រះ។ ហើយយើងរៀបចំនូវលិខិតដើម្បីឱ្យគាត់ចុះហត្ថលេខា ថាតើគាត់មិនចង់ចូលរួម ឬក៏គាត់មិនអាចចូលរួមបាន ដើម្បីឱ្យមានកំណត់ត្រាជាលាយលក្ខណ៍អក្សរ ដើម្បីដំណាក់បណ្តឹងសាទុក្ខ ឬក៏បណ្តឹងឧទ្ធរណ៍នោះ យើងមានឯកសារដើម្បីតទល់ថាគាត់មិនមានវត្តមាន ដោយសារថាគាត់មិនមានលទ្ធភាពចូលរួមបាន ហើយយើងមិនជំទាស់ថាគាត់អវត្តមាន សវនាការនឹងមិនយុត្តិធម៌នោះទេ។

[១៤:៤២:៥១]

**ប្រធានអង្គជំនុំ៖**

អញ្ជើញ!

**លោកស្រី អេលីហ្សាបេត ស៊ីម៉ុនណូហ្វត៖**

លោកប្រធាន, ខ្ញុំសូមសង្ខេបមានមេធាវីដើមបណ្តឹងរដ្ឋប្បវេណីអាស្រ័យលើសេចក្តីរបស់អង្គជំនុំជម្រះទាក់ទងទៅនឹងលក្ខណៈនៃការវិនិច្ឆ័យ។ ក៏ប៉ុន្តែគ្រាន់តែយើងសូមរំឭកថា ត្រូវតែគោរពសិទ្ធិរបស់បុគ្គលម្នាក់ៗ គឺថាបើវត្តមានរបស់ជនជាប់ចោទនោះ ក៏ជាការគោរពដល់ជនរងគ្រោះ ឬក៏ដើមបណ្តឹងរដ្ឋប្បវេណីដែរ ដែលថាពួកគាត់ទាំងអស់នេះក៏ចាស់ដូចគ្នាដែរ ហើយដែលគាត់ខំប្រឹងមកទីនេះ។ ហើយ

ចំពោះគាត់នោះ គឺថាវត្តមាននោះ គឺជាការសំខាន់ណាស់ ហើយដែលគាត់-- ដូច្នេះបើសិនជាអាចធ្វើបាន នោះ គឺថាសូមឲ្យជនជាប់ចោទទាំងអស់មានវត្តមាន។

*(ចៅក្រមពិភាក្សាគ្នា)*

[១៤:៤៨:២៨]

**ប្រធានអង្គជំនុំ៖**

ក្រោយពីបានស្ដាប់នូវសំណើសុំរបស់មេធាវីការពារក្ដីលោក អៀង សារី ហើយនិងស្ដាប់នូវសារណាតបរបស់សហព្រះរាជអាជ្ញា និងមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណី។ ក្រោយពីបានពិភាក្សាលើដំណើរសុំរបស់មេធាវី អង្គជំនុំជម្រះយល់ឃើញថា ការបង្ហាញនូវមូលហេតុ និងស្ថានភាពនៃជំងឺ និងសុខភាពរបស់ជនជាប់ចោទរូបនេះ មានបញ្ហាពិតប្រាកដដែលអាចឲ្យតុលាការជឿបាន។ ហេតុដូច្នេះអង្គជំនុំជម្រះយល់ព្រមអនុញ្ញាតឲ្យលោក អៀង សារី ទៅសម្រាកនៅបន្ទប់ខាងក្រោមដែលបានរៀបចំរួចជាស្រេចសម្រាប់ដំណើរការសវនាការពីចម្ងាយតាមប្រព័ន្ធសោតទស្សន៍។

[១៤:៤៩:៤៨]

ទីពីរ អង្គជំនុំជម្រះសូមបញ្ជាក់សាជាថ្មីម្ដងទៀតថា ចំពោះជនជាប់ចោទទាំងអស់ អង្គជំនុំជម្រះតម្រូវឲ្យអនុរក្សមន្ទីរឃុំឃាំងនាំខ្លួនមកកាន់បន្ទប់សវនាការជារៀងរាល់ព្រឹកសម្រាប់ថ្ងៃនីមួយៗ។ ចំណែកឯបញ្ហាផ្សេងៗដែលអាចកើតឡើងនៅក្នុងថ្ងៃនីមួយៗនោះ អង្គជំនុំជម្រះនឹងពិនិត្យទៅលើសំណើជាក់ស្ដែងករណីនីមួយៗ នឹងសម្រេចទៅតាមស្ថានភាពជាក់ស្ដែងថាតើអនុញ្ញាត ឬមិនអនុញ្ញាត?

អនុរក្សមន្ទីរឃុំឃាំងនាំលោក អៀង សារី ទៅកាន់បន្ទប់រងចាំដែលបានរៀបចំទុក ដើម្បីឲ្យគាត់ទៅដំណើរការតាមដាន និងដំណើរការនីតិវិធីសវនាការនេះតាមប្រព័ន្ធសោតទស្សន៍។

*(ជនជាប់ចោទចាកចេញពីបន្ទប់សវនាការ)*

[១៤:៥១:១៤]

ជាកិច្ចបន្ត អង្គជំនុំជម្រះសូមអញ្ជើញសហព្រះរាជអាជ្ញាឡើងធ្វើសេចក្ដីថ្លែងការណ៍តបទៅនឹងអំណះអំណាងរបស់មេធាវីអៀង សារី ដែលបានលើកឡើងកាលពីព្រឹកមិញពាក់ព័ន្ធនឹងបញ្ហាអញ្ញត្រកម្ម គោលការណ៍គ្មានការកាត់ទោសពីរដងចំពោះបទល្មើសតែមួយ។ ហើយអង្គជំនុំជម្រះសូមបញ្ជាក់ផងដែរថា កាលពីព្រឹកមិញ សហព្រះរាជអាជ្ញាបានដាក់សំណើមួយសុំមកអង្គជំនុំជម្រះសុំឆ្លើយតបទៅនឹងកំណត់សម្គាល់របស់មេធាវី នួន ជា ដែលបានលើកឡើងកាលពីព្រឹកមិញ ដោយមេធាវីការពារក្ដីអាក់

ខានមិនបានលើកឡើងនូវបញ្ហានេះ ហើយសុំពេលវេលាដើម្បីឆ្លើយតប អង្គជំនុំជម្រះអនុញ្ញាតបន្ទាប់ពីសហព្រះរាជអាជ្ញាធ្វើសេចក្ដីសន្និដ្ឋានតបទៅនឹងបញ្ហាអញ្ញត្រកម្មដែលបានលើកឡើងបញ្ជាក់អម្បាញ់មិញនេះ ដែលជារបៀបកម្មវត្ថុនៃការពិភាក្សា។ ហើយចំណែកឯការឆ្លើយតបទៅនឹងមេធាវី នួន ជា អង្គជំនុំជម្រះអនុញ្ញាតឲ្យពេលវេលាប្រាំនាទី។ សូមអញ្ជើញ!

[១៤:៥២:៤៥]

**លោក ម៉ៃខល កាណាវាស៖**

សូមលោកប្រធានបំភ្លឺអ្វីដែលខ្ញុំបានលើកកាលពីព្រឹកមិញ ខ្ញុំប្រហែលជាមិនច្បាស់ទេ ចំណុចមួយនៅពេលដែលខ្ញុំបង្ហាញថា នៅក្នុងមតិរបស់ខ្ញុំថា អង្គជំនុំជម្រះសាលាឧទ្ធរណ៍ ខ្ញុំដក ទាក់ទងទៅនឹងមាត្រា១២ នៃក្រមព្រហ្មទណ្ឌ-- នីតិវិធីព្រហ្មទណ្ឌកម្ពុជានោះ ដែលចែងថាមាត្រា១២ នៃក្រមនេះ ដូចដែលបានចែងខាងលើនៅក្នុងកថាខណ្ឌ៤៥ ដែលអាចចាត់ទុកជាឧទាហរណ៍នៃការស្នើសុំ សេចក្ដីដកស្រង់នោះគឺថាចេញមកពី សេចក្ដីសម្រេចពីមុន គឺថាគឺចេញពីសេចក្ដីសម្រេច ចុះថ្ងៃទី១៧ តុលា ឆ្នាំ២០០៨ នៅក្នុងកថាខណ្ឌ៤៧ នៃឯកសារនោះ C22/1/73 ខ្ញុំសូមបំភ្លឺអំពីចំណុចនេះ ដើម្បីកុំឲ្យភ័ន្តច្រឡំថាដកស្រង់មកពីឯកសារណាមួយនោះ ថ្ងៃទី១៧ តុលា ឆ្នាំ២០០៨។

[១៤:៥៤:០៣]

**ប្រធានអង្គជំនុំ៖**

លោកមេធាវីត្រូវការចំណាយពេលវេលាប៉ុន្មាន? តាមខ្ញុំចាំព្រឹកមិញ គឺមេធាវីបានប្រើប្រាស់ម៉ោងដែលបានចែងឲ្យអស់ហើយ។ នៅក្នុងការកំណត់បង្ហាញរបស់អង្គជំនុំជម្រះបានបញ្ជាក់ច្បាស់លាស់ណាស់ថា មិនឲ្យមេធាវីលើកឡើងនូវបញ្ហាដដែលៗ ដែលបានធ្វើសរសេរជាសារណាជាលាយលក្ខណ៍អក្សរជូនមកដល់អង្គជំនុំជម្រះរួចហើយ ប៉ុន្តែផ្ទុយទៅវិញមេធាវីបានប្រើប្រាស់នូវការបង្ហាញដដែលៗនៅក្នុងសេចក្ដីថ្លែងការណ៍ដោយផ្ទាល់មាត់នៅពេលនេះ។ អ៊ីចឹង ធ្វើឲ្យពេលវេលានោះវាអស់គឺមួយម៉ោងគត់ ព្រឹកមិញគឺរាប់ចាប់ផ្ដើមពីពេលចាប់ផ្ដើមរហូតដល់ពេលចប់។ ឥឡូវនេះ បើលោកបញ្ហាអីទៀត ថាតើលោកត្រូវការពេលវេលាប៉ុន្មាន ដើម្បីអង្គជំនុំជម្រះពិចារណា ពីព្រោះបញ្ហាលោកត្រូវនិយាយឲ្យច្បាស់លាស់ ហើយដាច់ខាតតែម្ដង ពីព្រោះអង្គជំនុំជម្រះបានបែងចែកពេលឲ្យលោកច្បាស់លាស់ហើយ មួយម៉ោងទាំងការរបៀបវារៈដែលបានបញ្ជូនឲ្យ ទាំងការកំណត់ព្រឹកមិញ។

[១៤:៥៥:១០]

**លោក ម៉ៃខល កាណាវាស៖**

សូមលោកប្រធាន ខ្ញុំគ្រាន់តែសុំអនុញ្ញាតបំភ្លឺតែប៉ុណ្ណោះ គឺថាអាចនឹងមានការបកប្រែខ្វះដោយខ្ញុំនិយាយ។ មិនមែនជាទឡ្ហីករណ៍អ្វីបន្ថែមទេ ព្រឹកមិញនេះនៅពេលខ្ញុំពិភាក្សាអំពីទំនាក់ទំនងមាត្រា៧ និងមាត្រា១២ ខ្ញុំអាចនឹងផ្តល់ការលើកឡើងមិនត្រឹមត្រូវនៅពេលដែលខ្ញុំដកស្រង់អ្វី ដែលអង្គបុរេជំនុំជម្រះបានរកឃើញនោះ។ សេចក្តីដកស្រង់នោះ ដែលខ្ញុំលើកឡើងនោះថា អង្គបុរេជំនុំជម្រះបានលើកឬក៏បានរកឃើញថាមាត្រា១២ ត្រូវចាត់ទុកជាឧទាហរណ៍នៃការអនុវត្តនូវអាជ្ញាអស់ជំនុំដែលមានចែងនៅក្នុងដីកាឃុំខ្លួនបណ្តោះអាសន្ន ថ្ងៃទី១៧ តុលា ឆ្នាំ២០០៨ មិនមែនយោងទៅរកដីកាដំណោះស្រាយនោះទេ។ ខ្ញុំគ្រាន់តែសុំបំភ្លឺចំណុចហ្នឹង ដើម្បីឲ្យភាគីទាំងអស់បានយល់ឲ្យបានច្បាស់តែប៉ុណ្ណោះទេ។

ចំណុចនេះមានចែងនៅក្នុងកថាខណ្ឌទី៤៧នៃដីកានោះ។ នេះជាចំណុចតែមួយគាត់ លោកប្រធានដែលខ្ញុំចង់បំភ្លឺដែលសហភាតារបស់ខ្ញុំបញ្ជាក់ប្រាប់ខ្ញុំថា ប្រហែលជាខ្ញុំយោងទៅរកឯកសារខុស។ សូមអភ័យទោសដែលខ្ញុំបានលើកឡើងគំនិតនេះជាថ្មី។ សូមអរគុណ។

[១៤:៥៦:៤១]

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញសហព្រះរាជអាជ្ញា។

**លោក អាន់ឌ្រូ ខេលី៖**

សូមអរគុណលោកប្រធាន។ ហើយខ្ញុំនឹងសុំបំភ្លឺ ហើយសូមអរគុណចំពោះការបំភ្លឺរបស់លោកម៉ៃខល កាណាវាស ដែលថាគាត់បានលើកឡើងថា នៅក្នុងអង្គជំនុំជម្រះសាលាឧទ្ធរណ៍ តែតាមពិតគឺអង្គបុរេជំនុំជម្រះទេ មិនមែនសាលាឧទ្ធរណ៍នោះទេ។

លោកប្រធានសូមអរគុណ ខ្ញុំត្រូវការពេលតែប្រាំនាទី ដើម្បីលើកលែងសារណារបស់ខ្ញុំ ដែលលើកឡើងដោយមេធាវីការពាររបស់លោក នួន ជា នោះ។ ចំណុចមួយចំនួនគប្បីលើកឡើងឲ្យបានច្បាស់បញ្ជាក់បញ្ហាមួយចំនួនឲ្យសាធារណជនបានច្បាស់ ជាពិសេសអង្គជំនុំជម្រះសាលាដំបូងបានដឹងអ្វីដែលខ្ញុំនឹងលើកឡើងនោះគឺថាក្នុងគោលបំណងឲ្យប្រជាជនបានពិនិត្យមើលទូទាំងពិភពលោក ហើយចំណុចណាខ្លះឲ្យបានច្បាស់ៗ។

[១៤:៥៧:៤៣]

ចំណុចទីមួយ មេធាវីការពារ នួន ជា បញ្ជាក់ថា ហើយលើកឡើងថាកូនក្តីរបស់គាត់ត្រូវបានរង

ការស៊ើបអង្កេតដោយសម្ងាត់ តែតាមពិតគឺថាក្រុមមេធាវីហ្នឹង គឺបានដឹងជាបន្តបន្ទាប់នៅដំណាក់កាលកិច្ចស៊ើបអង្កេតក្នុងដំណាក់បួនឆ្នាំ ចាប់តាំងពីទទួលបានដីកាបញ្ជូនទៅស៊ើបសួរនោះ ក្នុងករណីដែលឯកសារដែលការជំនុំជម្រះនេះយកមកប្រើនោះ គឺថាអាចមេធាវីពិនិត្យមើលបានគ្រប់ពេលវេលា ដោយក្រុម នួន ជា នោះដែរ។ តាមពិតគឺថាជាឯកសារដែលមានរក្សាការសម្ងាត់ចំពោះសាធារណជន អាហ្នឹងគឺជាលក្ខខណ្ឌនៃការស៊ើបអង្កេតនៅក្នុងប្រព័ន្ធច្បាប់នៃ អ.វ.ត.ក ដែលតាមពិតនៅពេលនេះភស្តុតាងហ្នឹង គឺថាអាចក្លាយទៅជាឯកសារសាធារណៈ គឺថាមិនមែនតែអង្គជំនុំជម្រះសាលាដំបូងទេ សាធារណជនក៏អាចពិនិត្យមើលបានដែល នៅក្នុងដំណាក់កាលសវនាការនេះដែលបញ្ជាក់ថា ថាតើលោក នួន ជា ត្រូវបានរងការស៊ើបអង្កេតដោយសម្ងាត់ហ្នឹង គឺជាសេចក្តីថ្លែងការណ៍មិនត្រឹមត្រូវទេ។ មេធាវីការពាររបស់ នួន ជា និយាយថាកូនក្តីរបស់ខ្លួន សំណើសុំស៊ើបអង្កេតបន្ថែម២៦ ត្រូវបានបដិសេធ។ ការអះអាងនេះក៏មិនត្រូវដែល សំណើមួយចំនួនដែលគេបានស្នើសុំនោះ ត្រូវបានទទួលស្គាល់ទាំងស្រុង ឬក៏មួយផ្នែកដោយសហចៅក្រមអង្កេត ហើយមួយចំនួនត្រូវបានបដិសេធ។ អ៊ីចឹងគឺថាករណីនេះ ភាគីទាំងអស់ជួបប្រទះដូចគ្នា មិនមែនគ្រប់តែសំណើត្រូវបានអនុញ្ញាតនោះទេ។ មេធាវីការពារក៏បានដឹងផងដែរថា គេមានឱកាសនៅក្នុងដំណើរនីតិវិធីនេះ ខ្លួនមានសំណើសុំឲ្យអង្គជំនុំជម្រះសាលាដំបូងស៊ើបអង្កេតនៅតាមវិធាន៩៣ឡើងវិញ ប្រសិនបើសហព្រះរាជអាជ្ញា ក៏មានការឆ្លើយតប ដែលថាយើងរង់ចាំសេចក្តីសម្រេចពីសាលាដំបូងនេះដែរ។

[១៤:៥៩:៤៦]

សហព្រះរាជអាជ្ញាមានគោលជំហរច្បាស់លើបញ្ហានេះ យើងជឿជាក់ថាការជំនុំជម្រះនេះត្រូវតែយុត្តិធម៌លឿន ហើយយើងគាំទ្ររាល់សំណើទាំងអស់ចេញពីភាគីណាក៏ដោយ កាលណាមានសក្តានុពល ដើម្បីបង្ហាញនូវភស្តុតាងដែលកំណត់ពីពិរុទ្ធភាព ឬភាពគ្មានទោសនៃជនជាប់ចោទណាម្នាក់។

អ្វីៗក៏ដោយ គឺថា វាទាក់ទងទៅនឹងការទទួលខុសត្រូវខាងព្រហ្មទណ្ឌ ប៉ុន្តែសូមបញ្ជាក់ថាមិនមែនគ្រប់តែសំណើសុំស៊ើបអង្កេតហ្នឹង ដែលស្នើឡើងដោយភាគីនោះសុទ្ធតែសំខាន់នៅក្នុងកំណត់គោលការណ៍សំខាន់ៗនៃរឿងក្តីនោះទេ។ ក៏ប៉ុន្តែ សំណើខ្លះក៏វាអាចមានការទាក់ទងតិច ឬក៏ច្រើនទាក់ទងទៅនឹងដំណើរការនីតិវិធីដែលវិវត្តទៅ។ ប៉ុន្តែ អ្វីដែលថាជាការបដិសេធទាំងស្រុង ដែល នួន ជា បានលើកឡើងនោះ គឺថាមិនមែនជាសេចក្តីថ្លែងការណ៍ត្រឹមត្រូវនោះទេ។

[១៥:០០:៤៤]

មេធាវីរបស់ នួន ជា បានបញ្ជាក់ព្រឹកមិញថា គឺថាមានសាក្សីជាង៣០០នាក់ ដែលខ្លួនបានស្នើ ហើយមិនបានពិចារណានោះទេ។ យើងត្រូវចងចាំថានៅក្នុងបញ្ជីដំបូងរបស់គេនោះ គេមាន៥៧០ជាង ឯណោះ ដែលអ្នកទាំងអស់នោះ គឺយើងយល់ឃើញថា ជាចំនួនសមាមាត្រតូចមួយដែលថា បង្ហាញ ភស្តុតាងអាចនឹងទាក់ទងទៅនឹងបទឧក្រិដ្ឋ ឬក៏តួនាទីរបស់ជនជាប់ចោទនៅក្នុងរឿងក្តីនេះដែរ។ មេធាវី ក៏បានដាក់សាក្សីជាច្រើនដែលបង្ហាញអំពីលក្ខខណ្ឌទូទៅ តួនាទីរបស់អង្គការសហប្រជាជាតិនៅក្នុង កម្ពុជាប្រជាធិបតេយ្យ លក្ខខណៈទូទៅនៃកម្ពុជាប្រជាធិបតេយ្យ...។ល។ ប៉ុន្តែ បានផ្តល់ព័ត៌មាន តិចតួចណាស់ទាក់ទងទៅនឹងភស្តុតាងដែលខ្លួនចង់ប្រើនោះ ដែលជួយដល់ចៅក្រមក្នុងការកំណត់នៅ បញ្ហាដែលមានចែងនៅក្នុងដីកាដំណោះស្រាយនោះទេ។

មេធាវីការពាររបស់នួន ជា មិនបានជំទាស់ទៅនឹងសាក្សីប្រហែលជា៣០០នាក់ ដែលសហព្រះ រាជអាជ្ញាបានលើកឡើងដែលថាវិធានតម្រូវឱ្យយើងដាក់បួនខែ គឺថាមានន័យថា ពួកគាត់បានយល់ ទៅនឹងការបង្ហាញបញ្ជីសាក្សីនេះ ហើយនិងអាចនឹងផ្តល់នូវទាក់ទងទៅនឹងព័ត៌មានដែលមានតម្លៃជា ភស្តុតាងនោះ ហើយគេមានសិទ្ធិសួរសំណួរទៅសាក្សីទាំងអស់នោះទាក់ទងទៅនឹងរឿងក្តីនេះបានដែរ។

[១៥:០២:១៦]

យើងក៏បានបញ្ជាក់ដែលថា នៅក្នុងដំណាក់កាលនេះ គឺថាអ្វីដែលគេលើកឡើងនេះគឺថាវាមិន សមស្របតាមពេលវេលាទេ ដែលថាអង្គជំនុំជម្រះមិនទាន់បានបញ្ជាក់ថា ដែលថាបញ្ជីសាក្សីនោះនឹង ត្រូវពិភាក្សានៅថ្ងៃព្រហស្បតិ៍ឯណោះទេ។ ដូច្នេះ ខ្លួនអាចត្រៀមដើម្បីពិភាក្សា។ គឺថាវាទាក់ទងទៅ នឹងបញ្ហាការជំនុំជម្រះដោយយុត្តិធម៌ មេធាវីការពារ នួន ជា បានលើកឡើង គឺថាជាកម្មវត្ថុនៃ ដើម្បី បញ្ជាក់ដល់សាធារណជនឱ្យបានដឹងឱ្យច្បាស់ថា ការតវ៉ារបស់គេនោះត្រូវបានបដិសេធ។ ដូច្នេះការណ៍ ដែលលើកឡើងនូវចំណុចហ្នឹងធ្វើឱ្យសាធារណជនអាចនឹងភ័ន្តច្រឡំ។ នេះហើយដែលយើងត្រូវឆ្លើយ តបវិញ គឺត្រូវតុលាការពិចារណា ហើយសាធារណជនក៏ចង់ដឹងអំពីហេតុការណ៍នេះ។

[១៥:០៣:០៩]

នៅចំណុចចុងក្រោយយើងសូមបញ្ជាក់ឡើងវិញថា ដោយសេចក្តីគោរពថា យើងទទួលស្គាល់ អំពីការទទួលខុសត្រូវរបស់អង្គជំនុំជម្រះសាលាដំបូង ការទទួលខុសត្រូវនោះគឺដើម្បីគ្រប់គ្រងសវនាការ នេះ។ បញ្ហាទាំងអស់ដែលមេធាវីការពារបានលើកឡើងនោះ គឺជាបញ្ហាដែលលោក លោកស្រីចៅក្រម ត្រូវពិចារណាសម្រេចដោយច្បាស់លាស់ ដោយប្រុងប្រយ័ត្ន ហើយពិនិត្យតាមដំណាក់កាលថ្ងៃទីមួយនៃ

សវនាការ ដែលបង្ហាញពីជនជាប់ចោទ ឬក៏មេធាវីការពារ ឬក៏ជនជាប់ចោទ ថាគាត់មិនចង់ចូលរួម គាត់មានចេតនានឹងធ្វើដូច្នោះ។ ហើយយើបានពិភាក្សា ហើយលោក កាណាវាស ក៏បានលើកឡើង ពីបញ្ហាហ្នឹងដែរ ថាតើបើសិនជាគាត់មិនមានចេតនាចូលរួម គាត់ចុះហត្ថលេខាលើលិខិតបោះបង់សិទ្ធិ ហើយយើងក៏ច្បាស់ដែលថា មានហេតុផលជាច្រើនដែលមេធាវី-- ជាមូលហេតុដែលមេធាវីការពារថា សុំឱ្យខ្លួនបានឱ្យកូនក្ដីរបស់ខ្លួនទៅនោះ ពេលខ្លះគឺសាធារណជនអាចយល់ថា មិនមែនជាការពិតជាមូលហេតុគាំទ្រដែលនឹងថា សុំដកខ្លួនចេញពីសវនាការនោះ។ ហើយភាគីទាំងអស់គឺថា សាធារណជនចង់ដឹង គឺថាភាគីទាំងអស់គឺត្រូវមានកាតព្វកិច្ចបង្ហាញនូវសាធារណជន។ ដូច្នេះ ថាតើនៅខាងក្រៅសវនាការនេះ បើសិនជាជនជាប់ចោទថយទៅ វាមានការចូលរួមជាក់ស្ដែង សាធារណជនយល់យ៉ាងដូចម្ដេច? អាចហ្នឹងជាកត្តាមួយ។ អ៊ីចឹង សូមបញ្ចប់ សូមអរគុណលោកប្រធាន។

[១៥:០៥:៤២]

**ប្រធានអង្គជំនុំ៖**

អរគុណសហព្រះរាជអាជ្ញា។ ហើយជាបន្ត គឺសេចក្ដីថ្លែងការណ៍តបទៅនឹងអញ្ញត្រកម្មគោល-ការណ៍នៃការមិនកាត់ទោសលើសពីមួយម្ដងចំពោះអង្គហេតុ ឬក៏បទល្មើសតែមួយចំពោះអង្គហេតុ ឬក៏បទល្មើសតែមួយដែលមេធាវីការពារក្ដី អៀង សារី បានធ្វើបទបង្ហាញកាលពីព្រឹកមិញហើយ។

**លោកស្រី ជា លាង៖**

សូមអរគុណ ខ្ញុំនឹងធ្វើសេចក្ដីសន្និដ្ឋានតបលើគោលការណ៍គ្មានការកាត់ទោសពីរដងចំពោះអង្គហេតុតែមួយ។ សូមគោរពអង្គសវនាការទាំងមូល។ ចំពោះមុខអង្គសវនាការបឋមនេះ លោកមេធាវីការពារក្ដីរបស់ជនជាប់ចោទ អៀង សារី បានលើកឡើងទៅនឹងអញ្ញត្រកម្មមួយដែលថា ការនាំយក អៀង សារី មកកាត់ទោសនាពេលនេះ គឺជាការរំលោភសិទ្ធិ អៀង សារី ពីព្រោះ អៀង សារី ត្រូវបានតុលាការប្រជាជនបដិវត្តន៍នៅភ្នំពេញកាត់ទោសរួចហើយ គឺកាត់ទោសកាលពីថ្ងៃទី១៥ ខែសីហា ឆ្នាំ១៩៧៩ តែបើអង្គជំនុំជម្រះសាលាដំបូង អ.វ.ត.ក លើកយកករណី អៀង សារី មកកាត់សេចក្ដីពេលនេះទៀត គឺជាការកាត់ទោសពីរដងលើអង្គហេតុតែមួយ។ មុននឹងលើកឡើងនូវបញ្ហាទាំងនេះ សហព្រះរាជអាជ្ញាសូមទាញការចាប់អារម្មណ៍ចំពោះការលើកឡើងអំពីគោលការណ៍នៃអាជ្ញាអស់ជំនុំ ដែលលោកសហមេធាវីជាតិការពារក្ដីឱ្យលោក អៀង សារី ថា គោលការណ៍មិនអាចលើកយកមកធ្វើការចោទប្រកាន់ម្ដងទៀតទេចំពោះបទល្មើសដដែល។ ខ្ញុំសូមបញ្ជាក់ថា គោលការណ៍នៃអាជ្ញាអស់ជំនុំដែល

មានចែងនៅក្នុងមាត្រា១២ នៃក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា គឺបានចែង អំពីការហាមឃាត់មិនឲ្យមានការចោទប្រកាន់ជាថ្មីម្តងទៀតចំពោះអំពើដដែល។ ហើយនៅក្នុងមាត្រានេះ ក៏បានបញ្ជាក់យ៉ាងច្បាស់ទៀតថា ទោះបីជាកំណត់ឈ្មោះបទល្មើសថ្មីផ្សេងទៀតក៏ដោយ។ នេះគឺបញ្ជាក់ឲ្យឃើញថា អំពើនោះគឺអាចមានបទល្មើសច្រើនដែលខុសពីអ្វីដែលសហមេធាវីបានលើកឡើង។

ដូច្នេះឃើញថា លោកមេធាវីមានការភ័ន្តច្រឡំរវាងបទល្មើសនិងអង្គហេតុនេះ។

[១៥:០៧:២៧]

ក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជានៅឆ្នាំ២០០៧ រៀបរាប់លម្អិតតែអំពីគោលការណ៍មួយដែលទាក់ទងទៅនឹងការលើកលែងការចោទប្រកាន់តែប៉ុណ្ណោះ ហើយមិនមែនទាក់ទងនឹងការសម្រេចថាត្រូវមានទោសនោះទេ។ អាស្រ័យហេតុនេះមិនអាចយកវាមកអនុវត្តដើម្បីរារាំងមិនឲ្យធ្វើការចោទប្រកាន់ចំពោះ អៀង សារី នាពេលនេះបានឡើយ។

បន្ទាប់មក សហព្រះរាជអាជ្ញាអន្តរជាតិគឺលោក អាន់ឌ្រូ ខេលី នឹងលើកឡើងអំពីគោលការណ៍អន្តរជាតិគ្មានការកាត់ក្តីពីរដងចំពោះអង្គហេតុតែមួយដោយហេតុថាការវិនិច្ឆ័យទោសក្នុងឆ្នាំ១៩៧៩ មិនបានធ្វើឡើងទៅតាមបទដ្ឋានត្រឹមត្រូវនិងយុត្តិធម៌។ គាត់ក៏នឹងលើកឡើងផងដែរថា ទាំងនៅក្នុងកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋនិងសិទ្ធិនយោបាយ និងទាំងវិធាននីតិវិធីអន្តរជាតិនានា គឺជាគោលការណ៍គ្មានការកាត់ក្តីពីរដងចំពោះអង្គហេតុតែមួយ។

[១៥:០៨:៣៥]

អៀង សារី ត្រូវបានតុលាការប្រជាជនបដិវត្តន៍នៅទីក្រុងភ្នំពេញប្រកាសផ្តន្ទាទោសប្រហារជីវិត និងពីបទប្រល័យពូជសាសន៍ដែលបានប្រព្រឹត្តក្នុងអំឡុងពេលកាន់អំណាច ៣ឆ្នាំ ៨ខែ និង២០ថ្ងៃ។ តុលាការបានបើកសវនាការកាលពីថ្ងៃទី១៥ ដល់ថ្ងៃទី១៩ ខែសីហា ឆ្នាំ១៩៧៩ ហើយបានអនុវត្តទៅតាមក្រឹត្យច្បាប់ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ១៩៧៩ ស្តីពីការបង្កើតតុលាការប្រជាជនបដិវត្តន៍នៅទីក្រុងភ្នំពេញ ដើម្បីជំនុំជម្រះឧក្រិដ្ឋកម្មប្រល័យពូជសាសន៍នៃរបបដឹកនាំដោយប៉ុល ពត និង អៀង សារី។

តុលាការប្រជាជនបដិវត្តន៍បានប្រកាសផ្តន្ទាទោសប្រហារជីវិត ប៉ុល ពត និង អៀង សារី និងរឹបអូសយកទ្រព្យសម្បត្តិទាំងអស់ដោយកំបាំងមុខ និងបិទផ្លូវតវ៉ា។ នៅក្នុងសាលក្រមនេះដែរ បានកំណត់អង្គហេតុពាក់ព័ន្ធនឹងឧក្រិដ្ឋកម្មដែលប្រព្រឹត្តឡើងដោយរបបកម្ពុជាប្រជាធិបតេយ្យក្នុងរយៈពេល ៣ឆ្នាំ ៨ខែ និង២០ថ្ងៃ ដោយកំណត់បទល្មើសតែមួយ គឺបទប្រល័យពូជសាសន៍។ តែបើយើងពិនិត្យ

មើលសំណុំរឿង០០២ ចុះថ្ងៃទី១៩ ខែកញ្ញា ឆ្នាំ២០០៧ របស់ អ.វ.ត.ក នាពេលបច្ចុប្បន្ននេះ គឺមានអង្គហេតុ ជាច្រើនបានដាក់បន្ទុកទៅលើ អៀង សារី។ អង្គហេតុទាំងនោះ បានកំណត់នៅបទចោទជាច្រើនដូចជា បទឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ បទបំពារបំពានយ៉ាងធ្ងន់ធ្ងរទៅលើអនុសញ្ញាទីក្រុងហ្សឺណែវ ថ្ងៃទី១២ ខែសីហា ឆ្នាំ១៩៤៩ បទប្រល័យពូជសាសន៍ និងបទឧក្រិដ្ឋកម្មដែលមានចែងនៅក្នុងក្រមព្រហ្មទណ្ឌ កម្ពុជាឆ្នាំ១៩៥៦។ ដោយបទចោទទាំងអស់នេះមានចែងលម្អិតនៅក្នុងដីកាដំណោះស្រាយរបស់សហចៅក្រមស៊ើបអង្កេត។

តុលាការប្រជាជនបដិវត្តន៍នៅទីក្រុងភ្នំពេញបានបើកសវនាការដេញដោលមានរយៈពេលតែ ៥ថ្ងៃ ពីថ្ងៃទី១៥ ដល់ថ្ងៃទី១៩ ខែសីហា ឆ្នាំ១៩៧៩ នឹងត្រូវបានបញ្ចប់នៅថ្ងៃនោះ នៅវេលាម៉ោង ១១ថ្ងៃត្រង់។ ម្យ៉ាងទៀត តុលាការប្រជាជនបដិវត្តន៍នៅពេលនោះមិនបានបើកធ្វើការស៊ើបអង្កេតឲ្យបានទូលំទូលាយចំពោះឧក្រិដ្ឋកម្មដែលមានលក្ខណៈធ្ងន់ធ្ងរនិងស្មុគស្មាញ ហើយដែលមានទីតាំងឧក្រិដ្ឋ-កម្មជាច្រើន ពាសពេញប្រទេស និងមានជនរងគ្រោះស្លាប់ជិតពីរលាននាក់នោះទេ។

[១៥:១១:១៥]

ទោះបីតុលាការប្រជាជនបដិវត្តន៍បានដំណើរការដោយមានការខ្វះចន្លោះខ្លះលើនីតិវិធីច្បាប់ និងខ្វះធនធានមនុស្សជាសារវន្តក៏ពិតមែនក៏ដោយ ក៏តុលាការប្រជាជនបដិវត្តន៍នៅភ្នំពេញបានផ្តន្ទាទោស ប៉ុល ពត និងអៀង សារី ដើម្បីឆ្លើយតបទៅនឹងកំហឹងឈឺចាប់របស់ប្រជាជនកម្ពុជាដែលនៅរស់រានមានជីវិតចំពោះរបបកម្ពុជាប្រជាធិបតេយ្យ។ ការឈឺចាប់របស់ប្រជាជនកម្ពុជាក្រោមរបបនេះ រួមមានទាំងស្មារតីនិងរូបរាងកាយដែលមិនអាចរកអ្វីមកប្រៀបបានឡើយ ពីព្រោះថា វាជារបបមួយដ៏សាហាវយង់ឃ្នងជាទីបំផុតសម្រាប់ប្រទេសកម្ពុជា។

អង្គសវនាការជាទីគោរព! នាបច្ចុប្បន្ននេះ ប្រសិនបើយើងធ្វើការប្រៀបធៀបអំពីដំណើរការតុលាការប្រជាជានបដិវត្តន៍នៅទីក្រុងភ្នំពេញ និងដំណើរការតុលាការ អ.វ.ត.ក ឃើញថា ប្រសិនបើយកលិខិតុបករណ៍អន្តរជាតិដូចជា កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋនិងសិទ្ធិនយោបាយ ដែលមានចែងអំពីសិទ្ធិជាមូលដ្ឋានរបស់ជនជាប់ចោទ តម្រូវឲ្យមានមេធាវីការពារក្តីដោយឯករាជ្យ និងសវនាការចំពោះមុខជនជាប់ចោទ ឃើញថា តុលាការប្រជាជនបដិវត្តន៍នៅភ្នំពេញមិនបានបំពេញនូវលក្ខខណ្ឌទាំងអស់នេះប្រកបដោយសមរម្យទេ ប៉ុន្តែនៅពេលដែលដំណើរការតុលាការនេះ នៅពេលនោះប្រទេសកម្ពុជាមិនទាន់ក្លាយជាហត្ថលេខីនៃកតិកាសញ្ញាស្តីពីសិទ្ធិពលរដ្ឋនិងសិទ្ធិនយោបាយនៅឡើយដែរ។

ប្រទេសកម្ពុជាបានក្លាយជាហត្ថលេខីនៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយនៅឆ្នាំ១៩៩២ ដោយឧត្តមក្រុមប្រឹក្សាជាតិជាន់ខ្ពស់កម្ពុជាដែលជាស្ថាប័នស្របច្បាប់តែមួយគត់របស់កម្ពុជាមុនពេលមានការបោះឆ្នោតដោយសេរី និងទូទៅមួយដែលរៀបចំដោយអាជ្ញាធរបណ្តោះអាសន្នរបស់អង្គការសហប្រជាជាតិប្រចាំនៅកម្ពុជាឆ្នាំ១៩៩៣ ដែលហៅកាត់ថា អ៊ុនតាក់។

ដោយសារតុលាការប្រជាជនបដិវត្តន៍មានកង្វះខាតលើមូលដ្ឋានខ្លះ និងគោលការណ៍បទដ្ឋានសំខាន់ខ្លះ នៅក្នុងដំណើរការនីតិវិធីជំនុំជម្រះនៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូងនាដំណាក់កាលសវនាការបឋមនេះ សហព្រះរាជអាជ្ញាសូមធ្វើលើកឡើងនូវទឡ្ហីករណ៍ឆ្លើយតបនឹងអំណះអំណាងរបស់មេធាវីការពារក្តី អៀង សារី ពាក់ព័ន្ធនឹងគោលការណ៍គ្មានការកាត់ទោសពីរដងចំពោះអង្គហេតុតែមួយថា ច្បាប់អ.វ.ត.ក និងវិធានផ្ទៃក្នុងមិនមានចែងអំពីការណែនាំទាក់ទងទៅនឹងគោលការណ៍គ្មានការកាត់ទោសពីរដងចំពោះអង្គហេតុតែមួយនោះទេ។

ដូច្នេះ អ.វ.ត.ក ត្រូវស្វែងរកការណែនាំពីក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា និងនីតិវិធីដែលបង្កើតឡើងនូវកម្រិតអន្តរជាតិ។

[១៥:១៤:៣០]

មាត្រា១២ នៃក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជានៅឆ្នាំ២០០៧ ដែលបានចែងទាក់ទងទៅនឹងអាជ្ញាអស់ជំនុំបានចែងយ៉ាងច្បាស់លើគោលការណ៍គ្មានការកាត់ទោសពីរដងចំពោះអង្គហេតុតែមួយ។

មាត្រា១២នេះបានចែងផងដែរថា ដោយអនុវត្តតាមគោលការណ៍អាជ្ញាអស់ជំនុំ។ ជនណាដែលត្រូវបានតុលាការសម្រេចឲ្យរួចខ្លួនជាស្ថាពរហើយ ជននោះមិនអាចត្រូវចោទប្រកាន់ទៀតទេ ចំពោះអំពើដដែលបានឡើយ។ ដូច្នេះ មាត្រានេះអនុញ្ញាតិឲ្យធ្វើការកាត់សេចក្តី អៀង សារី ចំពោះមុខ អ.វ.ត.ក ដោយសារតែគាត់ត្រូវបានតុលាការប្រជាជនបដិវត្តន៍នៅទីក្រុងភ្នំពេញផ្តន្ទាទោសប្រហារជីវិតមិនមែនសម្រេចឲ្យរួចខ្លួននោះទេ។

មាត្រា១២ នៃក្រមនីតិវិធីព្រហ្មទណ្ឌនៅឆ្នាំ២០០៧ មិនអាចយកមកអនុវត្តចំពោះករណីជនជាប់ចោទ អៀង សារី បានឡើយ។ គោលការណ៍នេះ គឺផ្អែកទៅលើការសន្មត ការជំនុំជម្រះក្តីអាចបណ្តាលឲ្យមានការលំបាក ឬការខូចខាតខាងផ្លូវកាយ ផ្លូវចិត្ត និងទ្រព្យសម្បត្តិដល់ជនជាប់ចោទ ហើយក៏គឺការអ្វីដែលជនជាប់ចោទគួរតែជួបប្រទះយ៉ាងតិចម្តងដែរ។ បើពិនិត្យទៅលើករណីរបស់លោក អៀង សារី ឃើញថា មិនដែលបានជួបប្រទះការខូចខាតទាំងនោះឡើយ។ ព្រោះថា អៀង សារី ត្រូវបានកាត់

ទោសដោយកំបាំងមុខ ហើយក៏មិនត្រូវបានឃុំខ្លួន និងមិនមានការខូចខាតជាក់ស្តែងណាមួយដែលកើតចេញមកពីការកាត់ទោសនោះដែរ។ លើសពីនេះទៀត គោលការណ៍ដែលគ្មានការកាត់ទោសពីរដងចំពោះអង្គហេតុតែមួយ ត្រូវបានរកឃើញមួយផ្នែកធំផ្អែកទៅលើគំនិតវានឹងមានភាពអយុត្តិធម៌សម្រាប់ជនជាប់ចោទក្នុងការទទួលទោសពីរផ្សេងគ្នាក្នុងអង្គហេតុតែមួយ។

សរុបមកកិច្ចដំណើរការនីតិវិធីបច្ចុប្បន្ននេះនឹងមិនតម្រូវឲ្យជនជាប់ចោទស៊ូទ្រាំនឹងការដាក់ទម្ងន់រួមជាមួយនឹងការកាត់ទោសជាលើកទីពីនោះទេ ហើយក៏មិនបណ្តាលឲ្យជនជាប់ចោទទទួលទោសលើសពីមួយដងចំពោះអង្គហេតុតែមួយនោះដែរ។

គោលការណ៍គ្មានការកាត់ទោសពីរដងចំពោះអង្គហេតុតែមួយ ត្រូវបានបង្ហាញឡើងដើម្បីគេចឲ្យផុតពីភាពអយុត្តិធម៌។ ទោះបីជាយ៉ាងណាក៏ដោយពុំមានភាពអយុត្តិធម៌ដើម្បីគេចឲ្យផុតនៅក្នុងរឿងក្តីនេះទេ។ នៅគ្រប់កាលៈទេសៈទាំងអស់ ការអនុវត្តគោលការណ៍គ្មានការកាត់ទោសពីរដងចំពោះអង្គហេតុតែមួយចំពោះការចោទប្រកាន់ទាំងឡាយដែលធ្វើឡើងដោយជនជាប់ចោទនៅក្នុងតុលាការនេះគឺជាការអនុវត្តដោយគ្មានមូលដ្ឋានទាំងស្រុង។ ពុំមានការលើកឡើងពីគោលការណ៍គ្មានការកាត់ទោសពីរដងចំពោះអង្គហេតុតែមួយនៅក្នុងច្បាប់អ.វ.ត.ក ឬវិធានផ្ទៃក្នុងឡើយ។ ដូចនេះ វាជាការចាំបាច់ក្នុងការក្រឡេកមើលក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា និងច្បាប់នានាព្រមទាំងគោលការណ៍ទាំងឡាយដែលត្រូវបានបង្កើតឡើងនៅកម្រិតអន្តរជាតិសម្រាប់ជាគោលការណ៍ណែនាំពាក់ព័ន្ធនឹងការអនុវត្តគោល-ការណ៍នៅ អ.វ.ត.ក។

[១៥:១៧:៥២]

ទោះបីសាលក្រមរបស់តុលាការប្រជាជនបដិវត្តន៍នៅទីក្រុងភ្នំពេញឆ្នាំ១៩៧៩ មិនមែនជាសាលក្រមស្ថាពរដោយសារតុលាការប្រជាជនបដិវត្តន៍នៅទីក្រុងភ្នំពេញបានកាត់សេចក្តីលើកទីមួយ និងបិទផ្លូវប្តឹងតវ៉ាក៏ដោយ ក៏មិនអាចការពារ អៀង សារី ពីការចោទប្រកាន់នៅអ.វ.ត.ក បានឡើយ។ ហើយគោលការណ៍គ្មានការកាត់ទោសពីរដងចំពោះអង្គហេតុតែមួយក៏មិនត្រូវបានរំលោភដែរ។

សហព្រះរាជ អាជ្ញាសុំស្នើដល់អង្គជំនុំជម្រះបដិសេធចោលនូវអញ្ញត្រកម្មរបស់មេធាវីការពារក្តីទៅនឹងយុត្តាធិការរបស់ អ.វ.ត.ក ដោយសំអាងលើមូលដ្ឋាននៃគោលការណ៍គ្មានការកាត់ក្តីពីរដងចំពោះអង្គហេតុតែមួយ។

ការលើកឡើងរបស់ អៀង សារី ការជំនុំជម្រះក្តីនៅចំពោះមុខតុលាការប្រជាជនបដិវត្តន៍

មិនបានដកហូតពីអង្គជំនុំជម្រះសាលាដំបូងនូវយុត្តាធិការក្នុងការចោទប្រកាន់គាត់ចំពោះឧក្រិដ្ឋកម្មនានាដែលជនជាប់ចោទបានប្រព្រឹត្តក្នុងរយៈកាលនៃរបបខ្មែរក្រហមនោះឡើយ។ គោលការណ៍ស្តីពីការគ្មានការកាត់ក្តីពីរដងចំពោះអង្គហេតុតែមួយ មិនអាចយកប្រើនៅក្នុងករណីនេះទេដោយសារគ្មានមូលដ្ឋានទាំងនៅក្នុងច្បាប់ជាតិ ទាំងនៅក្នុងច្បាប់អន្តរជាតិ។

តុលាការអន្តរជាតិជាទីគោរព! ហេតុផលដូចបានជម្រាបជូនខាងលើការនាំជនជាប់ចោទ អៀង សារី មកជំនុំជម្រះនៅពេលនេះគឺជាការត្រឹមត្រូវ និងពុំបានបំពារបំពានលើគោលការណ៍គ្មានការកាត់ទោសពីរដងចំពោះអង្គហេតុតែមួយឡើយ។ ហើយលោក អាន់ឌ្រូ ខេលី គាត់ជាសហការីរបស់ខ្ញុំគាត់នឹងធ្វើការឆ្លើយតបបន្ថែមទៀតពាក់ព័ន្ធទៅនឹងសិទ្ធិពលរដ្ឋនិងសិទ្ធិនយោបាយ និងនីតិវិធីនានាដែលពាក់ព័ន្ធទៅនឹងក្រមខណ្ឌនៃអន្តរជាតិ។

ចាំស, សូមអនុញ្ញាតិបន្តសូមអរគុណ។

**ប្រធានអង្គបុរេ៖**

អរគុណសហព្រះរាជអាជ្ញា សូមអញ្ជើញសហព្រះរាជអាជ្ញាអន្តរជាតិ។

[១៥:២០:០៩]

**លោក អាន់ឌ្រូ ខេលី៖**

សូមអរគុណលោកប្រធាន។ ជាបឋម ខ្ញុំដឹងអំពីសេចក្តីណែនាំរបស់លោកប្រធានដែលបានលើកឡើងនៅក្នុងរបៀបវារៈក្នុងថ្ងៃនេះដែលលោក លោកស្រីចៅក្រម បានពិចារណារួចទៅហើយចំពោះសារណាជាលាយលក្ខណ៍អក្សរលើករណីទាំងអស់នេះ ជាពិសេស សេចក្តីណែនាំដែលបានផ្តល់ជូនមេធាវីការពារក្តីឲ្យផ្តោតជាបឋមទៅលើករណី ថាតើសាលាក្តីប្រជាជនបដិវត្តន៍កម្ពុជានោះ គឺត្រឹមត្រូវដែរឬទេ?

ហើយចំណុចទីពីរ ថាតើសេចក្តីសម្រេចរបស់អង្គបុរេជំនុំជម្រះជាទឡ្ហីករណ៍ថ្មីពាក់ព័ន្ធទៅនឹងគោលការណ៍គ្មានការកាត់ទោសពីរដងដែរឬទេ?

[១៥:២០:៥៤]

ខ្ញុំនឹងលើកឡើងដោយសង្ខេបនូវអ្វីដែលសហសេវីករបស់ខ្ញុំ លើកឡើងរួចហើយទាក់ទងទៅនឹងលំដាប់លំដោយទឡ្ហីករណ៍របស់ខ្ញុំ។ ប៉ុន្តែយ៉ាងណាក៏ដោយ ខ្ញុំនឹងពិចារណាលើកឡើងអំពីការជំនុំជម្រះតើវាយុត្តិធម៌ដែរឬទេ កាលពីលើកមុន?

ទទ្បីការណ៍ដែលបានលើកឡើងនៅចំពោះមុខអង្គបុរជំនុំជម្រះ បានលើកឡើងរួចមកហើយ ហើយក៏បានពិចារណាដោយអង្គជំនុំជម្រះសាលាដំបូងរួចដែរ។ ដូច្នេះហើយ យើងខ្ញុំសូមរក្សាសិទ្ធិថា ទទ្បីករណ៍របស់យើងទាំងអស់នោះ គួរតែយកមកពិចារណាដោយយើងបានលើកឡើងនៅក្នុងកថាខណ្ឌ ៣១ នៅក្នុងចម្លើយតបរបស់យើងទៅលើសារណាបន្ថែមរបស់លោក អៀង សារី ចុះថ្ងៃទី៧ ខែមិថុនា ឆ្នាំ២០១១។ ជាពិសេសជំហររបស់សហព្រះរាជអាជ្ញាផ្អែកលើកជំហរចំនួនបី។ ទីមួយ គឺបទប្បញ្ញត្តិនៃក្រមព្រហ្មទណ្ឌកម្ពុជា គឺមានចែងអំពីគោលការណ៍គ្មានការកាត់ទោសពីរដងចំពោះបទល្មើសតែមួយ។ បទប្បញ្ញត្តិនេះមិនអាចអនុវត្តក្នុងរឿងក្តីនេះទេ។

ចំណុចទីពីរ យើងសូមលើកឡើងថា សហសេវិករបស់ខ្ញុំក៏បានលើកឡើងរួចហើយដែរ។ យើងសូមលើកឡើងថា អង្គបុរេជំនុំជម្រះពិតជាត្រឹមត្រូវក្នុងការរកឃើញថា មាត្រា១៤(៧) នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយមិនអនុវត្តចំពោះកិច្ចដំណើរការនីតិវិធីចំពោះមុខ អ.វ.ត.ក នេះទេ។

[១៥:២២:២៨]

ចំណុចចុងក្រោយយើងខ្ញុំសូមលើកឡើងថា ផ្អែកទៅលើគោលការណ៍ណែនាំដែលមានចែងដោយបទប្បញ្ញត្តិពាក់ព័ន្ធទៅនឹងគោលការណ៍គ្មានការកាត់ទោសពីរដង ជាពិសេស លើកលក្ខន្តិកៈតុលាការអន្តរជាតិ តុលាការ អាយ.ស៊ី.ធី.វាយ, អាយ.ស៊ី.ធី.អ័រ តុលាការ សៀរ៉ាឡេអូន និងតុលាការព្រហ្មទណ្ឌអន្តរជាតិ។ យើងសូមលើកឡើងថា អ.វ.ត.ក មិនតម្រូវឲ្យអនុវត្តយុត្តាធិការរបស់ខ្លួនក្នុងករណីដែលនីតិវិធីជាតិបានធ្វើឡើងដោយមិនលម្អៀង ដោយឯករាជ្យ និងស្របតាមនីតិវិធីត្រឹមត្រូវ ទទួលស្គាល់ដោយច្បាប់អន្តរជាតិតែប៉ុណ្ណោះ។

ចំពោះចំណុចនេះ ទទ្បីករណ៍របស់ខ្ញុំសូមបង្ហាញថា ខ្ញុំនឹងផ្តោតទៅលើនីតិវិធីរបស់សាលាក្តីប្រជាជនបដិវត្តន៍ថាតើវាត្រឹមត្រូវដែរឬទេ? យើងគិតថាវាមិនត្រឹមត្រូវ មិនយុត្តិធម៌ និងមិនឯករាជ្យ។ ដូច្នេះ ខ្ញុំសូមបង្ហាញដោយសង្ខេប។ បទប្បញ្ញត្តិនៃក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ២០០៧ គ្រាន់តែមិនអនុវត្តទេ ហេតុអ្វី?

[១៥:២៣:៤៦]

ដោយសារតែគោលការណ៍អាជ្ញាអស់ជំនុំ ដូចមានចែងនៅក្នុងមាត្រា៧ និង១២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ គឺរាំងការចោទប្រកាន់ជាលើកទីពីរចំពោះអំពើតែមួយ។ ប៉ុន្តែ វាអនុវត្តតែចំពោះករណីជន

ត្រូវបានកាត់ឲ្យរួចផុតពីបទចោទជាស្ថាពរតែប៉ុណ្ណោះ។ មាត្រានេះ គឺចែងមាត្រា៧ និងមាត្រ១២ រួមគ្នា។

អង្គបុរេជំនុំជម្រះបានពិចារណាលម្អិតនៅក្នុងកថាខណ្ឌ១២២ ដល់១២៣ នៃសាលដីការបស់ខ្លួន ដែលក្នុងនោះលើកឡើងអំពីការអះអាងរបស់មេធាវីការពារក្តីផងដែរ ដែលលើកឡើងថា គួរតែបក ស្រាយមាត្រា១២ ចំពោះអ្នកទាំងឡាយដែលត្រូវបានកាត់ទោសផងដែរ។ ទោះបីជាបទប្បញ្ញត្តិនោះមិន មានចែងអំពីករណីនេះក៏ដោយ។

[១៥:២៤:៣២]

អង្គបុរេជំនុំជម្រះបានពិចារណាបទប្បញ្ញត្តិដទៃទៀតនៅក្នុងក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា ហើយ រកឃើញថា មានហេតុផលល្អជាច្រើនដែលមាត្រា១២ចែងតែចំពោះបុគ្គលដែលត្រូវបានឲ្យកាត់ ឲ្យរួច ខ្លួនជាស្ថាពរ។ ហេតុផលមួយនោះ ដូចដែលលោក កាណាវាស បានលើកឡើង។ ខ្ញុំសូមផ្តល់ហេតុផល មួយគឺដោយសារតែផ្នែកដទៃទៀតនៅក្នុងក្រមនីតិវិធីព្រហ្មទណ្ឌ គឺផ្តល់ឲ្យជនដែលជាប់ពិរុទ្ធ ដែលត្រូវ បានកាត់កំបាំងមុខនោះ គឺអនុញ្ញាតឲ្យគាត់ត្រឡប់មកតុលាការវិញ ដើម្បីធ្វើការតវ៉ាសាលក្រមដោយ ផ្ទាល់មុខ អនុលោមតាមមាត្រា៣៦៥, ៣៧០ និង៣៧១។

[១៥:២៥:១៦]

ដូច្នេះ ប្រសិនបើគោលការណ៍អាជ្ញាអស់ជំនុំ មាត្រា១២អនុវត្តចំពោះបុគ្គលដែលត្រូវបានកាត់ឲ្យ ជាប់ពិរុទ្ធភាពនោះ ដូច្នេះវានឹងបដិសេធសិទ្ធិនោះដែលមានចែងនៅក្នុងវិធាន ជាពិសេសគឺវាបដិសេធ សិទ្ធិក្នុងការតវ៉ាសាលក្រមរបស់តុលាការដោយផ្ទាល់ខ្លួន។

ដូច្នេះ យើងខ្ញុំឆ្លើយតបទៅនឹងចំណុចនេះថា គោលការណ៍គ្មានការកាត់ទោសពីរដង គឺវាអាច អនុវត្តបានចំពោះជនជាប់ចោទដែលត្រូវបានកាត់ឲ្យរួចខ្លួន។ ហើយវាជាផលប្រយោជន៍របស់ជនជាប់ ចោទអនុលោមតាមក្រមនីតិវិធីព្រហ្មទណ្ឌ។ ដូច្នេះ ជំហររបស់សហព្រះរាជអាជ្ញា គឺមានលក្ខណៈរឹងមាំ យើងមិនអាចតវ៉ាថា យើងមិនអាចកាត់ទោសគេសាជាថ្មីនោះទេ ប៉ុន្តែយ៉ាងណាក៏ដោយវិធាននោះគឺ អនុញ្ញាតឲ្យមានការតវាទៅលើការជាប់ពិរុទ្ធភាពដែលពេលនោះ ជនជាប់ចោទត្រូវបានកាត់ទោសដោយ កំបាំងមុខ។

[១៥:២៦:៣០]

ដូច្នេះ យើងមិនអាចតវ៉ាថា អាជ្ញាអស់ជំនុំអនុវត្តគ្រប់ករណីទាំងអស់នោះទេ។ អង្គបុរេជំនុំ ជម្រះពិតជាត្រឹមត្រូវក្នុងការសម្រេចទៅលើបញ្ហានេះ។

មាត្រា១២ គឺមិនអនុវត្តចំពោះជនដែលត្រូវបានកាត់ឲ្យជាប់ទោសនោះឡើយ។ ដូច្នេះ អង្គជំនុំជម្រះសាលាដំបូងត្រូវពិចារណាទៅលើបទដ្ឋានណែនាំនៅក្នុងករណីដទៃៗទៀត។

ចំណុចមួយទៀតទឡ្ហីករណ៍របស់ខ្ញុំ សូមបង្ហាញអំពីកតិកាសញ្ញាអន្តរជាតិ មាត្រា១៤(៧) សហសេវិករបស់ខ្ញុំបានលើកឡើងអំពីការអនុវត្តអន្តររដ្ឋនៃកតិកាសញ្ញាចំពោះ អ.វ.ត.ក នេះ។ ហើយខ្ញុំនឹងមិនលើកឡើងសាជាថ្មីទេ ជាជាងការលើកឡើងថា អង្គបុរេជំនុំជម្រះពិតជារកឃើញយ៉ាងត្រឹមត្រូវថា មិនមានការការពារតាមច្បាប់អន្តរជាតិចំពោះគោលការណ៍គ្មានការកាត់ទោសពីរដង អនុលោមតាមកតិកាសញ្ញាអន្តរជាតិនោះឡើយ។ ដោយសារតែ អ.វ.ត.ក ជាការពិតទៅគឺជាតុលាការអន្តរជាតូបនីយកម្ម។ លោក កាណាវាស គាត់លើកឡើងថាតើយកមកពីណាដែលវាថាជាតុលាការអន្តរជាតូបនីយកម្ម។ យើងឃើញមានសេចក្ដីសម្រេចមួយចំនួនក្នុងនោះមានសេចក្ដីសម្រេចរបស់អង្គបុរេជំនុំជម្រះវិសាមញ្ញផងដែរ។

[១៥:២៧:៥១]

ខ្ញុំសូមលើកឡើងសេចក្ដីសម្រេច E39-5 អង្គជំនុំជម្រះបានលើកឡើងថា អង្គជំនុំជម្រះវិសាមញ្ញគឺជាតុលាការកម្ពុជា បង្កើតឡើងដោយកិច្ចព្រមព្រៀងរវាងរាជរដ្ឋាភិបាលកម្ពុជា និងអង្គការសហប្រជាជាតិ គឺជាតុលាការមួយដាច់ដោយឡែក ហើយឯករាជ្យពីតុលាការកម្ពុជា។

អង្គជំបុរេជំនុំជម្រះរកឃើញថា អង្គបុរេជំនុំជម្រះ និងអង្គជំនុំជម្រះសាលាដំបូងបានបង្ហាញថា អង្គជំនុំជម្រះវិសាមញ្ញមានលក្ខណៈពិសេស។ ហើយសេចក្ដីសម្រេចទាំងឡាយ គឺបានសម្រេចនៅក្នុងហ្នឹង ហើយវាជាមូលដ្ឋានមួយសម្រាប់ទឡ្ហីករណ៍របស់យើងថា តុលាការ អ.វ.ត.ក របស់យើងជាតុលាការមួយដែលមានលក្ខណៈពិសេសស្ថិតនៅក្នុងតុលាការកម្ពុជា។

ដូច្នេះ យើងខ្ញុំសូមបង្ហាញថា មាត្រា១៤(៧) នៃកតិកាសញ្ញាអន្តរជាតិមិនអនុវត្តចំពោះគោលការណ៍គ្មានការកាត់ទោសពីរដងនោះឡើយ។

[១៥:២៩:០០]

ចំណុចចុងក្រោយប្រសិនបើអង្គបុរេជំនុំជម្រះ ពិតជាខុសនោះមែន មាត្រា១៤(៧) យកមកអនុវត្តនោះ យើងនឹងរក្សាជំហររបស់យើងថា សូមឲ្យអស់លោក លោកស្រីពិចារណាទៅលើកថាខណ្ឌ១៨ នៃសេចក្ដីឆ្លើយតបរបស់យើងទៅលើសារណាបន្ថែមរបស់លោក អៀង សារី ចុះថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០១១។

ខ្ញុំមិនធ្វើការលើកឡើងទឡ្ហីករណ៍នេះឡើងវិញនោះទេ ដោយសារវាបានបង្ហាញច្បាស់លាស់រួចទៅហើយ។ ចំណុចចុងក្រោយ ខ្ញុំសូមលើកឡើងដល់ចំណុចចុងក្រោយតែម្តងនៃទឡ្ហីករណីរបស់ខ្ញុំ ដែលមើលទៅលើបទដ្ឋានក្នុងកម្រិតអន្តរជាតិ ជាសេសពាក់ព័ន្ធទៅនឹងគោលការណ៍គ្មានការកាត់ទោសពីរដងនេះ។

ចំណុចដែលសំខាន់នោះ តុលាការ យូហ្គោស្លាវី តុលាការ សៀរ៉ាឡេអូន និងតុលាការព្រហ្មទណ្ឌអន្តរជាតិ។ លិខិតុបករណ៍ លក្ខន្តិកៈទាំងអស់គឺ ហាមឃាត់មិនឲ្យអនុវត្តយុត្តាធិការរបស់ខ្លួនក្នុងករណីដែលបុគ្គលនោះត្រូវបានកាត់ទោសពីរដង។ លើកលែងតែនីតិវិធីជាតិមានលក្ខណៈស្របតាមនីតិវិធីត្រឹមត្រូវ។

តុលាការ អាយ.ស៊ី.ធី.វាយ, អាយ.ស៊ី.ធី.អ័រ ហើយនិងតុលាការ សៀរ៉ាឡេអូន គឺទាមទារថា ដើម្បីឲ្យអនុវត្តគោលការណ៍គ្មានការកាត់ទោសពីរដងបាន។ នីតិវិធីជាតិត្រូវតែអនុវត្តដោយឯករាជ្យ ហើយស្របទៅតាមនីវិធីត្រឹមត្រូវដែលទទួលស្គាល់ដោយច្បាប់អន្តរជាតិ។

[១៥:៣០:៤២]

បទប្បញ្ញត្តិនៃតុលាការព្រហ្មទណ្ឌអន្តរជាតិគឺមានចែងលក្ខខណ្ឌបន្ថែម ដែលក្នុងនោះលើកឡើងថា មិនត្រឹមនីតិវិធីជាតិ មិនត្រឹមតែឯករាជ្យ ហើយត្រឹមត្រូវតាមនីតិវិធីដែលទទួលស្គាល់ដោយអន្តរជាតិនោះទេ វាក៏ត្រូវតែអនុវត្តក្នុងលក្ខណៈមួយដោយមានចេតនាយកបុគ្គលដែលពាក់ព័ន្ធមកផ្តន្ទាទោសឲ្យបានត្រឹមត្រូវ។

យើងខ្ញុំសូមឲ្យអស់លោក លោកស្រី មើលមាត្រា២៣ នៃលក្ខន្តិកៈតុលាការ អាយ.ស៊ី.ស៊ី ។ នេះគឺជាអ្វីដែលមានចែង គ្មានបុគ្គលណាមួយដែលត្រូវបានកាត់ទោសដោយតុលាការមួយផ្សេង គឺទៅលើអំពើដែលមានចែងនៅក្នុងមាត្រា៧,៨ ដែលត្រូវយកមកកាត់ទោសឡើងវិញនោះទេ លើកឡើងតែនីតិវិធីរបស់តុលាការនោះគឺមិនមានបំណងជាខែលបាំងចំពោះបុគ្គលដែលស្ថិតនៅក្នុងយុត្តាធិការរបស់តុលាការ។

[១៥:៣១:៥៥]

ទីពីរ លើកលែងតែនីតិវិធីតុលាការនោះធ្វើឡើងស្របតាមនីតិវិធីត្រឹមត្រូវឯករាជ្យ ហើយនិងតាមច្បាប់អន្តរជាតិ។ ហើយនីតិវិធីនោះត្រូវធ្វើឡើងក្នុងនីតិវិធីមួយដើម្បីមានចេតនាចាប់យកបុគ្គលនោះឲ្យទទួលខុសត្រូវព្រហ្មទណ្ឌ នេះហើយជាលក្ខខណ្ឌដែលចែងក្នុងនោះ។

មេធាវីការពារក្តីបានបកស្រាយលក្ខខណ្ឌទីពីរនៃមាត្រា២៣ នៃលក្ខន្តិកៈនោះដោយខុសឆ្គង ដែលក្នុងនោះចែងថា នីតិវិធីត្រូវតែអនុវត្តដើម្បីយកបុគ្គលដែលពាក់ព័ន្ធនោះមកកាត់ទោស។ មេធាវីការពារក្តីបានបកស្រាយថា គឺនីតិវិធីនេះ គឺត្រូវបានធ្វើឡើងដើម្បីជួយឲ្យជនជាប់ចោទរួចផុតពីការទទួលខុសត្រូវ។

មេធាវីការពារក្តីបានលើកឡើងទៅលើចំណុចនោះ ហើយបានដាក់នៅក្នុងសេចក្តីសន្និដ្ឋានរបស់ខ្លួនដែលដាក់ជូនតុលាការ។ ដូច្នេះ ខ្ញុំសូមជម្រាបអង្គសវនាការថា ការបកស្រាយបែបនោះពាក់ព័ន្ធទៅនឹងមាត្រា២៣(ខ) នៃលក្ខន្តិកៈទីក្រុមរ៉ូម គឺខុស។ ហេតុអ្វី? ដោយសារតែមាត្រា២៣(ខ) គឺចែងដោយផ្ទាល់ពាក់ព័ន្ធទៅនឹងការជាខែលបាំងទៅលើជនជាប់ចោទ មិនឲ្យមានការកាត់ទោស ដែលក្នុងនោះគេលើកឡើងថា នីតិវិធីរបស់តុលាការជាតិគឺដើម្បីបិតបាំងជនជាប់ចោទមិនឲ្យទទួលការកាត់ទោស។

[១៥:៣៣:៤២]

ដូច្នេះហើយនៅក្នុងនេះគឺយើង ករណីរបស់យើងគឺមិនមានន័យដូចគ្នានោះឡើយ។ ហើយចំពោះមាត្រា២៣ (ក) និង(ខ) មិនមានលក្ខណៈដូចគ្នានោះឡើយ។ អង្គបុរេជំនុំជម្រះបានលើកឡើងនៅក្នុងកថាខណ្ឌ១៤១ នៃករណី មីឡូសីវិច ចំណុចពីរនេះបានបញ្ជាក់ថាវាមិនមានន័យដូចគ្នាឡើយ។

នៅក្នុងកថាខណ្ឌ១៥២ នៃអង្គបុរេជំនុំជម្រះ តុលាការអន្តរជាតិ បានលើកឡើងថាគ្មានអ្វីដែលវាលើកឡើងផ្ទុយថា គឺធ្វើឡើងដើម្បីផ្ទុយនឹងយុត្តិធម៌នោះឡើយ។

ដូច្នេះហើយវាមិនមែនថាជាការពិបាកក្នុងការកាត់ទោសជនជាប់ចោទឡើយ។ នៅក្នុងកថាខណ្ឌ ១៥២ នេះក៏បានចែងផងដែរ លក្ខខណ្ឌនៃការបិតបាំងជនជាប់ចោទពីការទទួលខុសត្រូវនោះគឺមានចែងនៅក្នុងមាត្រា២៣(ខ)។ ដូច្នេះ ការបកស្រាយមាត្រា២៣(ខ) គឺជាការបកស្រាយមួយច្រំដែលទៅលើមាត្រា២៣(ក)។

[១៥:៣៥:៤៩]

ខ្ញុំមិនធ្វើការលើកឡើងនូវសេចក្តីសន្និដ្ឋានរបស់ខ្ញុំជាលាយលក្ខណ៍អក្សរឡើងវិញនោះទេ ប៉ុន្តែខ្ញុំសូមឲ្យចៅក្រមធ្វើការពិចារណាកថាខណ្ឌ១៥៣ និង១៥៦ នៃសេចក្តីសម្រេចរបស់តុលាការអន្តរ-អាមេរិកាំង។

ជាសេចក្តីសន្និដ្ឋាន យើងខ្ញុំសូមលើកឡើងថា នីតិវិធីអន្តរជាតិដែលបានបង្កើតតុលាការអន្តរជា-តូបនីយកម្មនោះ គឺមិនអាចយុត្តាធិការចំពោះបុគ្គលទាំងឡាយដែលត្រូវបានកាត់ទោសដោយយុត្តាធិការ

មួយរួចទៅហើយនោះទេ លើកលែងតែនីតិវិធីជាតិនោះត្រូវបានធ្វើឡើងដោយមិនឯករាជ្យ ដោយមិនយុត្តិធម៌ និងដោយលម្អៀង។ យើងយល់ស្របជាមួយនឹងអង្គបុរេជំនុំជម្រះ ហើយលើកឡើងថា នីតិវិធីចំពោះមុខតុលាការប្រជាជនបដិវត្តន៍កម្ពុជា គឺមិនមានលក្ខណៈយុត្តិធម៌ មិនស្រប ហើយមិនត្រឹមត្រូវតាមច្បាប់។

នៅក្នុងនេះ ចំណុចចុងក្រោយរបស់ខ្ញុំ គឺជាការពិនិត្យមើលថា ហេតុអ្វីបានជាខ្ញុំបានលើកឡើងដូច្នេះ។ ការពិនិត្យដោយសង្ខេបទៅលើរបាយការណ៍របស់តុលាការប្រជាជនបដិវត្តន៍ថា វាមិនយុត្តិធម៌ និងមិនត្រឹមត្រូវតាមនីតិវិធីនោះ។ ខ្ញុំសូមឲ្យអង្គសវនាការមើលកថាខណ្ឌ១៦២ នៃសេចក្ដីសម្រេចរបស់អង្គបុរេជំនុំជម្រះ ដែលក្នុងនោះបានរៀបរាប់អំពីកាលប្រវត្តិនៃរបាយការណ៍របស់តុលាការប្រជាជនបដិវត្តន៍ ដែលក្នុងនោះបានបង្ហាញអំពីលំដាប់លំដោយ ដែលបានកើតឡើង។

តុលាការប្រជាជនបដិវត្តន៍កម្ពុជាមិនមែនបង្កើតឡើងដោយច្បាប់នោះទេ។

[១៥:៣៦:៤០]

**ប្រធានអង្គជំនុំ៖**

អាស្រ័យដោយសារបញ្ហាអស់ ឌី.វី.ឌី អ៊ីចឹងត្រូវការផ្លាស់ប្ដូរ សូមសម្រាក ផ្អាកមួយនាទីសិន ដើម្បីឲ្យផ្នែកខាងបច្ចេកទេសផ្លាស់ប្ដូរនូវ ឌី.វី.ឌី ដើម្បីបន្តកិច្ចដំណើរការ។

**លោក អាន់ត្រូ ខេលី៖**

សូមអរគុណ លោកប្រធាន ខ្ញុំនឹងធ្វើតាម។

[១៥:៣៧:២៥]

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញបន្តទៀត លោកសហព្រះរាជអាជ្ញាអន្តរជាតិ។ សូមអញ្ជើញ!

**លោក អាន់ត្រូ ខេលី៖**

សូមអរគុណលោកប្រធាន ខ្ញុំសូមលើកឡើងសាជាថ្មី។ ខ្ញុំអម្បាញ់មិញនិយាយអំពីកថាខណ្ឌ ១៦២ នៃសេចក្ដីសម្រេចរបស់អង្គបុរេជំនុំជម្រះ។ សេចក្ដីសម្រេចនេះ គឺពាក់ព័ន្ធទៅនឹងសេចក្ដីសម្រេចទៅលើបណ្ដឹងឧទ្ធរណ៍នៃដីកាដំណោះស្រាយដែលបង្ហាញអំពីកាលប្រវត្តិនៃសកម្មភាពរបស់តុលាការប្រជាជនបដិវត្តន៍កម្ពុជា។

តុលាការប្រជាជនបដិវត្តន៍កម្ពុជា បង្កើតឡើងមិនមែនដោយច្បាប់នោះទេ ប៉ុន្តែដោយក្រឹត្យច្បាប់

របស់ក្រុមប្រឹក្សាប្រជាជនបដិវត្តន៍កម្ពុជា គឺឯកសារលេខ D288/6.9/9.3 ដោយសារតែនៅក្នុងនោះ យើងឃើញថា តុលាការនេះ គឺវាមិនមែនបង្កើតឡើងដោយច្បាប់ដែលធ្វើឡើងដោយសភាទេ គឺច្បាប់ គឺវាជាក្រឹត្យបង្កើតឡើងដោយបទប្បញ្ញត្តិដែលជាក្រឹត្យច្បាប់មួយ។

ដូច្នេះ នៅពេលដែលយើងមើលក្រឹត្យ គឺវាបានបង្ហាញអំពីការយល់ឃើញរបស់រដ្ឋាភិបាល ជាពិសេសទាក់ទងទៅនឹងពិរុទ្ធភាពរបស់ជនជាប់ចោទនៅក្នុងរឿងក្តីនុ៎ង គឺ អៀង សារី និងលោក ប៉ុល ពត។ មុនពេលមានការស៊ើបអង្កេត និងការជំនុំជម្រះចាប់ផ្តើមទៅទៀត យ៉ាងហោចណាស់សមាជិក បីរូបរបស់តុលាការ គឺជាសមាជិករបស់រដ្ឋាភិបាល គឺមានរដ្ឋមន្ត្រីព័ត៌មាន គឺលោក កែវ ចិន្តា ដែលគាត់ ជាប្រធានតុលាការ ហើយនិងចៅក្រមជំនុំជម្រះពីររូបដែលជារដ្ឋាភិបាល សមាជិករដ្ឋាភិបាល ដែលរក ឃើញនៅក្នុងសៀវភៅស្តីអំពីប្រល័យពូជសាសន៍ក្នុងប្រទេសកម្ពុជា ឯកសារ D227/1/17.1.133 នៅ ក្នុងទំព័រ ៥៦ ដល់ ៥៧ ដែលជាឯកសាររបស់តុលាការ។

[១៥:៣៩:៣៩]

ប្រធានតុលាការបានធ្វើសន្និសីទសារព័ត៌មាននៅថ្ងៃទី២៨ ខែកក្កដា ឆ្នាំ១៩៧៩ ដែលក្នុងនោះ បានបង្ហាញថា បន ប៉ុល ពត អៀង សារី មានទោសអំពីបទប្រល័យពូជសាសន៍ បីថ្ងៃក្រោយពីការ បើកការស៊ើបអង្កេត ហើយមុនពេលការជំនុំជម្រះចាប់ផ្តើម គឺគាត់បានធ្វើសន្និសីទដូច្នេះ។ លោក លោកស្រីចៅក្រម អាចមើលក្នុងសៀវភៅ ស្តីអំពីប្រល័យពូជសាសន៍ក្នុងប្រទេសកម្ពុជា ទំព័រ៤៧។

ចៅក្រមពីររូបបានលើកឡើងថា គាត់មានអំណាចស្រដៀងនឹងប្រធានតុលាការ ហើយគាត់ បានផ្តល់សក្ខីកម្មទៅដល់តុលាការនៅក្នុងដំណាក់កាលមុនអង្គសេចក្តី ហើយគាត់ផ្តល់សក្ខីកម្មជាអ្នក ជំនាញផងដែរ។

លោក លោកស្រីចៅក្រម ឃើញនៅក្នុងសៀវភៅទំព័រ៣៣៥ ដល់ ៣៣៧ និង ៥៦, ៥៧ ផង ដែរ។ មេធាវីការពារក្តី គឺគាត់ធ្វើចម្លើយដាក់បន្ទុកក្នុងពេលស៊ើបអង្កេត។ ចំណុចនេះគាត់សរសេរក្នុង ទំព័រ ១៣៤ និង ១៣៨ ហើយក៏មិនមានការដេញដោលសាក្សីទៅវិញទៅមកផងដែរ។

[១៥:៤០:៥៦]

ខ្ញុំសូមឲ្យលោកចៅក្រមមើលទំព័រ១៦។ មិនមានភស្តុតាង ដែលជាភស្តុតាងដោះបន្ទុកទៅដល់ ជនជាប់ចោទ។ មិនមានទឡ្ហីករណ៍បង្ហាញនៅពេលបិទសន្និដ្ឋានការស៊ើប ការចោទប្រកាន់។ លោក ហួស ស្ទីវិន មកពីសហរដ្ឋអាមេរិក និងមេធាវីរបស់លោក អៀង សារី បានបង្ហាញថា លោក អៀង

សារី និង ប៉ុល ពត គឺជាជនមួយដែលអាក្រក់ នៅក្នុងទំព័រ៥០៤ សក្ខីកម្មរបស់សាក្សីផ្អែកទៅលើពាក្យមួយចំនួនដែលថា បន ប៉ុល ពត អៀង សារី គឺជាក្រុមមួយដែលបន ប៉ុល ពត មាន ជាក្រុមឧក្រិដ្ឋជន យើងឃើញមាននៅក្នុងទំព័រ ៧៥, ១០២, ១០៣, ១២០, ១២២ និង ១២៧។ រយៈពេលនីតិវិធី មានតែ ២០ថ្ងៃតែប៉ុណ្ណោះ ចាប់ពីថ្ងៃបើកការស៊ើបអង្កេត ហើយ៥ថ្ងៃសម្រាប់ការជំនុំជម្រះ។

នៅថ្ងៃចុងក្រោយនៃការជំនុំជម្រះ គឺថ្ងៃ១៩ ខែសីហា ឆ្នាំ១៩៧៩ គឺយើងឃើញមានទទ្បីករណ៍ និងការពិភាក្សារបស់ចៅក្រម គឺបង្ហាញថាពិរុទ្ធភាពរបស់ជនជាប់ចោទបានកំណត់ជាមុនរួចទៅហើយ។

លោក លោកស្រីចៅក្រម មើលក្នុងទំព័រ៦៧ ដល់ ៦៩។ មេធាវីការពារក្ដីបានលើកឡើងឲ្យយើងអនុវត្តគោលការណ៍គ្មានការកាត់ទោសពីរដង ហើយគោរពទៅលើនីតិវិធីរបស់តុលាការប្រជាជនបដិវត្តន៍កម្ពុជា។ ដូច្នេះហើយ តុលាការនោះមិនបានបំពេញទៅតាមបទដ្ឋាននៃការជំនុំជម្រះដោយយុត្តិធម៌។

មេធាវីការពារក្ដី ក្នុងកថាខណ្ឌទី១០ បានលើកឡើងថា គោលបំណងនៃការមិនកាត់ទោសពីរដង គឺដើម្បីជួយទៅដល់បុគ្គលឲ្យរួចផុតពីការឈឺចាប់ផ្នែករូបរាងកាយ សតិអារម្មណ៍ផ្លូវចិត្ត និងថវិកាដែលពាក់ព័ន្ធទៅនឹងការកាត់ទោសពីរដងនេះ។

លោកស្រី ជា លាង បានលើកឡើងរួចហើយ លោក អៀង សារី នៅពេលនោះមិនមានវត្តមានទេ ហើយក៏មិនទទួលបាននូវការឈឺចាប់ពីការកាត់ទោសនោះផងដែរ។

លោក អៀង សារី មិននៅទីនោះទទួលការជំនុំជម្រះ ដូច្នេះគាត់មិនមានទុក្ខព្រួយផ្លូវអារម្មណ៍នោះឡើយ។ ទទ្បីករណ៍របស់មេធាវីការពារក្ដីគ្មានអ្វីគួរឲ្យយើងជឿនោះទេ។

ដូច្នេះ ខ្ញុំសូមបញ្ជាក់ថា គោលការណ៍គ្មានការកាត់ទោសពីរដងនេះ មិនអាចអនុវត្តបានឡើយនៅក្នុងករណីនេះ។ ខ្ញុំសូមអនុញ្ញាតឲ្យអង្គជំនុំជម្រះសាលាដំបូងធ្វើការទាត់ចោលទៅលើការលើកឡើងទាក់ទងទៅនឹងគោលការណ៍នេះ។

សូមអរគុណ។

[១៥:៤៤:០៨]

**ប្រធានអង្គជំនុំ៖**

បាទ, អរគុណលោកសហព្រះរាជអាជ្ញាអន្តរជាតិ។

ជាកិច្ចបន្តសូមអញ្ជើញ អង្គជំនុំជម្រះផ្តល់វេទិការទៅសហមេធាវីនាំមុខ តំណាងដើមបណ្តឹង

រដ្ឋប្បវេណី ដើម្បីធ្វើសេចក្តីថ្លែងការណ៍តប ប្រសិនបើសហមេធាវីមានបំណង។

[១៥:៤៤:៣៧]

**លោក ពេជ អង្គ៖**

លោកប្រធាន! សហមេធាវីនាំមុខសូមអនុញ្ញាតលោកប្រធាន អញ្ជើញអនុញ្ញាតឲ្យមេធាវីដើមបណ្តឹងរដ្ឋប្បវេណីចំនួនពីររូប គឺលោកស្រីមេធាវី ម៉ុច សុវណ្ណារី ហើយនិងលោកមេធាវី ម៉ាទីន ហ្សាកកាំង ដើម្បីធ្វើបទអន្តរាគមន៍។

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះអនុញ្ញាតតាមសំណើនេះ ហើយអង្គជំនុំជម្រះសូមរំឭកថា មេធាវីទាំងពីររូបមានពេលវេលា៣០នាទី នៅក្នុងការធ្វើសេចក្តីថ្លែងការណ៍តបនេះ។ សូមអញ្ជើញ!

[១៥:៤៥:១៥]

**លោកស្រី ម៉ុច សុវណ្ណារី៖**

សូមអរគុណលោកប្រធានចំពោះការផ្តល់វេទិការឲ្យក្រុមនាងខ្ញុំនៅក្នុងការធ្វើសេចក្តីសន្និដ្ឋានតប។ ជាដំបូង នាងខ្ញុំសូមគោរពអង្គជំនុំជម្រះសាលាដំបូង។ នាងខ្ញុំ ម៉ុច សុវណ្ណារី នៅក្នុងនាមនៅក្នុងផលប្រយោជន៍របស់ជនរងគ្រោះដែលជាភាគីដើមបណ្តឹងរដ្ឋប្បវេណីនៃសំណុំរឿងនេះ។

យើងខ្ញុំសូមបង្ហាញនូវជំហរថា យើងខ្ញុំគាំទ្រទាំងស្រុងលើអំណះអំណាងដែលបានលើកឡើងដោយសហព្រះរាជអាជ្ញា ដោយបន្ថែមទៅលើចម្លើយតបជាលាយលក្ខណ៍អក្សររបស់ដើមបណ្តឹងរដ្ឋប្បវេណី ដែលបានដាក់ជូនអង្គជំនុំជម្រះសាលាដំបូងរួចហើយ នៅថ្ងៃទី០៦ ខែមិថុនា ឆ្នាំ២០១១។

នៅពេលនេះ ខ្ញុំនឹងធ្វើសេចក្តីសន្និដ្ឋានបន្ថែម ដោយសង្កត់ធ្ងន់ទៅអំណះអំណាងផ្លូវច្បាប់មួយចំនួន ដែលយើងគិតថា វាគឺជាជំហរដែលដើមបណ្តឹងរដ្ឋប្បវេណីត្រូវប្រកាន់យក ហើយនិងលើកឡើងនូវទស្សនៈមួយចំនួនដែលចេញពីគំនិតរបស់ជនរងគ្រោះនៃឧក្រិដ្ឋកម្មអន្តរជាតិទាំងនេះ ទាក់ទងនឹងការអនុវត្តគោលការណ៍គ្មានការកាត់ទោសពីរដង ចំពោះអង្គហេតុតែមួយនេះ។

[១៥:៤៦:១០]

នៅក្នុងគ្រប់ករណីទាំងអស់ ខ្ញុំគាំទ្រថា តុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់ប្រទេសអតីតប្រទេសយូហ្គោស្លាវី មានមូលហេតុត្រឹមត្រូវនៅក្នុងការទទួលស្គាល់នូវលទ្ធភាពនៅក្នុងការប្រកាសពី

ពិរុទ្ធត្រួតគ្នាចំពោះអង្គហេតុតែមួយ។ ក្នុងលក្ខខណ្ឌដែលបទល្មើសនីមួយៗមានធាតុផ្សំខុសគ្នាច្បាស់លាស់ ដែលបទល្មើសមួយទៀតគ្មាន។

ហើយនេះជាយុត្តិសាស្ត្រអន្តរជាតិ ដែលអង្គជំនុំជម្រះសាលាដំបូងត្រូវតែអនុវត្តតាម ក្នុងគោលបំណងធានាឲ្យបានថា គ្រប់អំពើដែលជាធាតុផ្សំនៃឧក្រិដ្ឋកម្មអន្តរជាតិធ្ងន់ធ្ងរត្រូវបានផ្តន្ទាទោសប្រកបដោយយុត្តិធម៌។

យើងខ្ញុំសូមប្រកាន់ជំហរយ៉ាងរឹងមាំទៀតថា គោលការណ៍គ្មានការកាត់ទោសពីរដងចំពោះបទអង្គហេតុតែមួយនេះ មិនរារាំងការចោទប្រកាន់លោក អៀង សារី នៅចំពោះមុខតុលាការនេះទេ ព្រោះថាការជម្រះក្តីលោក អៀង សារី នៅក្នុងឆ្នាំ១៩៧៩ មិនត្រូវបានប្រព្រឹត្តឡើងដោយឯករាជ្យ ឬអាណាគតិ និងមិនបានគោរពតាមបទដ្ឋាននៃការជម្រះក្តីប្រកបដោយសមធម៌។

[១៥:៤៧:០៤]

ដូច្នេះ តុលាការដែលមានចរឹកអន្តរជាតិមួយនេះ ត្រូវតែអនុវត្តករណីលើកលែងនៃគោលការណ៍នេះឲ្យអនុលោកតាមបទដ្ឋាននីតិវិធីនៅកម្រិតអន្តរជាតិ។ មុននឹងសហភាតារបស់ខ្ញុំលោកស្រីមេធាវី ម៉ាទីន ហ្សាកកាំង លើកអំណះអំណាងលម្អិតទាក់ទងទៅនឹងការជម្រះក្តីលោក អៀង សារី នៅក្នុងឆ្នាំ១៩៧៩ ខ្ញុំសូមធ្វើការបង្ហាញនូវមូលហេតុ នូវមូលដ្ឋានមួយចំនួន ដែលគាំទ្រការអនុវត្តបញ្ញត្តិស្តីពី ការអនុវត្តករណីលើកលែងនៃគោលការណ៍គ្មានការកាត់ទោសពីរដងចំពោះអង្គហេតុតែមួយ។ ដែលក្នុងនេះនឹងត្រូវពិចារណាផងដែរ ពីទស្សនៈរបស់ជនរងគ្រោះដែលប្រកាសថា សិទ្ធិ និងផលប្រយោជន៍របស់ពួកគេ នឹងត្រូវបានមើលរំលង ក្នុងករណីដែលតុលាការមានចរិតអន្តរជាតិមួយនេះ មិនព្រមអនុវត្តបទដ្ឋាននីតិវិធីនៅកម្រិតអន្តរជាតិ ដែលបានគាំទ្រការអនុវត្តករណីលើកលែងនៃគោលការណ៍គ្មានការកាត់ទោសពីរដងនៃអង្គហេតុតែមួយនេះ។

ជាការពិត គោលការណ៍នេះបានកំណត់ថា គ្មានជនណាម្នាក់ត្រូវបានយកមកចោទប្រកាន់ ឬយកមកផ្តន្ទាទោសសាជាថ្មីឡើយ ចំពោះបទល្មើសដែលបានផ្តន្ទាទោសជាស្ថាពរ ឬបានលើកលែងទោសស្របច្បាប់ និងនីតិវិធីរបស់រដ្ឋនីមួយៗរួចហើយ។

[១៥:៤៨:០៩]

ប៉ុន្តែ គោលការណ៍នេះមិនមានអានុភាពអនុវត្តដាច់ខាតទេចំពោះគោលការណ៍នេះ។ ចំពោះ នីតិវិធីដែលបានប្រព្រឹត្តឡើងដោយមិនឯករាជ្យ ឬអាណាគតិ ឬមិនស្របតាមបទដ្ឋានដែលបានទទួល

ស្គាល់ច្បាប់អន្តរជាតិ។

ខ្ញុំជឿថា អ.វ.ត.ក ដែលជាតុលាការមានចរិតអន្តរជាតិ ត្រូវតែជម្រះក្តីដែលអនុលោមតាមបទដ្ឋាននីតិវិធី ដែលបានបង្កើតឡើងនៅកម្រិតអន្តរជាតិ ដែលដំណើរការនីតិវិធីនៅកម្រិតអន្តរជាតិនេះមានចរិតលក្ខណៈគតិយុត្តិខុសគ្នាទៅនឹងដំណើរការនីតិវិធី នៅកម្រិតជាតិ។

ហើយក៏សូមគាំទ្រផងដែរថា ករណីលើកលែងនេះត្រូវបានគាំទ្រដោយតុលាការអន្តរជាតិមិនអចិន្ត្រៃយ៍ ក៏ដូចជាតុលាការព្រហ្មទណ្ឌអន្តរជាតិ។

លើសពីនេះទៅទៀត គណៈកម្មាធិការសិទ្ធិមនុស្សបាន--

[១៥:៤៨:៥២]

**អ្នកបកប្រែ៖**

លោកប្រធាន, សូមប្រធានសូមអនុញ្ញាតណែនាំឲ្យមេធាវីនិយាយយឺតដើម្បីកត់ត្រាឲ្យបានត្រឹមត្រូវបាទ។

**លោកស្រី ម៉ុច សុវណ្ណារី៖**

នៃកតិការសញ្ញាអន្តរជាតិ ស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ គឺមានអានុភាពត្រឹមតែកម្រិតជាតិតែប៉ុណ្ណោះ ហើយវាមិនត្រូវបានទទួលស្គាល់ជាអន្តរជាតិថា វាជាបទដ្ឋានដាច់ខាតនៃការអនុវត្តអន្តរប្រទេសនោះទេ។

ខ្ញុំសូមកត់សម្គាល់ថា វាផ្ទុយពីអំណះអំណាងដែលមិនត្រឹមត្រូវ ដែលភាគីមេធាវីការពារក្តីបានលើកឡើងនៅក្នុងកថាខណ្ឌទី២០ នៃសារណារបស់ខ្លួន ឯកសារE51/11 យើងខ្ញុំសូមបញ្ជាក់ថា គណៈកម្មាធិការសិទ្ធិមនុស្សមួយនេះ ដែលក្នុងនាមខ្លួនជាស្ថាប័នតាមដានការអនុវត្តកតិកាសញ្ញាស្តីពី សិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ មានសិទ្ធិជាផ្លូវការនៅក្នុងការបកស្រាយបទប្បញ្ញត្តិដែលមានចែងនៅក្នុងកតិកាសញ្ញានេះ។

ហើយនាងខ្ញុំសូមកត់សម្គាល់ទៀតថា ប្រសិនបើគណៈកម្មាធិការនេះ ដែលត្រូវបានបង្កើតឡើងដោយកតិកាសញ្ញានេះ គាត់មិនមានសិទ្ធិនៅក្នុងការបកស្រាយបទប្បញ្ញត្តិទាំងឡាយនៃកតិកាសញ្ញានេះ តើអ្នកណាមានសិទ្ធិនេះ? ហើយខ្ញុំសូមកត់សម្គាល់ទៀតថា ការអនុម័តច្បាប់មួយ បញ្ញត្តិច្បាប់មួយដែលគ្មានការត្រួតពិនិត្យការអនុវត្ត--

[១៥:៥០:០១]

**អ្នកបកប្រែ៖**

លោកចៅក្រមប្រធាន, សូមលោកជួយឲ្យមេធាវី ម៉ុច សុវណ្ណារី ជួយបន្ថយល្បឿនបន្តិចទាន។

**ប្រធានអង្គជំនុំ៖**

បន្ថយល្បឿននិយាយញាប់ណាស់ អ្នកបកប្រែមិនអាចបកប្រែបានទេ ហើយកាលណាបកប្រែមិនបានមិនអាចប្រតិចារឹកបានត្រឹមត្រូវទេ។

**លោកស្រី ម៉ុច សុវណ្ណារី៖**

ដូច្នេះខ្ញុំគាំទ្រទៀតថា អង្គបុរេជំនុំជម្រះបានសម្រេចយ៉ាងត្រឹមត្រូវនៅលើសេចក្ដីសម្រេចលើបណ្ដឹងឧទ្ធរណ៍របស់លោក អៀង សារី ប្រឆាំងនឹងដីកាដំណោះស្រាយ។ ដោយយោងទៅលើរបាយការណ៍របស់គណៈកម្មាធិការនៃច្បាប់អន្តរជាតិប្រព្រឹត្តទៅនៅថ្ងៃទី៦ ខែឧសភា ដល់ថ្ងៃទី២៦ ខែកក្កដា ឆ្នាំ១៩៩៦ ទាក់ទងនឹងការធ្វើសេចក្ដីអធិប្បាយលើមាត្រា១២ ចំណុច២(ក)(២)នៃសេចក្ដីព្រាងស្ដីពីឧក្រិដ្ឋកម្មប្រឆាំងនឹងសន្តិភាព និងសន្តិសុខរបស់មនុស្សជាតិថា ប្រសិនបើយុត្តាធិការជាតិមិនបានជម្រះក្ដីដោយឯករាជ្យ ឬអាណាគតិទេ ឬប្រសិនបើនីតិវិធីនៅចំពោះមុខយុត្តាធិការនេះមានគោលបំណងរារាំងការទទួលខុសត្រូវព្រហ្មទណ្ឌជាអន្តរជាតិ។ សហគមន៍អន្តរជាតិមិនជាប់កាតព្វកិច្ចនៅក្នុងការទទួលស្គាល់សេចក្ដីសម្រេច ដែលជាលទ្ធផលនៃការមិនគោរពតាមស្តង់ដារនៃការជម្រះក្ដីប្រកបដោយសមធម៌នេះទេ។ ហើយខ្ញុំសូមបញ្ជាក់ផងដែរថា សេចក្ដីអត្ថាធិប្បាយនេះក៏បានត្រូវបានគាំទ្រយ៉ាងពេញទំហឹងដែរ ដោយសេចក្ដីប្រកាសរបស់អង្គការលើកលែងទោសអន្តរជាតិនៅក្នុងឯកសារសាធារណៈរបស់ខ្លួនស្ដីពីគោលការណ៍ទាំង១៤ ដែលនាំទៅដល់ការអនុវត្តយុត្តាធិការសកលប្រកបដោយប្រសិទ្ធភាព។

[១៥:៥១:៤៣]

យើងខ្ញុំអះអាងទៀតថា ការអនុវត្តករណីលើកលែងចំពោះគោលការណ៍នេះ មិនអាចធ្វើឲ្យអន្តរាយដល់គោលការណ៍នៃការបំពេញបន្ថែមឡើយ។ ដែលតាមរយៈគោលការណ៍នៃការបំពេញបន្ថែមនេះ យុត្តាធិការអន្តរជាតិអាចអនុវត្តសមត្ថកិច្ចរបស់ខ្លួនក្នុងករណីដែលយុត្តាធិការជាតិមិនមានសមត្ថភាព ឬមិនមានឆន្ទៈនៅក្នុងការចោទប្រកាន់ឧក្រិដ្ឋកម្មអន្តរជាតិ ដែលស្ថិតនៅក្នុងដែនយុត្តាធិការរបស់ខ្លួន។

ហួសពីអ្វីដែលមេធាវីការពារក្ដីបានលើកឡើងគោលបំណងនៃបញ្ញត្តិស្ដីពីគោលការណ៍គ្មានការកាត់ទោសពីរដងចំពោះអង្គហេតុតែមួយនេះ គឺធ្វើឡើងដើម្បីជាការធានាដ៏សំខាន់មួយសម្រាប់សច្ចភាព

គតិយុត្តិ។ ប៉ុន្តែទោះយ៉ាងណាក៏ដោយ អង្គបុរេជំនុំជម្រះនៅក្នុងកថាខណ្ឌទី១៤៣ នៃសាលដីកាលើបណ្តឹងឧទ្ធរណ៍របស់លោក អៀង សារី ប្រឆាំងនឹងដីកាដំណោះស្រាយក៏បានទទួលស្គាល់ផងដែរថា ផលប្រយោជន៍ដែលទាញចេញពីគោលការណ៍នេះ ត្រូវតែបានថ្លឹងថ្លែងឲ្យមានតុល្យភាពជាមួយនឹងផលប្រយោជន៍របស់សហគមន៍អន្តរជាតិ និងជនរងគ្រោះ ខ្ញុំសូមសង្កត់ធ្ងន់ និងជនរងគ្រោះ។ ដើម្បីធានាថាអ្នកដែលទទួលខុសត្រូវចំពោះបទល្មើសអន្តរជាតិត្រូវបានផ្តន្ទាទោសយ៉ាងត្រឹមត្រូវ។

[១៥:៥២:៥១]

យើងទាំងអស់គ្នាសុទ្ធតែដឹងថា មានសំណួរមួយចំនួនទាក់ទងនឹងឧក្រិដ្ឋកម្មអន្តរជាតិធ្ងន់ធ្ងរដែលតុលាការកំពុងតែប្រឈមមុខនេះ គឺមិនអាចត្រូវបានឆ្លើយតបតាមរយៈគតិយុត្តិតែមួយមុខប៉ុណ្ណោះទេ។ តែតម្រូវការរបស់សង្គមមនុស្ស ទស្សនៈមួយចំនួនអាចបំពេញបន្ថែមទៅលើចម្លើយគតិយុត្តិទាំងអស់នោះបាន។ ហើយខ្ញុំដឹងទៀតថា អង្គជំនុំជម្រះសាលាដំបូងនឹងពិចារណាច្រើនលើអំណះអំណាងច្បាប់ តែខ្ញុំយល់ថា វាជាការប្រសើរដែលអង្គជំនុំជម្រះសាលាដំបូងធ្វើការពិចារណាជាបន្ថែមទៅលើទស្សនៈមួយចំនួនរបស់ជនរងគ្រោះ និងឥទ្ធិពលដែលពួកគាត់ត្រូវទទួលរង។ ក្នុងករណីដែលតុលាការនេះមិនអនុវត្តបទដ្ឋាននីតិវិធីអន្តរជាតិ។

ចំពោះពួកគាត់ដែលជាជនរងគ្រោះ ការជម្រះក្តីមិនប្រកបដោយសមធម៌នៅក្នុងឆ្នាំ១៩៧៩ មិនបានឆ្លើយតបទៅនឹងសិទ្ធិរបស់ពួកគាត់ឡើយ។ គឺសិទ្ធិនៅក្នុងការដឹងពីការពិតនៃរបបដ៏ឃោរឃៅនេះថា តើវាមានអ្វីកើតឡើងខ្លះនៅសម័យនោះ ហើយនិងសិទ្ធិទទួលបានសំណងរបស់ពួកគាត់។ ដូច្នេះ ការចោទប្រកាន់ និងការជំនុំជម្រះក្តីនៅចំពោះមុខតុលាការនេះ គឺជាក្តីសង្ឃឹមតែមួយគត់។ ខ្ញុំសូមបញ្ជាក់ថា គឺជាក្តីសង្ឃឹមតែមួយគត់ដែលពួកគាត់អាចស្តារឡើងនូវសិទ្ធិរបស់ពួកគាត់ ដែលពួកគាត់បានបាត់បង់កន្លងមក។

[១៥:៥៤:០៤]

សូមបញ្ជាក់ទៀតថា ការជម្រះក្តីព្រហ្មទណ្ឌមិនមែនគ្របដណ្តប់តែទៅលើជនដែលត្រូវបានចោទប្រកាន់ប៉ុណ្ណោះទេ តែវាមានការពាក់ព័ន្ធយ៉ាងខ្លាំងទៅដល់ជនរងគ្រោះនៃឧក្រិដ្ឋកម្មដែលស្ថិតនៅក្នុងវិសាលភាពនៃការចោទប្រកាន់។ នៅក្នុងគ្រប់ដំណើរការជម្រះក្តីទាក់ទងនឹងឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ តុលាការមានកាតព្វកិច្ចឆ្លើយតបទៅនឹងការទន្ទឹងរង់ចាំដែលមានលក្ខណៈពិសេស និងដោយឡែករបស់ជនរងគ្រោះ។ គឺជាការទន្ទឹងរង់ចាំនូវការទទួលស្គាល់ការពិតដែលជាអង្គហេតុជាក់ស្តែងមួយ

ដែលបានកើតឡើងយ៉ាងពិតប្រាកដដែលពួកគាត់បានទទួលរង។ ហើយដែលការទទួលស្គាល់នេះ វាបានផ្តល់លទ្ធភាពឲ្យពួកគាត់នៅក្នុងការចាប់ផ្តើមជីវិតរស់នៅសាជាថ្មីនៅក្នុងក្តីសង្ឃឹមដ៏ពិតមួយ។

[១៥:៥៤:៥១]

ដូចដែលអង្គការលើកលែងទោសអន្តរជាតិបានប្រកាសនៅក្នុងឯកសារដែលខ្ញុំបានលើកឡើងកាលពីពេលមុននេះបន្តិចថា សហគមន៍អន្តរជាតិទាំងមូលមានប្រយោជន៍ស្របច្បាប់នៅក្នុងការទាមទារឲ្យមានការចោទប្រកាន់ដោយអនុលោមទៅតាមច្បាប់អន្តរជាតិនៅឧក្រិដ្ឋកម្មអន្តរជាតិធ្ងន់ធ្ងរ ដើម្បី៖

ទីមួយ បញ្ឈប់ការវិលត្រឡប់មកវិញនូវឧក្រិដ្ឋកម្មទាំងអស់នេះនៅក្នុងពេលអនាគត។ ទីពីរ ផ្តន្ទាទោសឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តនៅក្នុងអតីតកាល និងទីបី ផ្តល់ឲ្យជនរងគ្រោះនូវសំណងដ៏សមស្រប។

ខ្ញុំអះអាងថា ជនរងគ្រោះនឹងមិនបានទទួលនូវសំណងដ៏សមស្របឡើយ ប្រសិនបើការចោទប្រកាន់ទទួលនូវបរាជ័យ។

ជនរងគ្រោះទន្ទឹងចង់បានសំណងមួយ ដែលមានអត្ថន័យទូលាយជាងអត្ថន័យធម្មតានៃសំណងជាទូទៅ។ ពួកគាត់គឺជាម្ចាស់នៃផលប្រយោជន៍នៃការទទួលបាននូវការចងចាំជាសាកលមួយ។ កាលដែលពួកគាត់ស្គាល់ ការដែលពួកគាត់យល់ច្បាស់នៅអតីតកាលដែលជាប្រវត្តិសាស្ត្ររបស់ខ្លួន។ ជាកត្តាចាំបាច់ និងជាចំណុចចាប់ផ្តើមនៃការកសាងប្រជាជនខ្មែរជំនាន់ក្រោយមួយប្រកបដោយអានុភាព។

នាងខ្ញុំសូមលើកថា នេះគឺជាមូលហេតុមួយនៃការចូលរួមរបស់ជនរងគ្រោះ តាំងពីដំណើរការក្តីនៅចំពោះមុខតុលាការយោធា នូរិមប៊ឺក រហូតមកដល់ អ.វ.ត.ក នេះមានការរីកចម្រើនៗ។

អំពើឃោរឃៅដែលកើតឡើងចេញពីឧក្រិដ្ឋកម្មនៃសង្គ្រាមលោកលើកទីពីរបានដាស់សម្បជញ្ញៈសហគមន៍អន្តរជាតិឲ្យធ្វើការយកចិត្តកដាក់ទៅលើតម្រូវការនៃសង្គមមនុស្ស គឺជាតម្រូវការទាមទារឲ្យបញ្ចប់នូវនិទ្ទណ្ឌភាពនៃឧក្រិដ្ឋកម្មអន្តរជាតិធ្ងន់ធ្ងរ។

ហើយខ្ញុំជឿជាក់ថានេះក៏ជាមូលហេតុដែលថា ឧក្រិដ្ឋកម្មអន្តរជាតិធ្ងន់ធ្ងរទាំងឡាយគឺមិនត្រូវបានបញ្ញត្តិថា មានអាជ្ញាយុកាលនៃការផុតរលត់នៃបណ្តឹងអាជ្ញាឡើយ។

[១៥:៥៦:៣៥]

ចំពោះជនរងគ្រោះនៃការបំពារបំពារធ្ងន់ធ្ងរលើសិទ្ធិជាសារវន្តរបស់មនុស្ស និទ្ទណ្ឌភាពមិនត្រូវបានសំដៅទៅតែការធ្វើការចោទប្រកាន់លើឧក្រិដ្ឋកម្មប៉ុណ្ណោះទេ ប៉ុន្តែវាត្រូវបានយល់ឃើញដោយលាតសន្ធឹងទៅដល់ការជម្រះក្តីដែលមិនប្រកបដោយសមធម៌ ដែលក្នុងនោះត្រូវបានរាប់បញ្ចូលផងដែរទៅនឹង

ការមិនអើពើទៅលើសិទ្ធិ និងទស្សនៈយល់ឃើញរបស់ពួកគាត់។

ហើយខ្ញុំសូមជម្រាបជូនផងដែរថា ប្រសិនបើតុលាការ អ.វ.ត.ក នេះមិនអនុវត្តករណីលើកលែងនៃគោលការណ៍គ្មានការកាត់ទោសពីរដងចំពោះអង្គហេតុតែមួយនេះទេ គឺវាន័យស្មើនឹងការទទួលស្គាល់ដោយស្ងៀមស្ងាត់នូវវប្បធម៌នៃនិទ្ទណ្ឌភាព។ ហើយខ្ញុំជឿថា វប្បធម៌នេះវាមិនមែនជាការប្រាថ្នារបស់ប្រជាជនក៏ដូចជារដ្ឋាភិបាលកម្ពុជានោះទេ។

ខ្ញុំសូមលើកឧទាហរណ៍មួយជូនដល់អង្គជំនុំជម្រះទាក់ទងជាមួយនឹងករណីយុត្តិសាស្ត្រមួយនៅប្រទេសបារាំង។ ក្នុងឆ្នាំ១៩៧៩ លោក ប៉ូល ទូវីយ៉េ គាត់ចូលរួមនៅក្នុងការធ្វើទុក្ខបុកម្នេញជនជាតិជ្វីស ហើយប្រឆាំងទៅនឹងក្រុមដែលមានទំនោរនិន្នាការប្រឆាំងជាមួយនឹងអំណាចផ្តាច់ការណាហ្ស៊ី។ ក្នុងឆ្នាំ១៩៤៦ គាត់ត្រូវបានផ្តន្ទាទោសប្រហារជីវិតដោយកំបាំងមុខដោយតុលាការឧក្រិដ្ឋទីក្រុងលីយ៉ុងប្រទេសបារាំង តែទោសនេះមិនត្រូវបានអនុវត្តឡើយ។ ខែវិច្ឆិកា ឆ្នាំ១៩៧១ គាត់ទទួលបានការលើកលែងទោសពីប្រធានាធិបតីសាធារណរដ្ឋបារាំងលោក ហ្សក ប៉ុមពីឌូ តែដោយមានប្រតិកម្មយល់ស្របមិនខ្លាំងក្លាពីសំណាក់ជនរងគ្រោះនិងសមាគមន៍ ជនដែលប្រឆាំងនឹងអំណាចផ្តាច់ការណាហ្ស៊ី ពួកគេបានដាក់បណ្តឹងសាជាថ្មី ពួកគេបានខំប្រឹងជំរុញឲ្យបណ្តឹងអាជ្ញានេះមានចលនាប្រឆាំងនឹងលោក ប៉ូល ទូវីយ៉េ ដោយទាមទារឲ្យលោកទទួលខុសត្រូវពីបទផ្សំគំនិតក្នុងការប្រព្រឹត្តឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ។ ការបើកកិច្ចស៊ើបសួរជាផ្លូវការបានចាប់ផ្តើមនៅក្នុងឆ្នាំ១៩៧៩ គឺរយៈជាង៣០ឆ្នាំ ក្រោយពីអង្គហេតុឧក្រិដ្ឋកម្ម។ តុលាការឧក្រិដ្ឋរបស់បារាំងបានផ្តន្ទាទោសដាក់ពន្ធនាគារគាត់អស់មួយជីវិត។

[១៥:៥៨:៤១]

ខ្ញុំលើកឧទាហរណ៍នេះ ខ្ញុំចង់បង្ហាញឲ្យអង្គជំនុំជម្រះនៅទីនេះឃើញនូវកម្លាំងនៃការតស៊ូរបស់ជនរងគ្រោះថា មិនថាជាពួកគេរស់រានមានជីវិតពីជ្រុងណានៃពិភពលោកទេ តែពួកគេមិនអាចទទួលបានឡើយនូវនិទ្ទណ្ឌភាពនៃឧក្រិដ្ឋកម្មអន្តរជាតិធ្ងន់ធ្ងរ។ ហើយការរំពឹងគិត និងការទាមទារ និងទស្សនៈរបស់ពួកគេត្រូវបានតុលាការឧក្រិដ្ឋប្រទេសបារាំងពិចារណា ហើយយល់ស្របតាម។

ខ្ញុំជឿជាក់ថាក្នុងនាមជនរងគ្រោះ ជឿជាក់ថាអ.វ.ត.ក នឹងមិនបោះជំហានថយក្រោយឡើយ។ អ.វ.ត.ក នឹងនៅតែបន្តស្តាប់សំឡេងជនរងគ្រោះ ពិចារណាលើទស្សនៈរបស់គាត់ក្នុងការស្វែងរកការពិតតាមរយៈការបំបែកការស្ងៀមស្ងាត់ដែលពួកគាត់បានទទួលរងជាង៣០ឆ្នាំ។

ដូច្នេះ ខ្ញុំសូមស្នើថា ការទាមទាររបស់មេធាវីការពារក្តីទាក់ទងនឹងការអនុវត្តគោលការណ៍គ្មាន

ការកាត់ទោសពីរដងចំពោះបទល្មើសតែមួយ បានបំពានយ៉ាងធ្ងន់ធ្ងរលើសិទ្ធិរបស់ជនរងគ្រោះ ហើយការជម្រះក្តីនៅឆ្នាំ១៩៧៩ មិនត្រូវបានធ្វើឡើងដោយយុត្តិធម៌ ហើយក៏មិនអាចរារាំងការចោទប្រកាន់រូបលោកនៅចំពោះមុខតុលាការនេះដែរ។

នាងខ្ញុំសូមអនុញ្ញាតផ្ទេរវេទិកានេះជូនលោកស្រីមេធាវី ម៉ាទីន ហ្សាកកាំង។ សូមអរគុណ។

[១៦:០០:០០]

**លោកស្រី ម៉ាទីន ហ្សាកកាំង៖**

លោកប្រធាន លោកស្រីចៅក្រម ជាទីគោរព!

ជាបឋមខ្ញុំសូមសប្បាយចិត្តដែលបានមកនិយាយនៅទីនេះ ដើម្បីដើមបណ្តឹងរដ្ឋប្បវេណី។ ខ្ញុំនឹងប្រើពេលវេលាពីរបីនាទីរបស់ខ្ញុំ ដើម្បីស្នើសុំនូវគំនិតបី។ ទីមួយ គឺទាក់ទងនឹងសាលក្រមនៅខែសីហា ឆ្នាំ១៩៧៩។ ទីពីរ ទាក់ទងទៅនឹងពាក្យសម្តីរបស់ជនជាប់ចោទ និងទីបី ទាក់ទងទៅនឹងយុត្តិសាស្ត្រទូយ៉េ។

ជាបឋម ខ្ញុំគិតថា ជាការចាប់អារម្មណ៍ដើម្បីលើកយកចំណុចមួយចំនួននៃសាលក្រមឆ្នាំ៧៩ នេះមកនិយាយ។ ខ្ញុំចង់ឲ្យជនជាប់ចោទទាំងអស់នោះ មានសេចក្តីក្លាហានក្នុងការមិនទទួលស្គាល់យុត្តាធិការតុលាការនៅសម័យនោះ ហើយនិងពន្យល់ទៅដល់ដើមបណ្តឹងរដ្ឋប្បវេណីថា នៅពេលណាហើយហេតុអ្វីបានជាបង្កើតគម្រោងនយោបាយបដិវត្តន៍ហ្នឹង បង្កើតឲ្យមានការភ័យខ្លាច ហើយនិងការធ្វើទារុណកម្ម និងសម្លាប់មនុស្ស។ ក៏ប៉ុន្តែផ្ទុយទៅវិញ មកដល់ពេលនេះទៅហើយ លោកនៅតែសុំឲ្យមាននិទ្ទណ្ឌភាព ហើយនិងបដិសេធតថភាពដែលមាននៅប្រទេសកម្ពុជា នៅចន្លោះឆ្នាំ១៩៧៥ ហើយនិង១៩៧៩ ហើយនិងលាក់ខ្លួននៅក្រោយសាលក្រមនៅឆ្នាំ១៩៧៩ ហើយបន្ទាប់មកទៀត និងមានការអនុគ្រោះទោសដោយ ព្រះករុណា។

ឈ្មោះតុលាការនេះ គឺឈ្មោះតុលាការ ប្រជាជនបដិវត្តន៍ ដែលស្ថិតនៅទីក្រុងភ្នំពេញ ហើយនិងដែលធ្វើកាត់សេចក្តីលើឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ដែលប្រព្រឹត្តដោយបនប៉ុល ពត, អៀង សារី។ ហើយក្រឹត្យច្បាប់ថ្ងៃទី១៥ កក្កដា ឆ្នាំ១៩៧៩ ហាក់ដូចជាបង្កើតតុលាការដើម្បីកាត់ទោសលើឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ ប៉ុល ពត និងអៀង សារី នោះ កាលនោះ ត្រូវចោទប្រកាន់ពីបទដូចតទៅនេះ៖

[១៦:០២:០៤]

គឺការអនុវត្តផែនការសម្លាប់ដោយរង្គាលជាប្រព័ន្ធកាន់តែខ្លាំងៗទៅ ទៅលើកម្មាភិបាល និង

ប្រជាជន និងជាពិសេសទៅនឹងរាជការនិងប្រជាជន ដែលរស់នៅក្រោមរដ្ឋបាល លន់ នល់។ ការសម្លាប់ជនជាតិភាគតិច ហើយនិងការសម្លាប់អ្នកជំទាស់ ដែលថាអាចមានគ្រោះថ្នាក់ដល់ខ្លួន ហើយនិងជម្លៀសដោយបង្ខំ និងចេញពីទីក្រុង និងធ្វើផ្លាស់ទីប្រជាជន ដែលបង្កឲ្យមានមនុស្សស្លាប់ជាច្រើននាក់។ ហើយនិងការបង្កើតរបបមួយ មានការជិះជាន់និងការបង្ខំ និងឲ្យមនុស្សបង្ខំរហូតដល់អស់កម្លាំង ហើយនិងធ្វើឲ្យមនុស្សក្លាយជាទាសករ បំបាក់កម្លាំង និងកម្លាំងកាយនិងកម្លាំងចិត្ត។ បំផ្លាញទំនាក់ទំនងសង្គម ហើយនិងរឹតត្បិតសិទ្ធិសេរីភាពក្នុងការពិចារណា មនុស្សក្លាយទៅជាទាសករ ឯកាហើយនិងមានតែគោរពអង្គការតែប៉ុណ្ណោះ។ ការបំបាត់ជាដាច់ខាត នូវអ្នកសាសនាព្រះសង្ឃ ហើយនិងអ្នកកាន់សាសនាអ៊ីស្លាម អ្នកជំនឿផ្សេងៗ និងបច្ចុប្បន្នជាដើម។ សម្លាប់កុមារ និងធ្វើឲ្យក្មេងជំទង់ក្លាយទៅជាអ្នកធ្វើការ ធ្វើទារុណកម្ម បន្ទាប់មកទៀតគឺបំផ្លាញសេដ្ឋកិច្ចជាតិ និងធ្វើទារុណកម្មប្រជាជនបង្អត់អាហារ។ នេះគឺជាបទចោទដែលសហព្រះរាជអាជ្ញាបានលើកឡើងនៅពេលនោះ ហើយមានសាក្សីដែលបានគេស្តាប់នៅពេលនោះ ហើយមានការសរសេររបាយការណ៍-- ដាក់របាយការណ៍នៅពេលនោះ។ ហើយការប្រកាសទោសប្រហារជីវិតទៅលើលោក អៀង សារី មេធាវីបាននិយាយដើមបណ្តឹងរដ្ឋប្បវេណីបានការពារ ហើយមានមេធាវីមួយរូបដែលបានការពារទំនួលខុសត្រូវរបស់លោក គឺលោក អៀង សារី ហ្នឹងតែម្តង។ លោកមិនមានវត្តមានទេនៅពេលនោះ ប៉ុន្តែមេធាវីលោកត្រូវបានគេស្តាប់ ហើយមានការចេញសាលក្រម គឺថាលោកថាមានទទួលទំនួលខុសត្រូវ ហើយនិងគេកាត់ទោសប្រហារជីវិតលោក។ ក៏ប៉ុន្តែលោក លោក អៀង សារី លោកមិនដែលបានទទួលស្គាល់សុពលភាពនៃសាលក្រមនោះទេ លោកបានជ្រើសរើសយកសេចក្តីសម្រេចនេះ ហើយនិងមិនបានទទួលផលវិបាកនោះទេ។ នេះគឺជាការជ្រើសរើសរបស់លោក។

[១៦:០៥:៤២]

នៅក្នុងការសម្ភាសន៍ជាមួយនឹងលោក ហ្សង់ ហ្វ្រង់ស្វ័រ តាំង នៅខែវិច្ឆិកា ឆ្នាំ១៩៩៦ លោកបានប្រកាសជាសាធារណៈតាមវិទ្យុថា ទៅលោក-- សូមរំឭកថា តុលាការបដិវត្តនៅឆ្នាំ១៩៧៩ ដែលបានកាត់ទោសខ្ញុំ ប្រហារជីវិតខ្ញុំមិនមានភាពស្របច្បាប់នោះទេ ពីព្រោះថាគឺជាតុលាការដែលរៀបចំឡើងនៅក្រោមការកាន់កាប់របស់វៀតណាម។ ដូច្នេះ គ្មានប្រយោជន៍អីដែលត្រឡប់មកក្រោយវិញទេ ខ្ញុំមិនមានពិរុទ្ធភាពនោះទេ។

ឆ្លើយតបទៅនឹងសំណួររបស់លោក ហ្សង់ ហ្វ្រង់ស្វ័រ តាំង លោក អៀង សារី-- នៅក្នុងករណី

ដែលមានការបង្កើតតុលាការក្នុងពេលឆាប់នេះ តុលាការអន្តរជាតិ ឬក៏អន្តរជាតិដើម្បីកាត់ទោសលើឧក្រិដ្ឋកម្មរបស់ពួកខ្មែរក្រហម តើលោកគិតថា លោកអាចរួចផុតពីយុត្តិធម៌ដែរឬទេ? លោកបានឆ្លើយថា លោកដឹងថា ថាតុលាការអន្តរជាតិ គឺថាការកាត់ក្តីមិនកើតមានឡើងនៅប្រទេសកម្ពុជានោះទេ។ ខ្ញុំមិនអាចទទួលកាលដែរថា មានការប្រល័យពូជសាសន៍នៅប្រទេសកម្ពុជានោះទេ។ ក៏ប៉ុន្តែអ្វីដែលយើងត្រូវតែទទួលស្គាល់នោះ គឺថាការដាក់អនុវត្តនយោបាយនៅសម័យនោះ គឺថាបង្កឲ្យមានការខូចខាតនឹងសោកនាដកម្មដ៏សម្បើមលើប្រជាជនកម្ពុជា។ ខ្ញុំចង់និយាយថា ខ្ញុំសោកស្តាយខ្លាំងណាស់។ តើលោកអៀង សារី តើហេតុអ្វីក៏លោកជំទាស់មិនព្រមនិយាយចំពោះមុខប្រជាជនកម្ពុជានៅថ្ងៃនេះ? ចំពោះមុខតុលាការអន្តរជាតិនៅប្រទេសកម្ពុជា ដែលផ្តល់វេទិកាដល់លោក ហើយនិងត្រៀមខ្លួនស្តាប់លោក?

[១៦:០៦:៣២]

នៅទីបញ្ចប់ខ្ញុំនឹងនិយាយអំពីយុត្តិសាស្ត្រ ទូវីយ៉េ នៅថ្ងៃ១០ កញ្ញា ១៩៤៦ លោក ប៉ូល ទូវីយ៉េ ត្រូវបានផ្តន្ទាទោសឲ្យស្លាប់ដោយអស់មួយជីវិត ដោយកំបាំងមុខ ហើយនៅឆ្នាំ១៩៤៧នោះ ក៏ត្រូវកាន់កាត់ទោសដោយតុលាការមួយទៀត កាត់ទោសប្រហារជីវិតផងដែរ។

ហើយពេលក្រោយមកគាត់ត្រូវបានលើកលែងទោស ដោយក្រឹត្យរបស់លោកប្រធានាធិបតី បារាំង ហ្សក ប៉ុមពីឌូ នៅឆ្នាំ១៩៧២។ ការលើកលែងទោសនេះទាក់ទងទៅនឹងការកាត់ទោសប្រហារជីវិតទាំងពីរនេះតែម្តង គឺថាឆ្នាំ១៩៤៦ ហើយនិងឆ្នាំ១៩៤៧ នៅសំបេរី, ៤៦ នៅទីក្រុងលីយ៉ុង។ នៅឆ្នាំ១៩៧៣ នៅលីយ៉ុង ហើយនិងឆ្នាំ១៩៧៤ នៅសំបេរី កូនរបស់ជនរងគ្រោះបានដាក់បណ្តឹងពីរប្រឆាំងនឹងបទឧក្រិដ្ឋប្រឆាំងនឹងមនុស្សជាតិ។

[១៦:០៧:៣៨]

នៅឆ្នាំ១៩៧៦ សាលាវិនិច្ឆ័យ ដោយឈរលើមូលដ្ឋានលើអនុសញ្ញាអន្តរជាតិបានប្រកាសថា បណ្តឹងអាជ្ញាមិនរលត់អាជ្ញាយុកាលនោះទេ។ បន្ទាប់មកទៀត សាលាវិនិច្ឆ័យតាមរយៈសាលដីកាចុះថ្ងៃ ១២ តុលា ឆ្នាំ១៩៨៣ បានបដិសេធបណ្តឹងសាទុក្ខរបស់ទូវីយ៉េ ដោយមូលហេតុថាវិធានគោលការណ៍មិនកាត់សេចក្តីពីរដងមិនអាចអនុវត្តបានក្នុងករណីនេះទេ។ ដោយយោងលើការកំណត់ប្រភេទអង្គហេតុថ្មី ដែលហៅថា ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិនោះ។ តាមរយៈសាលដីកាថ្ងៃទី២០ មេសា ឆ្នាំ១៩៧៤ ប៉ូល ទូវីយ៉េ ត្រូវបានកាត់ទោសអស់មួយជីវិត ពីបទដែលផ្សំគំនិតធ្វើឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ។

[១៦:០៨:៤៦]

ដើម្បីបញ្ចប់ អស់លោកលោកស្រីចៅក្រមជាទីគោរព! គំនិតរបស់ខ្ញុំមានដូចតទៅនេះ៖ តើយុត្តិធម៌អាចជួយធ្វើឲ្យការឈឺចាប់ជនរងគ្រោះនោះបានសះស្បើយនោះទេ? យុត្តិធម៌បានត្រឹមតែថាជួសជុលអ្វីដែលអាចជួសជុលបាន ហើយនិងព្យសនកម្មដែលអាចសងជាលុយកាក់បានតែប៉ុណ្ណោះទេ ហើយមិនអាចព្យាបាលអ្វីដែលមិនអាចព្យាបាល ហើយជាពិសេសដូចជាការស្មានរបួសដែលថា មានរហូតមួយជីវិតទាំងផ្លូវចិត្ត និងផ្លូវកាយនោះ។ ក៏ប៉ុន្តែ ការជម្រះសេចក្តីអាចនាំយើងទៅដល់ឲ្យដឹងការពិត ហើយនិងទទួលស្គាល់អង្គហេតុ ហើយនិងធ្វើឲ្យមានលំនឹងថ្មីដល់ជនរងគ្រោះ ហើយនិងបើកផ្លូវទៅដល់ការងារកាន់ទុក្ខ។ ហើយនិងអាចធ្វើឲ្យជនរងគ្រោះ និងដើមបណ្តឹងរដ្ឋប្បវេណីក្នុងការសម្តែងនូវសេចក្តីចង់បានសំណងរបស់ខ្លួន ហើយគឺនៅពេលនេះហើយដែលសំណូមពររបស់ដើមបណ្តឹងរដ្ឋប្បវេណីដែលសង្ឃឹមថាគេនឹងស្តាប់ខ្លួននៅចំពោះមុខតុលាការនេះ ហើយជាពិសេសគឺជនជាប់ចោទតែម្តង។

សូមអរគុណលោកប្រធាន។

[១៦:១០:០២]

**ប្រធានអង្គជំនុំ៖**

បាទ, អរគុណលោកស្រីមេធាវី។ ឥឡូវនេះឃើញថា ពេលវេលាមមាញឹក ហើយតឹងតែងដែរដោយសារមិនមានឈប់សម្រាកនៅពាក់កណ្តាលម៉ោង។ ឃើញថា ដល់ពេលត្រូវគួរត្រូវឈប់សម្រាកហើយ។ ដូច្នេះ អង្គជំនុំជម្រះប្រកាសសម្រាកដំណើរការសវនាការសម្រាប់ថ្ងៃនេះ ត្រឹមនេះ ហើយសវនាការនឹងលើកបន្តទៅដំណើរការនៅថ្ងៃស្អែកចាប់វេលាម៉ោងប្រាំបួនព្រឹក។

[១៦:១០:៤៥]

អនុរក្សមន្ទីរឃុំឃាំងឲ្យនាំជនជាប់ចោទ ខៀវ សំផន និង អៀង សារី ត្រឡប់ទៅកាន់មន្ទីរឃុំឃាំងវិញ ហើយស្អែកព្រលឹមឡើងបង្គាប់ឲ្យនាំជនជាប់ចោទទាំងបួននាក់ មកកាន់បន្ទប់សវនាការនេះឲ្យបានមុនម៉ោងប្រាំបួនព្រឹកជាកំណត់។

**លោកស្រី សែ កុលវុឌ្ឍី៖**

សូមអញ្ជើញក្រោកឈរ!

*(សវនាការផ្អាកនៅម៉ោង ១៦:១១ នាទី)*